ហើយពិចារណានូវកុសលនោះ នូវកុសលទាំងឡាយ ដែលសន្សំល្អហើយ ក្នុងកាលមុន ... ចេញអំពីឈាន ហើយពិចារណានូវឈាន ព្រះអរិយៈទាំងឡាយពិចារណានូវផល ពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទាន: និងផល ដោយអារម្មណប្បច្ច័យ ព្រះអរិយៈទាំងឡាយ តែងពិចារណានូវពួកកិលេសដែលមិនទៀង ដែលលះបង់ហើយ នូវកិលេសដែលសង្កត់សង្កិនហើយ ... ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... នូវចក្ខុ ... នូវវត្ថុ ... ឃើញនូវពួកខន្ធដែលមិនទៀង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ រាគៈដែលមិនទៀង ប្រារព្ធនូវខន្ធនោះ ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយចិត្ត ដែលមិនទៀង ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយអារម្មណប្បច្ច័យ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ពួកខន្ធដែលមិនទៀង ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ១៥៥ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយអារម្មណប្បច្ច័យ គឺរូបជីវិតិន្ទ្រិយ ជាបច្ច័យនៃមាតុឃាតកម្ម

បិតុឃាតកម្ម អរហន្តឃាតកម្ម និងរុហិរុប្បាទកម្ម ដោយអារម្មណប្បច្ច័យ ពួកខន្ធ ដែលមានសភាពខុស និងទៀងរបស់បុគ្គលកាលស្ទាបអង្អែលនូវវត្ថុណា កើតឡើង វត្ថុនោះ ជាបច្ច័យនៃពួកខន្ធ ដែលមានសភាពខុស និងទៀង ដោយអារម្មណប្បច្ច័យ ។

[ ១៥៦ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀង ដោយអារម្មណប្បច្ច័យ គឺព្រះនិព្វាន ជាបច្ច័យនៃមគ្គ ដោយអារម្មណប្បច្ច័យ ។

[ ១៥៧ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ១៥៨ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។

[ ១៥៩ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀងផង ធម៌ដែលមិនទៀងផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ១៦០ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ១៦១ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ធ្វើនូវមគ្គ ឲ្យជាទីគោរព ហើយពិចារណា ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។

[ ១៦២ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀងផង ធម៌ដែលមិនទៀងផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ដែលមានសភាពត្រូវ និងទៀង ( ជាបច្ច័យ ) នៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ។

[ ១៦៣ ] ធម៌ដែលមិនទៀង ជាបច្ច័យនៃធម៌ ដែលមិនទៀង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន នូវសីល ... ឧបោសថកម្ម ... ធ្វើនូវកុសលនោះឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវពួកកុសលដែលសន្សំល្អហើយក្នុងកាលមុនឲ្យជាទីគោរព ហើយពិចារណា ព្រះអរិយៈទាំងឡាយ ធ្វើនូវផល ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ... ព្រះនិព្វាន

ជាបច្ច័យនៃគោត្រភូ វោទាន: និងផល ដោយអធិបតិប្បច្ច័យ បុគ្គលធ្វើនូវចក្ខុ ... នូវវត្ថុ ... ធ្វើនូវពួកខន្ធដែលមិនទៀង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគ:ដែលមិនទៀង ធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលមិនទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ១៦៤ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ ដែលមានសភាពត្រូវ និងទៀង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺព្រះនិព្វានជាបច្ច័យនៃមគ្គ ដោយអធិបតិប្បច្ច័យ ។

[ ១៦៥ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃវុដ្ឋាន: ដោយអនន្តរប្បច្ច័យ ។

[ ១៦៦ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀងដោយអនន្តរប្បច្ច័យ គឺមគ្គជាបច្ច័យនៃផលដោយអនន្តរប្បច្ច័យ ។

[ ១៦៧ ] ធម៌ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធ ដែលមិនទៀងមុនៗ ជាបច្ច័យនៃពួកខន្ធ ដែលមិនទៀងក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: ផល ( ជាបច្ច័យ ) នៃផល អនុ-លោម ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតន: របស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ១៦៨ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយអនន្តរប្បច្ច័យ គឺទោមនស្សដែលមិនទៀងជាបច្ច័យនៃទោមនស្សដែលមានសភាពខុស និងទៀង ដោយអនន្តរប្បច្ច័យ អនិយតមិច្ឆាទិដ្ឋិ ( ជាបច្ច័យ ) នៃនិយតមិច្ឆាទិដ្ឋិ ដោយអនន្តរប្បច្ច័យ ។

[ ១៦៩ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀង ដោយអនន្តរប្បច្ច័យ គឺគោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ជាបច្ច័យនៃមគ្គ ដោយអនន្តរប្បច្ច័យ ។

[ ១៧០ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយសមនន្តរប្បច្ច័យ គឺប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ ប្រស្នា ៩ មានសេចក្តីប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺប្រស្នា ៣ មានសេចក្តីប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺប្រស្នា ១៣ មានសេចក្តីប្រហែលគ្នានឹងកុសលត្តិកៈដែរ ។

[ ១៧១ ] ធម៌ដែលមានសភាពខុសនិងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុសនិងទៀង ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺមាតុឃាតកម្ម ជាបច្ច័យនៃបិតុឃាតកម្ម ដោយឧបនិស្សយប្បច្ច័យ មាតុ-ឃាតកម្ម ... បិតុឃាតកម្ម ... អរហន្តឃាតកម្ម ... រុហិរុប្បាទកម្ម ... សង្ឃ-ភេទកម្ម ... ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ ។ ចក្ក: បណ្ឌិតគប្បីធ្វើផងចុះ ។ និយតមិច្ឆាទិដ្ឋិ ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ដោយ

ឧបនិស្សយប្បច្ច័យ និយតមិច្ឆាទិដ្ឋិ ជាបច្ច័យនៃមាតុឃាតកម្ម ... នៃសង្ឃ-ភេទកម្ម ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧២ ] ធម៌ ដែលមានសភាពខុស និងទៀង ( ជាបច្ច័យ ) នៃធម៌ ដែលមិនទៀង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យនិង បកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលផ្តាច់ជីវិតមាតា ហើយឲ្យទាន សមាទានសីល ធ្វើនូវឧបោសថកម្ម ដើម្បីប្រយោជន៍ឃាត់ឃាំងនូវផលនៃ កម្មនោះ ផ្តាច់ជីវិតបិតា ... ជីវិតព្រះអរហន្ត ... ញុំាងលោហិតនៃព្រះតថាគត ដោយទោសចិត្ត ... បំបែកសង្ឃ នូវទាន ... នូវសីល ... ធ្វើឧបោសថកម្ម ដើម្បីប្រយោជន៍ឃាត់ឃាំងនូវផលនៃកម្មនោះ ។

[ ១៧៣ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ( ជាបច្ច័យ ) នៃធម៌ ដែលមានសភាពត្រូវ និងទៀង ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូ-បនិស្ស័យ គឺបឋមមគ្គ ( ជាបច្ច័យ ) នៃទុតិយមគ្គដោយឧបនិស្សយប្បច្ច័យ តតិយមគ្គ ( ជាបច្ច័យ ) នៃចតុត្ថមគ្គ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧៤ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ( ជាបច្ច័យ ) នៃធម៌ ដែលមិនទៀង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺព្រះអរិយៈទាំង ឡាយ អាស្រ័យនូវមគ្គ ហើយញុំាងសមាបត្តិ ដែលមិនទាន់កើត ឲ្យកើត ឡើង ចូលកាន់សមាបត្តិដែលកើតឡើងហើយ ឃើញច្បាស់នូវសង្ខារទាំង ឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន មគ្គ ជាបច្ច័យនៃអត្ថប្បដិសម្ភិទា

របស់ពួកព្រះអរិយៈ ... នៃឋានាឋានកោសល្ល ដោយឧបនិស្សយប្បច្ច័យ មគ្គជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧៥ ] ធម៌ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ដែលមិនទៀងហើយឲ្យទាននូវសីល ... នូវឧបោសថកម្ម ... ញុំាងឈាន ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ... នូវមានះ ... ប្រកាន់ទិដ្ឋិ នូវសីលដែលមិនទៀង ... នូវសុតៈ ចាគៈ បញ្ញា រាគៈ បត្ថនា កាយិកសុខ កាយិកទុក្ខ រដូវ និងភោជន ... អាស្រ័យនូវសេនាសនៈ ហើយឲ្យទាន ... សម្លាប់អ្នកនិគម សទ្ធាដែលមិនទៀង ... បញ្ញា ... រាគៈ ... សេនាសនៈ ជាបច្ច័យនៃសទ្ធាដែលមិនទៀង នៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃបឋមជ្ឈាន ( ជាបច្ច័យ ) នៃបឋមជ្ឈាននោះឯង បរិកម្មនៃនេវសញ្ញានាសញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈនោះឯង បឋមជ្ឈាន ( ជាបច្ច័យ ) នៃទុតិយជ្ឈាន អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ បាណាតិបាត ជាបច្ច័យនៃបាណាតិបាត ដោយឧបនិស្សយប្បច្ច័យ ។ ចក្កៈ បណ្ឌិតគប្បីធ្វើផងចុះ ។

[ ១៧៦ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ ដែលមានសភាពខុសនិងទៀង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈ ដែលមិនទៀង

ហើយផ្តាច់ជីវិតមាតា ... បំបែកសង្ឃ ទោសៈ ដែលមិនទៀង ... បត្ថនា ... កាយិកសុខ ... អាស្រ័យនូវសេនាសនៈ ហើយផ្តាច់ជីវិតមាតា ... បំបែកសង្ឃ រាគៈដែលមិនទៀង ... សេនាសនៈ ជាបច្ច័យនៃមាតុឃាតកម្ម បិតុឃាតកម្ម អរហន្តឃាតកម្ម រុហិរុប្បាទកម្ម សង្ឃភេទកម្ម និងនិយតមិច្ឆាទិដ្ឋិ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧៧ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបរិកម្មនៃបឋមមគ្គ ( ជាបច្ច័យ ) នៃបឋមមគ្គ បរិកម្មនៃចតុត្ថមគ្គ ជាបច្ច័យនៃចតុត្ថមគ្គ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧៨ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ... ត្រេកអររីករាយ រាគៈដែលមិនទៀងប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង នូវរូបដោយទិព្វចក្ខុ ... ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ... វត្ថុជាបច្ច័យនៃពួកខន្ធដែលមិនទៀង ដោយបុរេជាតប្បច្ច័យ ។

[ ១៧៩ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ ដែលមានសភាពខុស

និងទៀង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺរូបជីវិតិន្ទ្រិយ ជាបច្ច័យនៃមាតុឃាតកម្ម បិតុឃាតកម្ម អរហន្តឃាតកម្ម និងរុហិរុប្បាទកម្ម ។បេ។ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុ-បុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលមានសភាពខុស និងទៀង ដោយបុរេជាតប្បច្ច័យ ។

[ ១៨០ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀង ដោយបុរេជាតប្បច្ច័យ បានដល់ វត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលមានសភាពត្រូវ និងទៀង ដោយបុរេជាតប្បច្ច័យ ។

[ ១៨១ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធដែលមានសភាពខុស និងទៀង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជា-តប្បច្ច័យ ។

[ ១៨២ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀងដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨៣ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធដែលមិនទៀង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨៤ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយ

អាសេវនប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមិនទៀង ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនទៀង ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោមជាបច្ច័យនៃវោទាន: ដោយអាសេវនប្បច្ច័យ ។

[ ១៨៥ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយអាសេវនប្បច្ច័យ គឺទោមនស្សដែលមិនទៀង ជាបច្ច័យនៃទោមនស្សដែលមានសភាពខុស និងទៀង ដោយអាសេវនប្បច្ច័យ អនិយតមិច្ឆាទិដ្ឋិ ជាបច្ច័យនៃនិយតមិច្ឆាទិដ្ឋិ ដោយអាសេវនប្បច្ច័យ ។

[ ១៨៦ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ ដែលមានសភាពត្រូវ និងទៀង ដោយអាសេវនប្បច្ច័យ គឺគោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ១៨៧ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយកម្មប្បច្ច័យ គឺចេតនាដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ១៨៨ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិក: ។ សហជាត គឺចេតនាដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិក: គឺចេតនា ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកវិបាកក្ខន្ធផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ១៨៩ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមាន

សភាពខុស និងទៀងផង ធម៌ដែលមិនទៀងផង ដោយកម្មប្បច្ច័យ បានដល់ចេតនា ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ១៩០ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវនិងទៀង ដោយកម្មប្បច្ច័យ គឺចេតនា ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ១៩១ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហ-ជាត គឺចេតនាដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ១៩២ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ ដែលមានសភាពត្រូវ និងទៀងផង ធម៌ដែលមិនទៀងផង ដោយកម្មប្បច្ច័យ គឺចេតនា ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ១៩៣ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលមិនទៀង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ឯនានាខណិកៈ គឺចេតនាដែល

មិនទៀងជាបច្ច័យនៃពួកវិបាកក្ខន្ធផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ១៩៤ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលមិនទៀង ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ១៩៥ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ។

[ ១៩៦ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៩៧ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហ-ជាត គឺពួកខន្ធដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៩៨ ] ធម៌ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធដែលមិនទៀង ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ពួកខន្ធជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធដែលមិនទៀង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធដែលមិនទៀង ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៩៩ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកខន្ធដែលមានសភាពខុស និងទៀង ដោយវិប្បយុត្តប្បច្ច័យ ។

[ ២០០ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ ដែលមានសភាពត្រូវ និងទៀង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលមានសភាពត្រូវ និងទៀង ដោយវិប្បយុត្តប្បច្ច័យ ។

[ ២០១ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលមានសភាពខុស និងទៀង ( ជាបច្ច័យ ) នៃខន្ធ ៣ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ។

[ ២០២ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត

គឺពួកខន្ធ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធដែលមានសភាពខុស និងទៀង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ២០៣ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀងផង ធម៌ដែលមិនទៀងផង ដោយអត្ថិប្បច្ច័យ គឺ ខន្ធ ១ ដែលមានសភាពខុស និងទៀង ( ជាបច្ច័យ ) នៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ខន្ធ ២ ... ។

[ ២០៤ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀង ដោយអត្ថិប្បច្ច័យ មានបញ្ហា ៣ ។

[ ២០៥ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលមិនទៀង ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្ត-សមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ពួកខន្ធជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយអត្ថិប្បច្ច័យ មហាភូត ១ ... មហាភូត ១ របស់ពួកអសញ្ញសត្វ ... ។ បុរេជាត គឺ បុគ្គលឃើញច្បាស់នូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ជាទុក្ខ ជាអនត្តា រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ )

នៃកាយវិញ្ញាណ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធ ដែលមិនទៀង ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលមិនទៀង ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡីការាហារ ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ២០៦ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺរូបជីវិតិន្ទ្រិយជាបច្ច័យនៃមាតុឃាតកម្ម ។បេ។ នៃរុហិរុប្បាទកម្ម ដោយអត្ថិប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដែលមានសភាពខុស និងទៀង ដោយអត្ថិប្បច្ច័យ ។

[ ២០៧ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ ដែលមានសភាពត្រូវ និងទៀង ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកខន្ធ ដែលមានសភាពត្រូវ និងទៀង ដោយអត្ថិប្បច្ច័យ ។

[ ២០៨ ] ធម៌ ដែលមានសភាពខុស និងទៀងក្តី ធម៌ដែលមិនទៀងក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានសភាពខុស និងទៀង ... បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលមានសភាពខុស និងទៀងក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ខន្ធ ២ ក្តី... ។

[ ២០៩ ] ធម៌ ដែលមានសភាពខុស និងទៀងក្តី ធម៌ដែលមិនទៀងក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនទៀង ... បានដល់ សហជាត បច្ឆាជាត

អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកខន្ធដែលមានសភាពខុស និងទៀងក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលមានសភាពខុស និងទៀងក្តី កពឡីការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលមានសភាពខុស និងទៀងក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ២១០ ] ធម៌ ដែលមានសភាពត្រូវ និងទៀងក្តី ធម៌ដែលមិនទៀងក្តី ជាបច្ច័យនៃធម៌ ដែលមានសភាពត្រូវ និងទៀង ដោយអត្ថិប្បច្ច័យ គឺមានបញ្ហា ២ ប្រហែលគ្នានឹងមិច្ឆត្តនិយតធម៌ដែរ ។

[ ២១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៨ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ

មានវារៈ ១៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ២១២ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុសនិងទៀង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២១៣ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ២១៤ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀងផង ធម៌ដែលមិនទៀងផង ដោយសហជាតប្បច្ច័យ ។

[ ២១៥ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ ដែលមានសភាពត្រូវ និងទៀង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២១៦ ] ធម៌ ដែលមានសភាពខុស និងទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។

[ ២១៧ ] ធម៌ ដែលមានសភាពត្រូវ និងទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀងផង ធម៌ដែលមិនទៀងផង ដោយសហជាតប្បច្ច័យ ។

[ ២១៨ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមិនទៀង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ២១៩ ] ធម៌ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពខុស និងទៀង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ២២០ ] ធម៌ ដែលមិនទៀង ជាបច្ច័យនៃធម៌ដែលមានសភាពត្រូវ និងទៀង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ២២១ ] ធម៌ ដែលមានសភាពខុស និងទៀងក្តី ធម៌ដែលមិនទៀងក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានសភាពខុស និងទៀង ... បានដល់ សហជាត និងបុរេជាត ។

[ ២២២ ] ធម៌ ដែលមានសភាពខុស និងទៀងក្តី ធម៌ដែលមិនទៀងក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនទៀង ... បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ២២៣ ] ធម៌ ដែលមានសភាពត្រូវ និងទៀងក្តី ធម៌ដែលមិនទៀងក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានសភាពត្រូវ និងទៀង ... បានដល់ សហជាត

និងបុរេជាត ។

[ ២២៤ ] ធម៌ ដែលមានសភាពត្រូវ និងទៀងក្តី ធម៌ដែលមិនទៀងក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនទៀង ... បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ២២៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងនអារម្មណប្បច្ច័យ នអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ និងនសមនន្តរប្បច្ច័យ មានវារៈ ១៣ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៣ ក្នុងនកម្មប្បច្ច័យ នវិបាកប្បច្ច័យ និងនអាហារប្បច្ច័យ មានវារៈ ១៣ ។ សេចក្តីបង្រួញ ។ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១៣ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយៈ ចប់

[ ២២៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ។បេ។ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ២២៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ...[១] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៨ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុង

១- ច្បាប់ឆដ្ឋសង្គាយនាថា នហេតុបច្ចយា អារម្មណេ បញ្ច ដែលប្រែថា ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះនហេតុប្បច្ច័យ ... ។

កម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

បច្ចនីយានុលោម ចប់

មិច្ឆត្តត្តិកៈទី ១៥ ចប់

# អដ្ឋកថា

## មិច្ឆត្តត្តិកៈ

[ ៩២-២២៧ ] ក្នុងមិច្ឆត្តត្តិកៈ មិច្ឆត្តនិយតធម៌ រមែងមិនជាបច្ច័យដោយបច្ច័យណាមួយដល់សម្មត្តនិយតធម៌ ឯសម្មត្តនិយតធម៌ក៏មិនជាបច្ច័យដោយបច្ច័យណាមួយ ដល់មិច្ឆត្តនិយតធម៌ ។ម្យ៉ាងទៀត មិច្ឆត្តនិយតធម៌ក្តី សម្មត្តនិយតធម៌ក្តី ឈ្មោះថា វៀរសហជាតាធិបតិប្បច្ច័យ រមែងមិនមាន ។ ក្នុងសម្មត្តនិយតធម៌ រមែងមិនមានអារម្មណបុរេជាតប្បច្ច័យដោយពិតប្រាកដ ( គឺសម្មត្តនិយតធម៌ មិនជាអារម្មណបុរេជាតប្បច្ច័យពិតប្រាកដ ) ។ ក្នុងមិច្ឆត្តនិយតធម៌ អាចមានអារម្មណបុរេជាតប្បច្ច័យបាន ។

និយតមិច្ឆាទិដ្ឋិ គប្បីប្រារព្ធអនិយតចិត្តកើតឡើងបាន និយតចិត្ត រមែងមិនប្រារព្ធនិយតចិត្តដ៏សេសកើតឡើង ។ ធម៌ណាមួយ រមែងមិនធ្វើមិច្ឆត្តនិយតធម៌ ឲ្យធ្ងន់កើតឡើង កុសលរមែងមិនជាឧបនិស្សយប្បច្ច័យ ដល់មិច្ឆត្តនិយតធម៌ ។ ពាក្យដ៏សេសក្នុងអធិការនេះ គប្បីជ្រាបតាមន័យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងបាលីនោះឯង ។៚

**អដ្ឋកថាមិច្ឆត្តត្តិកៈ ចប់**

# អភិធម្មបិដក

## មគ្គារម្មណត្តិកៈ

## បដិច្ចវារៈ

[ ២២៨ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គ ជាអារម្មណ៍ ខន្ធ ១ អាស្រ័យនូវខន្ធ ៣ នូវខន្ធ ២ ... ។ ពួកធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។

[ ២២៩ ] ធម៌ ដែលមានមគ្គជាហេតុ អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាហេតុ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គ ជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាហេតុ នូវខន្ធ ២ ... ពួកធម៌ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី

អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាហេតុក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាហេតុ នូវខន្ធ ២ ... ។

[ ២៣០ ] ធម៌ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គ ជាអធិបតិ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាហេតុ អាស្រ័យនូវធម៌ ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាហេតុ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិ នូវខន្ធ ២ ... ។ ពួកធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាហេតុក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិ នូវខន្ធ ២ ... ។

[ ២៣១ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមាន

មគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង មានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង មានមគ្គជាអធិបតិផង ខន្ធ ២ ... ។ ពួកធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង មានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។

[ ២៣២ ] ធម៌ ដែលមានមគ្គជាហេតុ អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាហេតុ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាហេតុផង មានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គ ជាអធិបតិ អាស្រ័យនូវធម៌ ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គ ជាអធិបតិ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាហេតុផង មានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។ ពួកធម៌ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិ

ក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាហេតុក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាហេតុផង មានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។

[ ២៣៣ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

[ ២៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៧ ក្នុងអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

អនុលោម ចប់

[ ២៣៥ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។

[ ២៣៦ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គ ជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គ ជាអារម្មណ៍ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។

[ ២៣៧ ] ធម៌ ដែលមានមគ្គជាហេតុ អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមានមគ្គជាហេតុ អាស្រ័យនូវខន្ធទាំងឡាយដែលមានមគ្គជាហេតុ ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាហេតុ ។ ធម៌ដែលមានមគ្គជាហេតុក្តី ធម៌ដែលមាន

មគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាហេតុ ។

[ ២៣៨ ] ធម៌ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាអធិបតិ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាហេតុ អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ... ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ដែលមានមគ្គជាហេតុ អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាអធិបតិ ។ ធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ ដែលមានមគ្គជាអធិបតិ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមានមគ្គជាហេតុក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គ

ជាអធិបតិ ។

[ ២៣៩ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង មានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ... ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង មានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ មានមគ្គជាអារម្មណ៍ក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង មានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។

[ ២៤០ ] ធម៌ ដែលមានមគ្គជាហេតុ អាស្រ័យនូវធម៌ ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមានមគ្គជាហេតុ អាស្រ័យនូវខន្ធទាំងឡាយដែលមានមគ្គជាហេតុផង មានមគ្គជាអធិបតិផង ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ... គឺអធិបតិធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យខន្ធទាំងឡាយ

ដែលមានមគ្គជាហេតុផង មានមគ្គជាអធិបតិផង ។ ធម៌ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ... ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ដែលមានមគ្គជាហេតុក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធទាំងឡាយដែលមានមគ្គជាហេតុផង មានមគ្គជាអធិបតិផង ។

[ ២៤១ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ និងនបច្ឆាជាតប្បច្ច័យ គឺបច្ច័យទាំង ២ មានបរិបូណ៌រូបហើយ ។

[ ២៤២ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ មានមគ្គជាអធិបតិ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ មានមគ្គជាអារម្មណ៍ក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ នូវខន្ធ ២ ... ។

[ ២៤៣ ] ធម៌ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ ដែលមានមគ្គជាអធិបតិ ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែល

មានមគ្គជាអធិបតិនូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិ នូវខន្ធ ២ ... ។ ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គ ជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអធិបតិនូវខន្ធ ២ ... ។

[ ២៨៤ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ មានមគ្គជាអារម្មណ៍ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ មានមគ្គជាអធិបតិ អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង នូវខន្ធ ២ ... ។ ធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ខន្ធ ២ ... ។

[ ២៨៥ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាមានមគ្គជាអារម្មណ៍ អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាអារម្មណ៍ ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធទាំងឡាយដែលមានមគ្គជាអារម្មណ៍ ។ ធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ ដែលមានមគ្គជាអារម្មណ៍ ... ព្រោះនកម្មប្បច្ច័យ គឺចេតនា ដែលមានមគ្គជាអារម្មណ៍ក្តី ... មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាអារម្មណ៍ ។

[ ២៨៦ ] ធម៌ ដែលមានមគ្គជាហេតុ អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាមានមគ្គជាហេតុ អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាហេតុ ។ ធម៌ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុ ... ព្រោះនកម្មប្បច្ច័យ គឺចេតនាមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាហេតុ ។ ធម៌ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុ ... ព្រោះនកម្មប្បច្ច័យ គឺចេតនាមានមគ្គជាហេតុក្តី មានមគ្គជាអធិបតិក្តី អាស្រ័យនូវខន្ធទាំងឡាយ ដែលមានមគ្គជាហេតុ ។

[ ២៨៧ ] ធម៌ ដែលមានមគ្គជាអធិបតិ អាស្រ័យនូវធម៌ដែលមានមគ្គជាអធិបតិ ... ព្រោះនកម្មប្បច្ច័យ គឺចេតនាមានមគ្គជាអធិបតិ អាស្រ័យនូវខន្ធ

ទាំងឡាយ ដែលមានមគ្គជាអធិបតិ មានបញ្ហា ៥ ។

[ ២៤៨ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ... ព្រោះនកម្មប្បច្ច័យ ។ ក្នុងបឋមឃដនៈ ( តំណាទី ១ ) មានវារៈ ៣ ។

[ ២៤៩ ] ធម៌ ដែលមានមគ្គជាហេតុ អាស្រ័យនូវធម៌ដែលមានមគ្គជាហេតុផង ធម៌មានមគ្គជាអធិបតិផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ ។ ក្នុងទុតិយឃដនៈ ( តំណាទី ២ ) មានបញ្ហា ៣ ។

[ ២៥០ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ បរិបូណ៌ ។

[ ២៥១ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ដែលមានមគ្គជាអារម្មណ៍ ខន្ធ ២ ... ។

[ ២៥២ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ អាស្រ័យនូវធម៌ដែលមានមគ្គជាអារម្មណ៍ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ បរិបូណ៌ហើយ ។ ពាក្យថា អរូប បណ្ឌិតគប្បីកំណត់យ៉ាងនេះផងចុះ ។

[ ២៥៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ១៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុង

នវិប្បយុត្តប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

បច្ចនីយៈ ចប់

[ ២៥៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ និងនកម្មប្បច្ច័យ មានវារៈ ៩ ក្នុងនវិបាកប្បច្ច័យ និងនវិប្បយុត្តប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

អនុលោមប្បច្ចនីយៈ ចប់

[ ២៥៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ មានវារៈ ១ ដូចគ្នា ។ ក្នុងឈានប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

បច្ចនីយានុលោម ចប់

បដិច្ចវារៈ ចប់

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បញ្ហាវារៈ

[ ២៥៦ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គ

ជាអារម្មណ៍ ដោយហេតុប្បច្ច័យ គឺហេតុទាំងឡាយ មានមគ្គជាអារម្មណ៍ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយហេតុប្បច្ច័យ ។បេ។

[ ២៥៧ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអធិបតិ ដោយហេតុប្បច្ច័យ គឺហេតុទាំងឡាយ មានមគ្គជាអារម្មណ៍ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដែលមានមគ្គជាអធិបតិ ដោយហេតុប្បច្ច័យ ។

[ ២៥៨ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយហេតុប្បច្ច័យ ។បេ។ បញ្ហា ១៧ បណ្ឌិតគប្បីធ្វើដោយហេតុនេះចុះ ។

[ ២៥៩ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយចិត្ត មានមគ្គជាហេតុ ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយ មានមគ្គជាហេតុ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ នូវបុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ២៦០ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអធិបតិ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ២៦១ ] ធម៌ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ ដែលមានមគ្គ

ជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ២៦២ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ២៦៣ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈចេញអំពីមគ្គ ពិចារណានូវមគ្គ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយចិត្ត ដែលមានមគ្គជាអធិបតិ ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ នូវបុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ២៦៤ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ២៦៥ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអារម្មណ៍ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយចិត្ត ដែលមានមគ្គជាហេតុ និងដែលមានមគ្គជាអធិបតិ ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយ ដែលមានមគ្គជាហេតុក្តី ដែលមានមគ្គជា

អធិបតិក្តី ជាបច្ច័យនៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសា-នុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ២៦៦ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ២៦៧ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ២៦៨ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិ-ធម៌ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិ-បតិប្បច្ច័យ ។

[ ២៦៩ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាអធិបតិ ដោយអធិបតិប្បច្ច័យ ។

[ ២៧០ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ បាន

ដល់ សហជាតាធិបតិ គឺអធិបតិធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ ។

[ ២៧១ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ២៧២ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកព្រះអរិយៈចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ២៧៣ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតា-ធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាអធិបតិ ដោយអធិបតិប្បច្ច័យ ។

[ ២៧៤ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ២៧៥ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាហេតុផង ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ ។

[ ២៧៦ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ។បេ។ ហើយពិចារណា ។ ឯសហជាតាធិបតិ គឺធម៌ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ២៧៧ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈចេញអំពីមគ្គ ។បេ។ ហើយពិចារណា ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធដែលមានមគ្គជាអារម្មណ៍ ដោយអធិបតិប្បច្ច័យ ។

[ ២៧៨ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ ដែលមានមគ្គជាហេតុ ដោយអធិបតិប្បច្ច័យ ។

[ ២៧៩ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ។បេ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាអារម្មណ៍ផង មានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ ។

[ ២៨០ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃពួកសម្ប-យុត្តកក្ខន្ធ ដែលមានមគ្គជាហេតុផង ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ ។

[ ២៨១ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាអារម្មណ៍ ដោយអធិបតិប្បច្ច័យ ។

[ ២៨២ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជា

អធិបតិក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាអធិបតិ ដោយអធិបតិប្បច្ច័យ ។

[ ២៨៣ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គ ជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ ។

[ ២៨៤ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអារម្មណ៍ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គ ឲ្យជាទីគោរព ហើយពិចារណា ។

[ ២៨៥ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ ដែលមានមគ្គជាហេតុក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាហេតុ ដោយអធិបតិប្បច្ច័យ ។

[ ២៨៦ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ បានដល់ អារម្មណាធិបតិ និងសហ-

ជាតាធិបតិ ។ ដោយអធិបតិប្បច្ច័យ អារម្មណាធិបតិ គឺពួកព្រះអរិយៈចេញ អំពីមគ្គ ។បេ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ដែលមានមគ្គជាហេតុក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាអធិបតិ ដោយអធិបតិប្បច្ច័យ ។

[ ២៨៧ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ( ចេញ ) អំពីមគ្គ ។បេ។ ហើយពិចារណា ។

[ ២៨៨ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ដែលមានមគ្គជាហេតុក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដែលមានមគ្គជាហេតុផង ដែលមានមគ្គជាធិបតិផង ដោយអធិបតិប្បច្ច័យ ។

[ ២៨៩ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអារម្មណ៍ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃពួកខន្ធដែលមានមគ្គជាអារម្មណ៍ ដោយអនន្តរប្បច្ច័យ ។

[ ២៩០ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអារម្មណ៍

ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអធិបតិ ដោយអនន្តរប្បច្ច័យ អាវជ្ជនា ជាបច្ច័យនៃពួកខន្ធដែលមានមគ្គជាអធិបតិ ដោយអនន្តរប្បច្ច័យ ។

[ ២៩១ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយអនន្តរប្បច្ច័យ អាវជ្ជនា ជាបច្ច័យនៃពួកខន្ធ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយអនន្តរប្បច្ច័យ ។

[ ២៩២ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអធិបតិ ដោយអនន្តរប្បច្ច័យ ។

[ ២៩៣ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអារម្មណ៍ ដោយអនន្តរប្បច្ច័យ ។

[ ២៩៤ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយអនន្តរប្បច្ច័យ ។

[ ២៩៥ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិ

ក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអារម្មណ៍ ដោយអនន្តរប្បច្ច័យ ។

[ ២៩៦ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអធិបតិ ដោយអនន្តរប្បច្ច័យ ។

[ ២៩៧ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអារម្មណ៍ក្តី ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយអនន្តរប្បច្ច័យ ។

[ ២៩៨ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយសមនន្តរប្បច្ច័យ គឺបទទាំងអស់ ប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ បញ្ហាទាំង ១៧ បណ្ឌិតត្រូវធ្វើឲ្យដូចគ្នា ក្នុងបទទាំងបីផងចុះ ។

[ ២៩៩ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបក-

តូបនិស្ស័យ ។ បកតូបនិស្ស័យ គឺការពិចារណា ជាបច្ច័យនៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០០ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺការពិចារណា ( ជាបច្ច័យ ) នៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០១ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺការពិចារណា ជាបច្ច័យនៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០២ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺមគ្គទី ១ ជាបច្ច័យនៃមគ្គទី ២ ដោយឧបនិស្សយប្បច្ច័យ ។ សេចក្តីបង្រួញ ។ មគ្គទី ៣ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០៣ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ គឺព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ៣០៤ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូ-

បនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺមគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ២ មគ្គទី ៣ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០៥ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ គឺព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ៣០៦ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺមគ្គទី ១ ជាបច្ច័យនៃមគ្គទី ២ ។បេ។ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០៧ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺមគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ២ មគ្គទី ៣ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ការពិចារណា ជាបច្ច័យនៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០៨ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺការពិចារណា ជា

បច្ច័យនៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០៩ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺមគ្គទី ១ ។បេ។ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣១០ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង មានមគ្គជាអធិបតិផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺការពិចារណា ជាបច្ច័យនៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣១១ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺមគ្គទី ១ ។បេ។ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣១២ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺការពិចារណា ជាបច្ច័យនៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣១៣ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺការពិចារណា

ជាបច្ច័យនៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣១៤ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺការពិចារណា ជាបច្ច័យនៃការពិចារណា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣១៥ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ គឺព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ៣១៦ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺមគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ២ មគ្គទី ៣ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣១៧ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអធិបតិ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺមគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ២ មគ្គទី ៣ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣១៨ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយឧបនិស្សយបច្ច័យ បានដល់ អារម្មណូបនិស្ស័យ គឺព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ។

[ ៣១៩ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយឧបនិស្សយបច្ច័យ បានដល់ បកតូបនិស្ស័យ គឺមគ្គទី ១ ( ជាបច្ច័យ ) នៃមគ្គទី ២ មគ្គទី ៣ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយបច្ច័យ ។

[ ៣២០ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអាសេវនបច្ច័យ គឺពួកខន្ធមុនៗ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមានមគ្គជាអារម្មណ៍ ដោយអាសេវនបច្ច័យ ។

[ ៣២១ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអាសេវនបច្ច័យ គឺបញ្ហា ៩ បណ្ឌិតត្រូវធ្វើឲ្យប្រហែលគ្នានឹងអនន្តរបច្ច័យចុះ ។ ការពិចារណា បណ្ឌិតមិនត្រូវធ្វើឡើយ ។

[ ៣២២ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយកម្មបច្ច័យ ជាបច្ច័យដោយសហជាតបច្ច័យ គឺនានាខណិកៈ មិនមានទេ ឯបញ្ហា ១៧ បណ្ឌិតត្រូវធ្វើផងចុះ ។ ធម៌ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអារម្មណ៍ ដោយ

អាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យដោយអត្ថិប្បច្ច័យ ។ បច្ច័យទាំង ៧ នេះ មានបញ្ហា ១៧ ប្រហែលគ្នានឹងហេតុប្បច្ច័យដែរ ។ ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ គឺប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។ ជាបច្ច័យដោយវិគតប្បច្ច័យ គឺមានបញ្ហា ១៧ ។

[ ៣២៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ១៧ ក្នុងអាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យនិងសម្បយុត្តប្បច្ច័យ មានវារៈ ១៧ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### អនុលោម ចប់

[ ៣២៤ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣២៥ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣២៦ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣២៧ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣២៨ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣២៩ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣០ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣១ ] ធម៌ ដែលមានមគ្គជាហេតុ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣២ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជា

អធិបតិ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣៣ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣៤ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣៥ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣៦ ] ធម៌ ដែលមានមគ្គជាអធិបតិ ជាបច្ច័យនៃធម៌ដែលមានមគ្គជាហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣៧ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣៨ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអធិបតិ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៣៩ ] ធម៌ ដែលមានមគ្គជាអារម្មណ៍ក្តី ធម៌ដែលមានមគ្គជាអធិបតិ

ក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨០ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអារម្មណ៍ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨១ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨២ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គជាអធិបតិ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨៣ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ ដែលមានមគ្គជាអារម្មណ៍ផង ដែលមានមគ្គជាអធិបតិផង ដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨៤ ] ធម៌ ដែលមានមគ្គជាហេតុក្តី ធម៌ដែលមានមគ្គជាអធិបតិក្តី ជាបច្ច័យនៃធម៌ដែលមានមគ្គហេតុផង ធម៌ដែលមានមគ្គជាអធិបតិផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៧ កាលបើនអារម្មណប្បច្ច័យ លោកសង្គ្រោះយកហើយ អា-

រម្មណ៍ទាំងពីរ គឺបកតារម្មណ៍ក្តី ឧបនិស្សយារម្មណ៍ក្តី រមែងដាច់ចេញពីគ្នា ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២១ ក្នុងនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នសហជាតប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ ននិស្សយប្បច្ច័យ នឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ នវិបាកប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ នសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោអត្ថិប្បច្ច័យ នោនត្ថិប្បច្ច័យ នោវិគតប្បច្ច័យ និងនោអវិគតប្បច្ច័យ មានវារៈ ២១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៣៤៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ នវិបាកប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមបច្ចនីយៈ ចប់

[ ៣៤៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ២១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុង

សមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ១៧ ក្នុងអាហារប្បច្ច័យ មានវារៈ ១៧ ក្នុងឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ និងសម្បយុត្តប្បច្ច័យ មានវារៈ ១៧ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បញ្ហាវារៈ ចប់

មគ្គារម្មណត្តិកៈទី ១៦ ចប់

# អដ្ឋកថា

## មគ្គារម្មណត្តិកៈ

[ ២២៨-៣៤៧ ] ក្នុងមគ្គារម្មណត្តិកៈ ក្នុងអនុលោមនៃបដិច្ចវារៈ មិនមានវិបាកប្បច្ច័យ សូម្បីក្នុងកម្មប្បច្ច័យ ( នៃបញ្ហាវារៈ ) ក្នុងតិកៈនេះ ក៏មិនបាននានាខណិកកម្មប្បច្ច័យ ។៚

## អដ្ឋកថាមគ្គារម្មណត្តិកៈ ចប់

# អភិធម្មបិដក

## ឧប្បន្នត្តិកៈ

## បញ្ហាវារៈ

[ ៣៤៨ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលកើតឡើងហើយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ពួកហេតុដែលកើតឡើងហើយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តា-រូបផង ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ ។

[ ៣៤៩ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឃើញច្បាស់នូវចក្ខុ ដែលកើតឡើងហើយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ក៏ត្រេកអរ រីករាយ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆា ... ឧទ្ធច្ចៈ ... ទោមនស្ស ... នូវត្រចៀក ដែលកើតឡើងហើយ ... នូវច្រមុះ អណ្តាត កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... ឃើញច្បាស់នូវពួកខន្ធដែលកើតឡើងហើយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញច្បាស់នូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វ-សោតធាតុ ពួកខន្ធដែលកើតឡើងហើយ ជាបច្ច័យនៃការពិចារណា នូវឥទ្ធិវិធញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៣៥០ ] ធម៌ ដែលមិនទាន់កើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើត

ឡើងហើយ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឃើញច្បាស់នូវពួករូប ដែលមិនទាន់កើតឡើងហើយ ... នូវពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... នូវពួកខន្ធ ដែលមិនទាន់កើតឡើងហើយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។បេ។ ទោមនស្សកើតឡើង ពួកខន្ធដែលមិនទាន់កើតឡើងហើយ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៣៥១ ] ធម៌ ដែលកំពុងកើតឡើង ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអារម្មណប្បច្ច័យ គឺបុគ្គល ( ឃើញច្បាស់ ) នូវចក្ខុដែលកំពុងកើតឡើង ... នូវកាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... នូវពួកខន្ធ ដែលកំពុងកើតឡើង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។បេ។ ទោមនស្សកើតឡើង ពួកខន្ធដែលកំពុងកើតឡើង ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ។បេ។ ដោយអារម្មណប្បច្ច័យ ។

[ ៣៥២ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវចក្ខុដែលកើតឡើងហើយ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ធ្វើនូវចក្ខុនោះឲ្យជាទីគោរព ។បេ។ ទិដ្ឋិកើតឡើង នូវត្រចៀក ដែលកើតឡើងហើយ ... ច្រមុះ អណ្តាត កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... បុគ្គលធ្វើនូវពួកខន្ធដែលកើតឡើងហើយ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ធ្វើនូវ

ពួកខន្ធនោះ ដែលកើតឡើងហើយ ឲ្យជាទីគោរព ទើបកើតឡើង ។បេ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃពួកសម្បយុត្តកធម៌ផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៣៥៣ ] ធម៌ ដែលមិនទាន់កើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គល ( ធ្វើ ) នូវពួករូបដែលមិនទាន់កើតឡើងហើយ ... នូវពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... បុគ្គលធ្វើនូវពួកខន្ធ ដែលមិនទាន់កើតឡើងហើយ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ធ្វើនូវពួកខន្ធនោះ ដែលមិនទាន់កើតឡើងហើយ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៣៥៤ ] ធម៌ ដែលកំពុងកើតឡើង ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវចក្ខុដែលកំពុងកើតឡើង ... នូវកាយ ពួករូប ... នូវពួកផោដ្ឋព្វៈ វត្ថុ ... ធ្វើនូវពួកខន្ធ ដែលកំពុងកើតឡើង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៣៥៥ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលកើតឡើងហើយ ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ខន្ធ ១ ដែលមិនទាន់កើតឡើង ជាបច្ច័យនៃខន្ធ ៣ ផង ពួកកដត្តារូបផង ក្នុង

ខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង ពួកកដត្តារូបផង ដោយសហជាតប្បច្ច័យ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយសហជាតប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយសហជាតប្បច្ច័យ មហាភូត ១ ជាបច្ច័យនៃមហាភូត ៣ ដោយសហជាតប្បច្ច័យ មហាភូត ២ ... ពួកមហាភូត ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប និងពួកឧបាទារូប ដោយសហជាតប្បច្ច័យ ពាហិរ ... អាហារ ... រដូវ ... មហាភូត ១ របស់ពួកអសញ្ញសត្វ ... មហាភូត ២ ... ពួកមហាភូត ជាបច្ច័យនៃពួកកដត្តារូប និងពួកឧបាទារូប ដោយសហជាតប្បច្ច័យ ។

[ ៣៥៦ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលកើតឡើងហើយ ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ដែលកើតឡើងហើយ ជាបច្ច័យនៃខន្ធ ៣ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ... ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយអញ្ញមញ្ញប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូត ១ ... ពាហិរ ... អាហារ ... រដូវ ... មហាភូត ១ របស់ពួកអសញ្ញសត្វ ជាបច្ច័យនៃមហាភូត ៣ ដោយអញ្ញមញ្ញប្បច្ច័យ មហាភូត ២ ... ។

[ ៣៥៧ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលកើតឡើងហើយ ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយនិស្សយប្បច្ច័យ ខន្ធ ២ ... ពួក

ខន្ធ ( ជាបច្ច័យ ) នៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ វត្ថុ ( ជាបច្ច័យ ) នៃពួកខន្ធ មហាភូត ១ ... ពាហិរៈ ... អាហារ ... រដូវ ... មហាភូត ១ របស់ពួកអសញ្ញសត្វ ... ពួកមហាភូត ( ជាបច្ច័យ ) នៃពួកកដត្តារូប និង ឧបាទារូប ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធ ដែលកើតឡើង ហើយ ដោយនិស្សយប្បច្ច័យ ។

[ ៣៥៨ ] ធម៌ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើង ហើយ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូ-បនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរដូវ ដែលកើតឡើងហើយ ញ៉ាំងឈានឲ្យកើតឡើង ញ៉ាំងវិបស្សនា ... ញ៉ាំង មគ្គ ... ញ៉ាំងអភិញ្ញា ... ញ៉ាំងសមាបត្តិ ... ដំឡើងមានះ ប្រកាន់ទិដ្ឋិ នូវភោជន ដែលកើតឡើងហើយ ... អាស្រ័យនូវសេនាសនៈ ហើយញ៉ាំងឈានឲ្យកើត ឡើង ញ៉ាំងវិបស្សនា ... ញ៉ាំងមគ្គ ... ញ៉ាំងអភិញ្ញា ... ញ៉ាំងសមាបត្តិ ... ដំឡើងមានះ ប្រកាន់ទិដ្ឋិ នូវរដូវដែលកើតឡើងហើយ ... ភោជន ... សេនា-សនៈ ជាបច្ច័យនៃសទ្ធា ដែលកើតឡើងហើយ នៃបញ្ញា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣៥៩ ] ធម៌ ដែលមិនទាន់កើតឡើងហើយ ជាបច្ច័យនៃធម៌ដែល កើតឡើងហើយ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលកាលប្រាថ្នា

នូវវណ្ណសម្បទា ដែលមិនទាន់កើតឡើងហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម នូវសទ្ទសម្បទា ដែលមិនទាន់កើតឡើង ... នូវគន្ធសម្បទា រសសម្បទា ផោដ្ឋព្វសម្បទា ... កាលប្រាថ្នានូវពួកខន្ធ ដែលមិនទាន់កើតឡើងហើយ ទាន ... សីល ... ឧបោសថកម្ម ... វណ្ណសម្បទា ដែលមិនទាន់កើតឡើងហើយ ... ពួកខន្ធដែលមិនទាន់កើតឡើងហើយ ជាបច្ច័យនៃសទ្ធា ដែលកើតឡើងហើយ នៃបញ្ញា កាយិកសុខ កាយិកទុក្ខ មគ្គនិងផល-សមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣៦០ ] ធម៌ ដែលកំពុងកើតឡើង ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូ-បនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលកាលប្រាថ្នានូវចក្ខុសម្បទា ដែលកំពុងកើតឡើង ទាន ... សីល ... ឧបោសថកម្ម ... នូវសោតសម្បទា ដែលកំពុងកើតឡើង ... នូវកាយសម្បទា វណ្ណសម្បទា គន្ធសម្បទា ... នូវរសសម្បទា ... នូវផោដ្ឋព្វសម្បទា ... កាលប្រាថ្នានូវពួកខន្ធដែលកំពុងកើតឡើង ទាន ... សីល ... ឧបោសថកម្ម ... ចក្ខុសម្បទាដែលកំពុងកើតឡើង ... កាយសម្បទា វណ្ណសម្បទា ។បេ។ ផោដ្ឋព្វសម្បទា ... ពួកខន្ធ ដែលកំពុងកើតឡើង ជាបច្ច័យនៃសទ្ធា ដែលកើតឡើងហើយ នៃបញ្ញា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្ស-យប្បច្ច័យ ។

[ ៣៦១ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើង

ហើយ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សកើតឡើង នូវរូប ដោយទិព្វចក្ខុ ... ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ។បេ។ វត្ថុជាបច្ច័យនៃពួកខន្ធដែលកើតឡើងហើយ ដោយបុរេជាតប្បច្ច័យ ។

[ ៣៦២ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធដែលកើតឡើងហើយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣៦៣ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយកម្មប្បច្ច័យ គឺចេតនា ដែលកើតឡើងហើយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ គឺចេតនាដែលកើតឡើងហើយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។

[ ៣៦៤ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយវិបាកប្បច្ច័យ គឺខន្ធ ១ ដែលកើតឡើងហើយ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ ខន្ធ

២ ... ខន្ធ ១ ដែលកើតឡើងហើយ ជាបច្ច័យនៃខន្ធ ៣ ផង ពួកកដត្តារូប ផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ... ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ។

[ ៣៦៥ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអាហារប្បច្ច័យ គឺពួកអាហារដែលកើតឡើងហើយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ក្នុងខណៈនៃបដិសន្ធិ ដោយអាហារប្បច្ច័យ ។

[ ៣៦៦ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយដែលកើតឡើងហើយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយិន្ទ្រិយ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៦៧ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលកើតឡើងហើយ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធដែលកើតឡើង

ហើយ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុជាបច្ច័យនៃពួកខន្ធដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ... វត្ថុ ជាបច្ច័យនៃពួកខន្ធ ដែលកើតឡើងហើយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯ បច្ឆាជាត គឺពួកខន្ធ ដែលកើតឡើងហើយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៦៨ ] ធម៌ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលកើតឡើងហើយ ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបង្រួញ ។ មហាភូត ១ ... ពាហិរ ... អាហារ ... ឧតុ ... របស់ពួកអសញ្ញសត្វ ... ។ បុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ជាមិនទៀង ជាទុក្ខ ... នូវវត្ថុ ជាមិនទៀង ... ទោមនស្សកើតឡើង ( បុគ្គល ) ដោយទិព្វចក្ខុ ... ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដែលកើតឡើងហើយ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលកើតឡើងហើយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ( ជាបច្ច័យ )

នៃកាយនេះ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៣៦៩ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអវិគតប្បច្ច័យ ។

[ ៣៧០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ឆាជាតប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៣៧១ ] ធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៧២ ] ធម៌ ដែលមិនទាន់កើតឡើងហើយ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៧៣ ] ធម៌ ដែលកំពុងកើតឡើង ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៧៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៣៧៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ក្នុងនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ១ ។

## អនុលោមបច្ចនីយៈ ចប់

[ ៣៧៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ១ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ១ ។

បច្ចនីយានុលោម ចប់

បញ្ហាវារៈ ចប់

ឧប្បន្នត្តិកៈទី ១៧ ចប់

# អតីតត្តិកៈ

## បញ្ហាវារៈ

[ ៣៧៧ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយហេតុប្បច្ច័យ គឺ បច្ចុប្បន្នហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៧៨ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យទាន សីល ... ឧបោសថកម្ម ... ហើយពិចារណា ពិចារណានូវកុសលទាំងឡាយ ដែលធ្លាប់សន្សំល្អហើយក្នុងកាលមុន ចេញអំពីឈានហើយ ពិចារណានូវឈាន ព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គហើយ ពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវពួកកិលេសដែលលះបង់ហើយ ពិចារណានូវកិលេស ដែលសង្កត់សង្កិនហើយ ឃើញច្បាស់នូវអតីតចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។បេ។ ទោមនស្ស កើតឡើង នូវត្រចៀក ដែលកន្លងហើយ ... នូវច្រមុះ អណ្តាត កាយ ពួករូប ពួកសំឡេង ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... ឃើញច្បាស់នូវអតីតក្ខន្ធទាំងឡាយ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ រាគៈប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆា ... ឧទ្ធច្ចៈ ... ទោមនស្ស កើតឡើង អាកាសានញ្ចាយតនៈ ជាបច្ច័យនៃវិញ្ញាណញ្ចាយតនៈ ដោយអារម្មណប្បច្ច័យ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយអារម្មណប្បច្ច័យ អតីតក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវ

ឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងយថា-កម្មុបគញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៣៧៩ ] អនាគតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) នូវអនាគតចក្ខុ ... នូវវត្ថុ ... នូវអនាគតក្ខន្ធទាំងឡាយ ថាមិនទៀង ... ទោមនស្សកើតឡើង អនាគតក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៣៨០ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) នូវបច្ចុប្បន្នចក្ខុ ... កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... នូវបច្ចុប្បន្នក្ខន្ធទាំងឡាយ ថាមិនទៀង ... ទោមនស្សកើតឡើង ដោយទិព្វចក្ខុ ... ឮនូវសំឡេង ដោយទិព្វសោធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយ-វិញ្ញាណ បច្ចុប្បន្នក្ខន្ធទាំងឡាយ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៣៨១ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ ( បុគ្គល ) ឲ្យទាន នូវសីល ។បេ។ ធ្វើនូវកុសលទាំងឡាយ ដែលសន្សំល្អហើយក្នុងកាលមុន ឲ្យជាទីគោរព ហើយពិចារណា ចេញអំពីឈាន ធ្វើនូវឈានឲ្យជាទីគោរព ហើយពិចារណាព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរពហើយ ពិចារណា

ធ្វើនូវផលឲ្យជាទីគោរព ហើយពិចារណា នូវអតីតចក្ខុ ... នូវកាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... ( បុគ្គល ) ធ្វើនូវអតីតក្ខន្ធទាំងឡាយ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៣៨២ ] អនាគតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ ( បុគ្គល ) នូវអនាគតចក្ខុ ... នូវវត្ថុ ... ធ្វើនូវអនាគតក្ខន្ធទាំងឡាយ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៣៨៣ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) នូវបច្ចុប្បន្នចក្ខុ ... នូវវត្ថុ ... ធ្វើនូវបច្ចុប្បន្នក្ខន្ធទាំងឡាយ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺបច្ចុប្បន្នាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៣៨៤ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអនន្តរប្បច្ច័យ គឺ អតីតក្ខន្ធមុនៗ ជាបច្ច័យនៃពួកបច្ចុប្បន្នក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ( ជាបច្ច័យ ) នៃមគ្គ មគ្គ ( ជាបច្ច័យ ) នៃផល ផល ( ជាបច្ច័យ ) នៃផល អនុលោម

( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ៣៨៥ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយសមនន្តរប្បច្ច័យ គឺប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។

[ ៣៨៦ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ ។ សេចក្តីបំប្រួញ ។

[ ៣៨៧ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ។បេ។ បុគ្គលអាស្រ័យនូវសំឡេងដែលកន្លងហើយឲ្យទាន សីល ... ធ្វើឧបោសថកម្ម ញុំាងឈាន ។បេ។ ញុំាងវិបស្សនា ... ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ឲ្យកើតឡើង ជំឡើងមានះ ប្រកាន់ទិដ្ឋិ អាស្រ័យនូវអតីតសីល ... នូវបញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ ... អាស្រ័យនូវកាយិកទុក្ខ ហើយឲ្យទាន សីល ... ឧបោសថកម្ម ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សម្លាប់សត្វ បំបែកសង្ឃ អតីតសទ្ធា ... បញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ ... កាយិកទុក្ខ ជាបច្ច័យនៃបច្ចុប្បន្នបញ្ញា រាគៈ សេចក្តីប្រាថ្នា ។បេ។ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨៨ ] អនាគតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បក-

តូបនិស្ស័យ គឺបុគ្គលកាលប្រាថ្នានូវចក្ខុសម្បទាជាអនាគត នូវសោតសម្បទា ... នូវឃានសម្បទា ជិវ្ហាសម្បទា កាយសម្បទា វណ្ណសម្បទា សទ្ទសម្បទា គន្ធសម្បទា រសសម្បទា ... កាលប្រាថ្នានូវផោដ្ឋព្វសម្បទា កាលប្រាថ្នានូវអនាគតក្ខន្ធទាំងឡាយ ឲ្យទាន សីល ... ឧបោសថកម្ម ... ចក្ខុសម្បទា ជាអនាគត ... វណ្ណសម្បទា ... ផោដ្ឋព្វសម្បទា ... អនាគតក្ខន្ធទាំងឡាយ ជាបច្ច័យនៃសទ្ធាជាបច្ចុប្បន្ន នៃបញ្ញា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨៩ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរដូវ ជាបច្ចុប្បន្ន ហើយញ៉ាំងឈានឲ្យកើតឡើង ញ៉ាំងវិបស្សនា ។បេ។ នូវភោជន ជាបច្ចុប្បន្ន ... បុគ្គលអាស្រ័យនូវសេនាសនៈ ហើយញ៉ាំងឈាន ឲ្យកើតឡើង ញ៉ាំងសមាបត្តិឲ្យកើតឡើង រដូវជាបច្ចុប្បន្ន ... ភោជន ... សេនាសនៈ ជាបច្ច័យនៃសទ្ធាជាបច្ចុប្បន្នបញ្ញា កាយិកៈ ។បេ។ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣៩០ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញនូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ... ទោមនស្សកើតឡើង ឃើញនូវរូបដោយទិព្វចក្ខុ ដោយទិព្វសោតធាតុ ... រូបាយតនៈ ( ជាបច្ច័យ ) នៃ

ចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធ ជាបច្ចុប្បន្ន ដោយបុរេជាតប្បច្ច័យ ។

[ ៣៩១ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធជាបច្ចុប្បន្ន ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣៩២ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអាសេវនប្បច្ច័យ គឺពួកអតីតក្ខន្ធមុនៗ ជាបច្ច័យនៃពួកបច្ចុប្បន្នក្ខន្ធក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៣៩៣ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺអតីតចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធជាបច្ចុប្បន្នផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៩៤ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយកម្មប្បច្ច័យ គឺបច្ចុប្បន្នចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ បច្ចុប្បន្នចេតនា ជាបច្ច័យនៃសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។

[ ៣៩៥ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ជាបច្ចុប្បន្ន ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូប ផង ដោយវិបាកប្បច្ច័យ ខន្ធ ២ ... ពួកខន្ធជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃ បដិសន្ធិ ដោយវិបាកប្បច្ច័យ ។

[ ៣៩៦ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យ ដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យដោយវិប្ប-យុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺ ពួកបច្ចុប្បន្នក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ពួក បច្ចុប្បន្នក្ខន្ធ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្ប-យុត្តប្បច្ច័យ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃ ពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ... វត្ថុជាបច្ច័យនៃពួកបច្ចុប្បន្នក្ខន្ធ ដោយវិប្ប-យុត្តប្បច្ច័យ ។ បច្ឆាជាត គឺពួកបច្ចុប្បន្នក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែល កើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៩៧ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអត្ថិប្បច្ច័យ មានវារៈប្រហែលគ្នានឹងអត្ថិប្បច្ច័យ ក្នុងឧប្បន្នត្តិកៈដែរ ។

[ ៣៩៨ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយនត្ថិប្បច្ច័យ ជា បច្ច័យដោយវិគតប្បច្ច័យ ។

[ ៣៩៩ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអវិគតប្បច្ច័យ ។បេ។

[ ៤០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ និងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ និងអាហារប្បច្ច័យ មានវារៈ ១ ។ សេចក្តីបង្រួញ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

អនុលោម ចប់

[ ៤០១ ] អតីតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤០២ ] អនាគតធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៤០៣ ] បច្ចុប្បន្នធម៌ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៤០៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ។ សេចក្ដីបង្រួញ ។ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

## បច្ចនីយៈ ចប់

[ ៤០៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ ( មានវារៈ ១ ) ។ សេចក្ដីបង្រួញ ។ ក្នុងនសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

## អនុលោមបច្ចនីយៈ ចប់

[ ៤០៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ឆាជាតប្បច្ច័យ និងអាសេវនប្បច្ច័យ មានវារៈ ១ ។ សេចក្ដីបង្រួញ ។

ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងបទទាំងអស់នេះ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

បច្ចនីយានុលោម ចប់

បញ្ហាវារៈ ចប់

អតីតត្តិកៈទី ១៨ ចប់

# អដ្ឋកថា

## ឧប្បន្នត្តិកៈ និងអតីតត្តិកៈ

[ ៣៩៨-៤០៦ ] ក្នុងឧប្បន្នត្តិកៈ និងអតីតត្តិកៈ មិនមានបដិច្ចវារៈជាដើម មានតែបញ្ហាវារៈប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ព្រោះបដិច្ចវារៈជាដើម មានចំពោះតែសហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យប៉ុណ្ណោះ ។ម្យ៉ាងទៀត តិកៈទាំងនេះ មានធម៌ទាំងដែលជាអតីត និងអនាគតលាយឡំគ្នា បច្ច័យទាំងឡាយ ដែលជាពួកនៃអនន្តរប្បច្ច័យ រមែងមិនបានក្នុងឧប្បន្នត្តិកៈនេះ ព្រោះហេតុអ្វី ព្រោះក្នុងឧប្បន្នត្តិកៈ មិនមានធម៌ដែលជាអតីត ក្នុងអធិការនេះ ធម៌ ២ គឺធម៌ដែលកើតឡើងហើយ និងធម៌ដែលមិនទាន់កើតឡើង រមែងមិនជាបច្ច័យដោយបច្ច័យណាមួយ ដល់ធម៌ទាំង ២ នេះ គឺធម៌ដែលកើតហើយ និងធម៌ដែលមិនទាន់កើតឡើង ។ ចំណែកធម៌ ២ គឺធម៌ដែលមិនទាន់កើតឡើង និងដែលនឹងកើតឡើង ជាបច្ច័យដល់ធម៌ដែលកើតឡើងហើយដោយបច្ច័យ ២ គឺអារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ពាក្យដ៏សេសក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលមកហើយក្នុងព្រះបាលី ។

ក្នុងអតីតត្តិកៈ ធម៌ដែលជាបច្ចុប្បន្ន រមែងមិនជាបច្ច័យណាមួយ ដល់ធម៌ដែលជាអតីត និងអនាគត ធម៌ដែលជាអតីត និងអនាគត រមែងមិនជាបច្ច័យដោយបច្ច័យណាមួយ ដល់ធម៌ដែលជាអតីត និងអនាគត ឯនិព្វាន

រមែងមិនបានដោយភាពជាបច្ច័យ និងដោយភាពជាបច្ចយុប្បន្នៈ ក្នុងតិកៈទាំងពីរពួកនេះ ។ ពាក្យដ៏សេសក្នុងអធិការនេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងព្រះបាលីនោះឯង ៕

## អដ្ឋកថាឧប្បន្នត្តិកៈ និងអតីតត្តិកៈ ចប់

# អភិធម្មបិដក

## អតីតារម្មណត្តិកៈ

## បដិច្ចវារៈ

[ ៤០៧ ] អតីតារម្មណធម៌ ( ធម៌ដែលមានអារម្មណ៍កន្លងទៅហើយ ) អាស្រ័យនូវអតីតារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអតីតារម្មណ៍ ខន្ធ ២ អាស្រ័យនូវខន្ធ ២ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអតីតារម្មណ៍ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវខន្ធ ២ ។

[ ៤០៨ ] អនាគតារម្មណធម៌ ( ធម៌ដែលមានអារម្មណ៍មិនទាន់មានមក ) អាស្រ័យនូវអនាគតារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអនាគតារម្មណ៍ នូវខន្ធ ២ ... ។

[ ៤០៩ ] បច្ចុប្បន្នារម្មណធម៌ អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាបច្ចុប្បន្នារម្មណ៍ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាបច្ចុប្បន្នារម្មណ៍ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

[ ៤១០ ] អតីតារម្មណធម៌ អាស្រ័យនូវអតីតារម្មណធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ និងអធិបតិប្បច្ច័យ គឺបដិសន្ធិ មិនមានក្នុងអធិបតិប្បច្ច័យទេ ។ ព្រោះអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ និង

អាសេវនប្បច្ច័យ គឺក្នុងបុរេជាតប្បច្ច័យ និងអាសេវនប្បច្ច័យ មិនមានបដិសន្ធិទេ ។ ព្រោះកម្មប្បច្ច័យ និងវិបាកប្បច្ច័យ គឺនូវវិបាកក្ខន្ធ ១ ជាអតីតារម្មណ៍ ... ។ ឯប្រស្នាទាំង ៣ ចប់បរិបូណ៌ហើយ បវត្តិប្បដិសន្ធិ បណ្ឌិតគប្បីធ្វើផងចុះ ។ ព្រោះអាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

[ ៤១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

អនុលោម ចប់

[ ៤១២ ] អតីតារម្មណធម៌ អាស្រ័យនូវអតីតារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាអតីតារម្មណ៍ នូវខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៤១៣ ] អនាគតារម្មណធម៌ អាស្រ័យនូវអនាគតារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាអនាគតារម្មណ៍ នូវខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយ

ឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ៤១៤ ] បច្ចុប្បន្នារម្មណធម៌ អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាបច្ចុប្បន្នារម្មណ៍ នូវខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកបច្ចុប្បន្នារម្មណក្ខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៤១៥ ] អតីតារម្មណធម៌ អាស្រ័យនូវអតីតារម្មណធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺប្រហែលគ្នានឹងសហជាតប្បច្ច័យ ក្នុងអនុលោមដែរ ។

[ ៤១៦ ] អតីតារម្មណធម៌ អាស្រ័យនូវអតីតារម្មណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺអាស្រ័យនូវខន្ធ ១ ជាអតីតារម្មណ៍ ក្នុងអរូប នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៤១៧ ] អនាគតារម្មណធម៌ អាស្រ័យនូវអនាគតារម្មណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអនាគតារម្មណ៍ ក្នុងអរូប នូវខន្ធ ២ ... ។

[ ៤១៨ ] បច្ចុប្បន្នារម្មណធម៌ អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺអាស្រ័យនូវខន្ធ ១ ជាបច្ចុប្បន្នារម្មណ៍ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

[ ៤១៩ ] អតីតារម្មណធម៌ អាស្រ័យនូវអតីតារម្មណធម៌ ទើបកើត

ឡើង ព្រោះនបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ គឺដូចគ្នានឹងអធិប-តិប្បច្ច័យដែរ ។ ព្រោះកម្មប្បច្ច័យ គឺចេតនាជាអតីតារម្មណ៍ អាស្រ័យនូវពួកខន្ធជាអតីតារម្មណ៍ ។

[ ៤២០ ] អនាគតារម្មណធម៌ អាស្រ័យនូវអនាគតារម្មណធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាជាអនាគតារម្មណ៍ អាស្រ័យនូវពួកខន្ធ ជាអនាគតារម្មណ៍ ។

[ ៤២១ ] បច្ចុប្បន្នារម្មណធម៌ អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាជាបច្ចុប្បន្នារម្មណ៍ អាស្រ័យនូវពួកខន្ធ ជាបច្ចុប្បន្នារម្មណ៍ ។

[ ៤២២ ] អតីតារម្មណធម៌ អាស្រ័យនូវអតីតារម្មណធម៌ ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺក្នុងនវិបាកប្បច្ច័យ មិនមានបដិសន្ធិទេ ។

[ ៤២៣ ] បច្ចុប្បន្នារម្មណធម៌ អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយបញ្ចវិញ្ញាណ នូវខន្ធ ២ ... ។

[ ៤២៤ ] អតីតារម្មណធម៌ អាស្រ័យនូវអតីតារម្មណធម៌ ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ គឺអាស្រ័យនូវអហេតុកក្ខន្ធ ១ ជាអតីតារម្មណ៍ប្រស្នា ៣ ប្រហែលគ្នានឹងនហេតុប្បច្ច័យដែរ ឯមោហៈមិនមានទេ ។

[ ៤២៥ ] អតីតារម្មណធម៌ អាស្រ័យនូវអតីតារម្មណធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺអាស្រ័យនូវខន្ធ ១ ជាអតីតារម្មណ៍ ក្នុង

អរូប នូវខន្ធ ២ ... ។

[ ៤២៦ ] អនាគតារម្មណធម៌ អាស្រ័យនូវអនាគតារម្មណធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺអាស្រ័យនូវខន្ធ ១ ជាអនាគតារម្មណ៍ក្នុងរូប នូវខន្ធ ២ ... ។

[ ៤២៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ និងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បដិច្ចវារៈ ចប់

[ ៤២៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ និងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

អនុលោមប្បច្ចនីយៈ ចប់

[ ៤២៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ គ្រប់បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ដូចគ្នា ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បដិច្ចវារៈ ចប់

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បញ្ហាវារៈ

[ ៤៣០ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ជាអតីតារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ពួកហេតុជាអតីតារម្មណ៍ ( ជាបច្ច័យ ) នៃពួកសម្បយុត្តកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។

[ ៤៣១ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាអនាគតារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។

[ ៤៣២ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាបច្ចុប្បន្នារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ

ដោយហេតុប្បច្ច័យ ពួកហេតុជាបច្ចុប្បន្នារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្ត-កក្ខន្ធ ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។

[ ៤៣៣ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលពិចារណានូវវិញ្ញាណញ្ចាយតនៈជាអតីត ពិចា-រណានូវនេវសញ្ញានាសញ្ញាយតនៈ ពិចារណានូវអតីតឥទ្ធិវិធញ្ញាណ ជាអតីតារម្មណ៍ នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... ពិចារណានូវយថាកម្មុបគញ្ញាណ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេសជាអតីតារម្មណ៍ដែលលះបង់ហើយ នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ... នូវពួកកិលេសដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... ឃើញច្បាស់នូវពួកអតីតក្ខន្ធជាអតីតារម្មណ៍ថា មិនទៀង ជាទុក្ខ មិនមែនខ្លួន ត្រេកអរ រីករាយរាគៈជាអតីតារម្មណ៍ ប្រារព្ធនូវអតីតក្ខន្ធនោះ ទើបកើតឡើង ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចៈ ... ទោមនស្សកើតឡើង ពួកអតីតក្ខន្ធ ជាអតីតារម្មណ៍ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណនិងយថាកម្មុបគញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៣៤ ] អតីតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលពិចារណានូវវិញ្ញាណញ្ចាយតនៈ ជាអនាគត ពិចារណានូវនេវសញ្ញានាសញ្ញាយតនៈ ពិចារណានូវអនាគតឥទ្ធិវិធញ្ញាណ ជាអតីតារម្មណ៍ នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មុបគញ្ញាណ ... ឃើញច្បាស់នូវពួកអនាគតក្ខន្ធ ជាអតីតារម្មណ៍

ថា មិនទៀង ... ត្រេកអរ រីករាយ រាគៈជាអនាគតារម្មណ៍ ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ទោមនស្សកើតឡើង ពួកអនាគតក្ខន្ធជាអតីតារម្មណ៍ ( ជាបច្ច័យ ) នៃការពិចារណានូវចេតោបរិយញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៣៥ ] អតីតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលដឹងនូវចិត្តនៃបុគ្គលអ្នកប្រកបដោយបច្ចុប្បន្នចិត្តជាអតីតារម្មណ៍ ដោយចេតោបរិយញ្ញាណ ពួកបច្ចុប្បន្នក្ខន្ធជាអតីតារម្មណ៍ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៣៦ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលពិចារណានូវអនាគតឥទ្ធិវិធញ្ញាណ ជាអនាគតារម្មណ៍ នូវចេតោបរិយញ្ញាណ ... នូវអនាគតំសញ្ញាណ ... ឃើញច្បាស់នូវពួកអនាគតក្ខន្ធជាអនាគតារម្មណ៍ ថាមិនទៀង ... ត្រេកអរ រីករាយ រាគៈជាអនាគតារម្មណ៍ ប្រារព្ធនូវខន្ធនោះ ... ទោមនស្ស កើតឡើង ពួកអនាគតក្ខន្ធ ជាអនាគតារម្មណ៍ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៣៧ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលពិចារណានូវអតីតឥទ្ធិវិធញ្ញាណ ជាអនាគតារម្មណ៍ នូវចេតោបរិយញ្ញាណ ... នូវអនាគតំសញ្ញាណ ... ពួកព្រះអរិយៈពិចារណានូវពួកកិលេស ជាអនាគតារម្មណ៍ដែលលះបង់ហើយ ពិចារណា

នូវពួកកិលេសដែលសង្កត់សង្កិនហើយ នូវពួកកិលេសដែលធ្លាប់សន្សំមកហើយ ក្នុងកាលមុន ... ឃើញច្បាស់នូវពួកអតីតក្ខន្ធ ជាអនាគតារម្មណ៍ ថាមិនទៀង ... ត្រេកអរ រីករាយ រាគៈជាអតីតារម្មណ៍ ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ទោមនស្សកើតឡើង ពួកអតីតក្ខន្ធជាអនាគតារម្មណ៍ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងយថាកម្មុបគញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៣៨ ] អនាគតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយបច្ចុប្បន្នចិត្តជាអនាគតារម្មណ៍ ដោយចេតោបរិយញ្ញាណ ពួកបច្ចុប្បន្នក្ខន្ធជាអនាគតារម្មណ៍ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៣៩ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយបច្ចុប្បន្នចិត្តជាបច្ចុប្បន្នារម្មណ៍ ដោយចេតោបរិយញ្ញាណ ពួកបច្ចុប្បន្នក្ខន្ធជាបច្ចុប្បន្នារម្មណ៍ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៤០ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលពិចារណានូវទិព្វចក្ខុជាអតីត ពិចារណានូវទិព្វសោតធាតុ ពិចារណានូវអតីតឥទ្ធិវិធញ្ញាណ ជាបច្ចុប្បន្នារម្មណ៍ នូវចេតោ-

បរិយញ្ញាណ ... ពួកព្រះអរិយៈពិចារណានូវពួកកិលេស ជាបច្ចុប្បន្នារម្មណ៍ ដែលលះបង់ហើយ នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ... នូវពួកកិលេស ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... ឃើញច្បាស់នូវពួកអតីតក្ខន្ធជាបច្ចុប្បន្នារម្មណ៍ ថាមិនទៀង ... ត្រេកអរ រីករាយ រាគៈជាអតីតារម្មណ៍ ប្រារព្ធនូវពួកខន្ធនោះ ... ទោមនស្ស កើតឡើង ពួកអតីតក្ខន្ធ ជាបច្ចុប្បន្នារម្មណ៍ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងយថាកម្មុបគញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៤១ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលពិចារណានូវទិព្វចក្ខុជាអនាគត ពិចារណានូវទិព្វសោតធាតុ ពិចារណានូវអនាគតឥទ្ធិវិធញ្ញាណ ជាបច្ចុប្បន្នារម្មណ៍ នូវចេតោបរិយញ្ញាណ ... ឃើញច្បាស់នូវពួកអនាគតក្ខន្ធ ជាបច្ចុប្បន្នារម្មណ៍ ថាមិនទៀង ... ។បេ។ រាគៈជាអនាគតារម្មណ៍ ប្រារព្ធនូវខន្ធនោះ ទោមនស្ស កើតឡើង ពួកអនាគតក្ខន្ធ ជាបច្ចុប្បន្នារម្មណ៍ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៤៤២ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវវិញ្ញាណញ្ចាយតនៈជាអតីត ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវនេវសញ្ញានាសញ្ញាយតនៈ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវអតីតឥទ្ធិវិធញ្ញាណ ជាអតីតារម្មណ៍ ឲ្យជាទីគោរព ហើយពិចារណា

នូវចេតោបរិយញ្ញាណ នូវបុព្វេនិវាសានុស្សតិញ្ញាណ ... ធ្វើនូវយថាកម្មុប-គញ្ញាណឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវពួកអតីតក្ខន្ធជាអតីតារម្មណ៍ឲ្យជាទីគោរព ហើយពិចារណា ... ត្រេកអរ រីករាយ រាគៈជាអតីតារម្មណ៍ធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអតីតារម្មណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៤៤៣ ] អតីតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវវិញ្ញាណញ្ចាយតនៈជាអនាគត ឲ្យជាទីគោរព ... នូវនេវសញ្ញានាសញ្ញាយតនៈ ... ធ្វើនូវអនាគតតទ្ធិវិធញ្ញាណជាអតីតារម្មណ៍ ឲ្យជាទីគោរព ... នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មុបគញ្ញាណ ធ្វើនូវពួកអនាគតក្ខន្ធ ជាអតីតារម្មណ៍ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈជាអនាគតារម្មណ៍ ធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៤៤៤ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្ម-ណាធិបតិ គឺបុគ្គលធ្វើនូវអនាគតតទ្ធិវិធញ្ញាណ ជាអនាគតារម្មណ៍ ឲ្យជាទីគោរព ... នូវចេតោបរិយញ្ញាណ ... ធ្វើនូវអនាគតំសញ្ញាណ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវពួកអនាគតក្ខន្ធ ជាអនាគតារម្មណ៍ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈជាអនាគតារម្មណ៍ ធ្វើនូវខន្ធនោះ ឲ្យជាទី

គោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ សហជាតាធិបតិ គឺអនាគតា-
រម្មណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៤៤៥ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយ
អធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ ឯអា-
រម្មណាធិបតិ គឺបុគ្គលធ្វើនូវអតីតឥទ្ធិវិធញ្ញាណ ជាអនាគតារម្មណ៍ ឲ្យជាទី
គោរព ... នូវចេតោបរិយញ្ញាណ ... ធ្វើនូវអនាគតំសញ្ញាណឲ្យជាទីគោរព ...
ធ្វើនូវពួកអតីតក្ខន្ធជាអនាគតារម្មណ៍ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ
រាគៈជាអតីតារម្មណ៍ ធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើត
ឡើង ។

[ ៤៤៦ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយ
អធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺបច្ចុប្បន្នារម្មណាធិបតិធម៌ ជា
បច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៤៤៧ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយ
អធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវទិព្វចក្ខុជាអតីត ឲ្យ
ជាទីគោរព ហើយពិចារណា ធ្វើនូវទិព្វសោតធាតុ ឲ្យជាទីគោរព ហើយ
ពិចារណា ធ្វើនូវអតីតឥទ្ធិវិធញ្ញាណជាបច្ចុប្បន្នារម្មណ៍ ឲ្យជាទីគោរព ... ធ្វើ
នូវចេតោបរិយញ្ញាណ ឲ្យជាទីគោរព ... ធ្វើនូវពួកអតីតក្ខន្ធជាបច្ចុប្បន្នារម្មណ៍
ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈជាអតីតារម្មណ៍ ធ្វើនូវខន្ធនោះ
ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៤៤៨ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវទិព្វចក្ខុជាអនាគតឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវទិព្វសោតធាតុ ឲ្យជាទីគោរព ... ធ្វើនូវអនាគតឥទ្ធិវិធញ្ញាណ ជាបច្ចុប្បន្នារម្មណ៍ឲ្យជាទីគោរព ធ្វើនូវពួកអនាគតក្ខន្ធ ជាបច្ចុប្បន្នារម្មណ៍ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈជាអនាគតារម្មណ៍ ធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៤៤៩ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកអតីតារម្មណក្ខន្ធមុនៗ ជាបច្ច័យនៃពួកអតីតារម្មណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។

[ ៤៥០ ] អតីតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺអតីតារម្មណភវង្គ ជាបច្ច័យនៃអាវជ្ជនា ជាអនាគតារម្មណ៍ ដោយអនន្តរប្បច្ច័យ ។

[ ៤៥១ ] អតីតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺចុតិចិត្តជាអតីតារម្មណ៍ ជាបច្ច័យនៃបដិសន្ធិចិត្តជាបច្ចុប្បន្នារម្មណ៍ ដោយអនន្តរប្បច្ច័យ អតីតារម្មណភវង្គ ជាបច្ច័យនៃអាវជ្ជនា ជាបច្ចុប្បន្នារម្មណ៍ ដោយអនន្តរប្បច្ច័យ ។

[ ៤៥២ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកអនាគតារម្មណក្ខន្ធមុនៗ ជាបច្ច័យនៃពួកអនាគតារម្មណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៣ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺឥទ្ធិវិធញ្ញាណ ជាអនាគតារម្មណ៍ ជាបច្ច័យនៃវុដ្ឋានៈ ( ការចេញ ) ជាអតីតារម្មណ៍ ចេតោបរិយញ្ញាណ ( ជាបច្ច័យ ) នៃវុដ្ឋានៈ ជាអតីតារម្មណ៍ អនាគតំសញ្ញាណ ( ជាបច្ច័យ ) នៃវុដ្ឋានៈ ជាអតីតារម្មណ៍ ពួកអនាគតារម្មណក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ ជាអតីតារម្មណ៍ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៤ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកបច្ចុប្បន្នារម្មណក្ខន្ធមុនៗ ជាបច្ច័យនៃពួកបច្ចុប្បន្នារម្មណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ បដិសន្ធិចិត្តជាបច្ចុប្បន្នារម្មណ៍ ( ជាបច្ច័យ ) នៃបច្ចុប្បន្នារម្មណភវង្គ បច្ចុប្បន្នារម្មណភវង្គ ជាបច្ច័យនៃបច្ចុប្បន្នារម្មណភវង្គ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៥ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺបដិសន្ធិចិត្ត ជាបច្ចុប្បន្នារម្មណ៍ ( ជាបច្ច័យ ) នៃភវង្គ ជាអតីតារម្មណ៍ បច្ចុប្បន្នារម្មណភវង្គ ( ជាបច្ច័យ ) នៃអតីតារម្មណភវង្គ ពួកបច្ចុប្បន្នារម្មណក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ ជាអតីតារម្មណ៍ ដោយអនន្តរប្បច្ច័យ ។

[ ៤៥៦ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយសមនន្តរប្បច្ច័យ គឺដូចគ្នានឹងអនន្តរប្បច្ច័យដែរ ។

[ ៤៥៧ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយ

សហជាតបច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្ស-យប្បច្ច័យ ។ ឯបច្ច័យទាំង ៣ ( នេះ ) ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៤៥៨ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនាជាអតីតារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនាជាអតីតារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៥៩ ] អតីតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាអតីតារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខានុ-បស្សនា និងអនត្តានុបស្សនាជាអនាគតារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦០ ] អតីតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាអតីតារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនាជាបច្ចុប្បន្នារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦១ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និង

បកតូបនិស្ស័យ ។ ឯកបតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាអនាគតារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខា-នុបស្សនា និងអនត្តានុបស្សនាជាអនាគតារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦២ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាអនាគតារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខា-នុបស្សនា និងអនត្តានុបស្សនា ជាអតីតារម្មណ៍ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦៣ ] អនាគតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុ-បស្សនា និងអនត្តានុបស្សនា ជាអនាគតារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាបច្ចុប្បន្នារម្មណ៍ ដោយឧបនិស្ស-យប្បច្ច័យ ។

[ ៤៦៤ ] បច្ចុប្បន្នារម្មណធម៌ ( ជាបច្ច័យ ) នៃបច្ចុប្បន្នារម្មណធម៌ ... បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺអនិច្ចា-នុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាបច្ចុប្បន្នារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាបច្ចុប្បន្នារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦៥ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយ

ឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និង បកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាបច្ចុប្បន្នារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខា-នុបស្សនា និងអនត្តានុបស្សនា ជាអតីតារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦៦ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយ ឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និង បកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ជាបច្ចុប្បន្នារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខា-នុបស្សនា និងអនត្តានុបស្សនាជាអនាគតារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៤៦៧ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយ អាសេវនប្បច្ច័យ គឺពួកខន្ធ ជាអតីតារម្មណ៍មុនៗ ជាបច្ច័យនៃពួកខន្ធ ជា អតីតារម្មណ៍ក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៤៦៨ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយ អាសេវនប្បច្ច័យ គឺពួកខន្ធ ជាអនាគតារម្មណ៍មុនៗ ជាបច្ច័យនៃពួកខន្ធ ជា អនាគតារម្មណ៍ក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៤៦៩ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយ អសេវនប្បច្ច័យ គឺពួកខន្ធ ជាបច្ចុប្បន្នារម្មណ៍មុនៗ ជាបច្ច័យនៃពួកខន្ធ ជា បច្ចុប្បន្នារម្មណ៍ក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៤៧០ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយ

កម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនា ជាអតីតារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាជាអតីតារម្មណ៍ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាអតីតា-រម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧១ ] អតីតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺអតីតារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាអនាគតារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧២ ] អតីតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺអតីតារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាបច្ចុប្បន្នារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧៣ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺអនាគ-តារម្មណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺអនាគតារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាអនា-គតារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧៤ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺអនាគតារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាអតីតារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧៥ ] អនាគតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយ

កម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺអនាគតារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាបច្ចុប្បន្នារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧៦ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺបច្ចុប្បន្នារម្មណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺបច្ចុប្បន្នារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាបច្ចុប្បន្នារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧៧ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺបច្ចុប្បន្នារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាអតីតារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧៨ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺបច្ចុប្បន្នារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ជាអនាគតារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៤៧៩ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយវិបាកប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យដោយអត្ថិប្បច្ច័យ ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ៤៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ និងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៤៨១ ] អតីតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៨២ ] អតីតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៨៣ ] អតីតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៨៤ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយ

អារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិ-ស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៨៥ ] អនាគតារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៨៦ ] អនាគតារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៨៧ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៨៨ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអតីតារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៨៩ ] បច្ចុប្បន្នារម្មណធម៌ ជាបច្ច័យនៃអនាគតារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៤៩០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩

ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៤៩១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ និងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ។ សេចក្តីបង្រួញ ។ ក្នុងនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ៤៩២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩

ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបា-កប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ និងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យមានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បញ្ហាវារៈ ចប់

អតីតារម្មណត្តិកៈទី ១៩ ចប់

# អភិធម្មបិដក

## អជ្ឈត្តត្តិកៈ

## បដិច្ចវារៈ

[ ៤៩៣ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្នុង នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្នុង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ៣ អាស្រ័យនូវមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវមហាភូតទាំងឡាយ ។

[ ៤៩៤ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវខន្ធ ២ វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ៣ អាស្រ័យនូវមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវមហាភូតទាំងឡាយ ។

[ ៤៩៥ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ខាងក្នុង អាស្រ័យនូវខន្ធ ២ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ខាងក្នុង ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ ។

[ ៤៩៦ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ពួកខន្ធអាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ៤៩៧ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្នុង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យនូវមហាភូត ១ អាស្រ័យនូវមហាភូតទាំងឡាយ ។

[ ៤៩៨ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ... ព្រោះអធិបតិ-ប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យនូវមហាភូត ១ អាស្រ័យនូវមហាភូតទាំងឡាយ ។

[ ៤៩៩ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ... ព្រោះអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ និងសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្នុង នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្នុង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ៣ អាស្រ័យនូវមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវមហាភូតទាំងឡាយ អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូបនិងឧបាទារូប អាស្រ័យនូវម-ហាភូត ១ របស់ពួកអសញ្ញសត្វ អាស្រ័យនូវមហាភូតទាំងឡាយ ។

[ ៥០០ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធ អាស្រ័យនូវវត្ថុ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវមហាភូត ១ អាស្រ័យនូវមហាភូតទាំងឡាយ ពាហិរ ... អាហារសមុដ្ឋាន ឧតុសមុដ្ឋាន ... កដត្តារូប និងឧបាទារូប អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ អាស្រ័យនូវមហាភូតទាំងឡាយ ។

[ ៥០១ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ និងអាសេវនប្បច្ច័យ គឺបដិសន្ធិមិនមានក្នុងបុរេជាតប្បច្ច័យ និងអាសេវនប្បច្ច័យទេ ។ ព្រោះកម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យនិងអវិគតប្បច្ច័យ ។

[ ៥០២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

**អនុលោម ចប់**

[ ៥០៣ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១

ខាងក្នុង នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ... អាហារសមុដ្ឋាន ... ឧតុ-សមុដ្ឋាន ... នូវមហាភូត ១ របស់ពួកអសញ្ញសត្វ ... កដត្តារូប និងឧបាទា-រូប អាស្រ័យនូវពួកមហាភូត មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ៥០៤ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ អាស្រ័យនូវមហាភូត ១ ពាហិរ ... អាហារ-សមុដ្ឋាន ... ឧតុសមុដ្ឋាន ... អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ៥០៥ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ខាងក្នុង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យនូវពួកខន្ធ ខាងក្នុង វត្ថុ អាស្រ័យនូវពួកខន្ធ អាហារសមុដ្ឋាន អាស្រ័យនូវមហាភូត ១ ... ឧតុសមុដ្ឋាន ... អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ ។

[ ៥០៦ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ខាងក្រៅ ក្នុង

ខណៈនៃបដិសន្ធិ កដត្តារូបអាស្រ័យនូវពួកខន្ធ ខាងក្រៅ វត្ថុអាស្រ័យនូវពួកខន្ធ នូវមហាភូត ១ ... ពាហិរ ... អាហារ ... ឧតុ ... របស់ពួកអសញ្ញសត្វ ... ។

[ ៥០៧ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។បេ។ ដូចគ្នានឹងសហជាតប្បច្ច័យក្នុងអនុលោមដែរ ការធ្វើឲ្យផ្សេងៗ គ្នា មិនមានទេ ។ ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ និងនបុរេជាតប្បច្ច័យ គឺអាស្រ័យនូវខន្ធ ១ ខាងក្នុង ក្នុងអរូប ។បេ។ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធខាងក្នុង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្នុង ... នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ អាហារអាស្រ័យនូវមហាភូត ១ ... ឧតុ ... របស់ពួកអសញ្ញសត្វ... ។

[ ៥០៨ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ មានសេចក្តីបរិបូណ៌ ។ នូវមហាភូត ១ ... ពាហិរ:... អាហារ... ឧតុ... របស់ពួកអសញ្ញសត្វ ... ។

[ ៥០៩ ] អាស្រ័យនូវធម៌ខាងក្នុង ... ព្រោះនបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ និងនកម្មប្បច្ច័យ គឺចេតនាខាងក្នុង អាស្រ័យនូវពួកខន្ធ ខាងក្នុង អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... ។

[ ៥១០ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ... ព្រោះនកម្មប្បច្ច័យ គឺចេតនាខាងក្រៅ អាស្រ័យនូវពួកខន្ធខាងក្រៅ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... ។

[ ៥១១ ] អាស្រ័យនូវធម៌ខាងក្នុង ... ព្រោះនវិបាកប្បច្ច័យ គឺបដិសន្ធិមិនមានទេ ។ ព្រោះនអាហារប្បច្ច័យ ឧតុ ... របស់ពួកអសញ្ញសត្វ ... ។

[ ៥១២ ] អាស្រ័យនូវធម៌ខាងក្រៅ ... ព្រោះនអាហារប្បច្ច័យ គឺពាហិរ ... ឧតុ ... របស់ពួកអសញ្ញសត្វ ... ។

[ ៥១៣ ] អាស្រ័យនូវធម៌ខាងក្នុង ... ព្រោះនឥន្ទ្រិយប្បច្ច័យ គឺអាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... រូបជីវិតិន្ទ្រិយ អាស្រ័យនូវពួកមហាភូតរបស់ពួកអសញ្ញសត្វ ។

[ ៥១៤ ] អាស្រ័យនូវធម៌ខាងក្រៅ ... ព្រោះនឥន្ទ្រិយប្បច្ច័យ គឺពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... រូបជីវិតិន្ទ្រិយ អាស្រ័យនូវពួកមហាភូត របស់ពួកអសញ្ញសត្វ ។

[ ៥១៥ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ... ព្រោះនឈានប្បច្ច័យ គឺបញ្ចវិញ្ញាណ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ។

[ ៥១៦ ] ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ... ព្រោះនឈានប្បច្ច័យ គឺបញ្ចវិញ្ញាណ ... ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ... ។

[ ៥១៧ ] អាស្រ័យនូវធម៌ខាងក្នុង ... ព្រោះនមគ្គប្បច្ច័យ គឺដូចគ្នានឹង

នហេតុប្បច្ច័យដែរ តែមោហៈមិនមានទេ ។ ព្រោះនសម្បយុត្តប្បច្ច័យ និង នវិប្បយុត្តប្បច្ច័យ គឺក្នុងអរូប អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួក អសញ្ញសត្វ ... ។

[ ៥១៨ ] អាស្រ័យនូវធម៌ខាងក្រៅ ... ព្រោះនវិប្បយុត្តប្បច្ច័យ គឺក្នុង អរូប ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញ-សត្វ ... ព្រោះនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

[ ៥១៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអនន្តរប្បច្ច័យ មាន វារៈ ២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ បច្ច័យ ទាំងអស់សុទ្ធតែមានវារៈ ២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៥២០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ក្នុងនវិបាកប្បច្ច័យ នសម្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## ចប់ អនុលោមប្បច្ចនីយៈ ។

[ ៥២១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងមគ្គប្បច្ច័យ មាន

វារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បដិច្ចវារៈ ចប់

សហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៥២២ ] ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ខាងក្នុងនឹងខន្ធ ២ ... ឯក្នុងខណៈនៃបដិសន្ធិ មានសេចក្តីបរិបូណ៌ ។ មហាភូត ១ ... ពួកខន្ធខាងក្នុង ពឹងផ្អែកនឹងវត្ថុ ។

[ ៥២៣ ] ធម៌ខាងក្រៅ ពឹងផ្អែកនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពឹងផ្អែកនឹងខន្ធ ១ ខាងក្រៅ ... ក្នុងខណៈនៃបដិសន្ធិ នឹងមហាភូត ១ ... ពួកខន្ធខាងក្រៅ ពឹងផ្អែកនឹងវត្ថុ ។

[ ៥២៤ ] ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺដូចបដិច្ចវារៈដែរ ។ ចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ ... ពួកខន្ធខាងក្នុង ពឹងផ្អែកនឹងវត្ថុ ។

[ ៥២៥ ] ធម៌ខាងក្រៅ ពឹងផ្អែកនឹងធម៌ខាងក្រៅ ... ដូចគ្នានឹងបដិច្ចវារៈដែរ ។ នឹងចក្ខាយតនៈ ... នឹងកាយាយតនៈ ... ពួកខន្ធខាងក្រៅ ពឹងផ្អែកនឹងវត្ថុ ។

[ ៥២៦ ] ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺវត្ថុដ៏លើសលែង ដូចគ្នានឹងបដិច្ចវារៈដែរ ។ ព្រោះអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ និងសហជាតប្បច្ច័យ គឺពួកបច្ច័យក្នុងមហាភូត ( ចប់ ) បរិបូណ៌ ក្នុងសហជាតវារៈ បញ្ចាយតនៈក្តី វត្ថុក្តី បណ្ឌិតគប្បីធ្វើ ក្នុងកាលជាខាងក្រោយ នៃពួកមហាភូតផង នៃពួកខន្ធផងចុះ ។ ព្រោះអញ្ញមញ្ញប្បច្ច័យនិងនិស្សយប្បច្ច័យ ។ សេចក្តីបង្រួញ ។ ព្រោះអវិគតប្បច្ច័យ ។

[ ៥២៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ ( មានវារៈ ២ ) ។ សេចក្តីបង្រួញ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

### អនុលោម ចប់

[ ៥២៨ ] ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺនឹងអហេតុកក្ខន្ធ ១ ខាងក្នុង ... វត្ថុ ពឹងផ្អែកនឹងពួកខន្ធក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកខន្ធពឹងផ្អែកនឹងវត្ថុ នឹងមហាភូត ១ ... អាហារ ... ឧតុ ... របស់ពួកអសញ្ញសត្វ ... ចក្ខាយតនៈ ... កាយាយតនៈ ... ពួកអហេតុកក្ខន្ធ ខាងក្នុងពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។

[ ៥២៩ ] ធម៌ខាងក្រៅ ពឹងផ្អែកនឹងធម៌ខាងក្រៅ ... ព្រោះនហេតុប្បច្ច័យ គឺបវត្តិប្បដិសន្ធិក្តី ពួកមហាភូតក្តី បណ្ឌិតគប្បីធ្វើផងចុះ ។ ចក្ខាយតនៈ ...

កាយាយតនៈ ... ពួកអហេតុកក្ខន្ធ ខាងក្រៅពីងផ្អែកនឹងវត្ថុ មោហៈដែលប្រឡូំដោយវិចិកិច្ឆា ប្រឡូំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រឡូំដោយវិចិកិច្ឆា ប្រឡូំដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។បេ។ ព្រោះនអារម្មណប្បច្ច័យ និងនអធិបតិប្បច្ច័យ គឺដូចគ្នានឹងសហជាតវារៈដែរ ។ ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ និងនបុរេជា-តប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈដែរ ។ ព្រោះនបច្ឆាជាតប្បច្ច័យ នអាសេវ-នប្បច្ច័យ និងនកម្មប្បច្ច័យ ។ សេចក្តីបង្រួញ ។ ព្រោះនវិប្បយុត្តប្បច្ច័យ គឺដូចគ្នានឹងវិប្បយុត្តប្បច្ច័យ ក្នុងបច្ចនីយៈនៃបដិច្ចវារៈដែរ ។ ព្រោះនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

[ ៥៣០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ។

## បច្ចនីយៈ ចប់

[ ៥៣១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងនវិបាកប្បច្ច័យ នសម្ប-យុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ២ ។

## អនុលោមបច្ចនីយៈ ចប់

[ ៥៣២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

## បច្ចនីយានុលោម ចប់

និស្សយវារៈ ដូចគ្នានឹងបច្ចយវារៈដែរ ឯសំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារចុះ ។

## បញ្ហាវារៈ

[ ៥៣៣ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយហេតុប្បច្ច័យ គឺពួកហេតុខាងក្នុង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៥៣៤ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយហេតុប្បច្ច័យ គឺពួកហេតុខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៥៣៥ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយពិចារណានូវកុសលនោះ នូវកុសលទាំងឡាយ ដែលធ្លាប់សន្សំហើយក្នុងកាលមុន ... ចេញអំពីឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវពួកកិលេស ដែលលះបង់ហើយ ពិចារណានូវពួកកិលេសដែលសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលធ្លាប់សន្សំហើយក្នុងកាលមុន នូវចក្ខុខាងក្នុង ... នូវកាយ ពួករូប ... នូវពួកផោដ្ឋព្វៈ វត្ថុ ... ឃើញច្បាស់នូវពួកខន្ធ ខាងក្នុង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ រាគៈប្រារព្ធនូវខន្ធនោះ ... ទោមនស្សកើតឡើង ឃើញនូវរូបដោយទិព្វចក្ខុ ... ឮនូវសំឡេងដោយទិព្វសោតធាតុ អាកាសានញ្ចាយតនៈ

ជាបច្ច័យនៃវិញ្ញាណញ្ចាយតនៈ ដោយអារម្មណប្បច្ច័យ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយអារម្មណប្បច្ច័យ រូបាយតនៈ ... ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកខន្ធខាងក្នុង ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណដោយអារម្មណប្បច្ច័យ ។

[ ៥៣៦ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ គឺបុគ្គលដទៃ ( ឃើញ ) នូវចក្ខុខាងក្នុង ។ សេចក្តីបង្រួញ ។ នូវវត្ថុ ... ឃើញច្បាស់នូវពួកខន្ធ ខាងក្នុង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ រាគៈប្រារព្ធនូវខន្ធនោះ ... ទោមនស្សកើតឡើង នូវរូបដោយទិព្វចក្ខុ ... នូវសំឡេង ដោយទិព្វសោតធាតុ ... ដឹងនូវចិត្តរបស់អ្នកប្រកបដោយចិត្ត ខាងក្នុង ដោយចេតោបរិយញ្ញាណ រូបាយតនៈ ខាងក្នុង ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណខាងក្រៅ ផោដ្ឋព្វាយតនៈខាងក្នុង ជាបច្ច័យនៃកាយវិញ្ញាណខាងក្រៅ ដោយអារម្មណប្បច្ច័យ ពួកខន្ធខាងក្នុង ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៥៣៧ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ គឺបុគ្គលដទៃឲ្យទាន នូវសីល ... នូវឧបោសថកម្ម ... ហើយពិចារណានូវកុលសនោះ ពិចារណានូវកុសលទាំងឡាយ ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ ហើយ

ពិចារណានូវមគ្គ ពិចារណានូវផល ... នូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទាន: មគ្គ និងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេសដែលលះបង់ហើយ នូវពួកកិលេសដែលសង្កត់សង្កិនហើយ ... នូវពួកកិលេស ដែលធ្លាប់សន្សំមកហើយ ក្នុងកាលមុន ... បុគ្គលដទៃ នូវចក្ខុខាងក្រៅ ... នូវវត្ថុ ... នូវពួកខន្ធខាងក្រៅជាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលនូវរូបដោយទិព្វចក្ខុ ... នូវសំឡេងដោយទិព្វសោតធាតុ ... របស់បុគ្គលអ្នកប្រកបដោយចិត្តខាងក្រៅ ដោយចេតោបរិយញ្ញាណ ... អាកាសានញ្ចាយតនៈ ជាបច្ច័យនៃវិញ្ញាណញ្ចាយតនៈ ដោយអារម្មណប្បច្ច័យ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយអារម្មណប្បច្ច័យ ពួកខន្ធខាងក្រៅ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ និងចេតោបរិយញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៥៣៨ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទាន: មគ្គ និងផល ដោយអារម្មណប្បច្ច័យ បុគ្គល នូវចក្ខុខាងក្រៅ ... នូវវត្ថុ ... នូវពួកខន្ធខាងក្រៅ ជាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយចិត្តខាងក្រៅ ដោយចេតោបរិយញ្ញាណ រូបាយតនៈខាងក្រៅ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណខាងក្នុង ផោដ្ឋព្វាយតនៈខាងក្រៅ ( ជាបច្ច័យ ) នៃកាយវិញ្ញាណខាងក្នុង ពួកខន្ធខាងក្រៅ ជា

បច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៥៣៩ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន នូវសីល ... នូវឧបោសថកម្ម ... ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវកុសលទាំងឡាយដែលធ្លាប់សន្សំល្អហើយ ក្នុងកាលមុន ឲ្យជាទីគោរព ... ចេញអំពីឈាន ធ្វើនូវឈានឲ្យជាទីគោរព ... ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយធ្វើនូវមគ្គឲ្យជាទីគោរព ... ធ្វើនូវផល ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវចក្ខុខាងក្នុង ... នូវវត្ថុ ... នូវពួកខន្ធខាងក្នុង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ... ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ខាងក្នុង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៥៤០ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលដទៃធ្វើនូវចក្ខុខាងក្នុង ... នូវវត្ថុ ... នូវពួកខន្ធខាងក្នុង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៥៤១ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គល

ដទៃឲ្យទាន នូវសីល ... នូវឧបោសថកម្ម ... ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ... ធ្វើនូវកុសលទាំងឡាយ ដែលសន្សំល្អហើយក្នុងកាលមុន ឲ្យជាទីគោរព ... ចេញអំពីឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ ធ្វើនូវមគ្គ ឲ្យជាទីគោរព ... ធ្វើនូវផលឲ្យជាទីគោរព ... ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុខាងក្រៅ ... នូវវត្ថុ ... ធ្វើនូវពួកខន្ធខាងក្រៅ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៥៤២ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកព្រះអរិយៈធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុខាងក្រៅ ... នូវវត្ថុ ... ធ្វើនូវពួកខន្ធខាងក្រៅ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ... ទិដ្ឋិកើតឡើង ។

[ ៥៤៣ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធខាងក្នុងមុនៗ ជាបច្ច័យនៃពួកខន្ធខាងក្នុងក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ( ជាបច្ច័យ ) នៃមគ្គ

មគ្គ ( ជាបច្ច័យ ) នៃផល ។បេ។ អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈរបស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរបច្ច័យ ។

[ ៥៤៤ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអនន្តរបច្ច័យ គឺត្រង់ពាក្យថា ពួកខន្ធខាងក្រៅមុនៗ នោះ ជាដំណើរធ្វើឲ្យផ្សេងគ្នាបុណ្ណោះឯង ។

[ ៥៤៥ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយសមនន្តរបច្ច័យ គឺដូចអនន្តរបច្ច័យដែរ ។បេ។ ជាបច្ច័យដោយសហជាតបច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញបច្ច័យ ជាបច្ច័យដោយនិស្សយបច្ច័យ ជាបច្ច័យដោយឧបនិស្សយបច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធាខាងក្នុង ហើយឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ... នូវឈាន ... ញុំាងវិបស្សនា ... ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិឲ្យកើតឡើង ជំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីលខាងក្នុង ... នូវបញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ រដូវ ភោជន ... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ... ញុំាងសមាបត្តិឲ្យកើតឡើង សម្លាប់សត្វ បំបែកសង្ឃ សទ្ធាខាងក្នុង ... បញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ ... សេនាសនៈ ជាបច្ច័យនៃសទ្ធាខាងក្នុង នៃបញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយបច្ច័យ ។

[ ៥៤៦ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលដទៃអាស្រ័យនូវសទ្ធាខាងក្នុង ហើយឲ្យទាន ... ញុំងមានះ ប្រកាន់ទិដ្ឋិ បុគ្គលដទៃ នូវសីលខាងក្នុង ... អាស្រ័យនូវសេនាសនៈ ហើយឲ្យទាន ... សម្លាប់សត្វ បំបែកសង្ឃ សទ្ធាខាងក្នុង ... សេនាសនៈជាបច្ច័យនៃសទ្ធាខាងក្រៅ នៃមគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៧ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលដទៃ អាស្រ័យនូវសទ្ធាខាងក្រៅ ... នូវសេចក្តីប្រាថ្នា កាយិកសុខ ... នូវសេនាសនៈ ហើយឲ្យទាន ... បំបែកសង្ឃ សទ្ធាខាងក្រៅ ... សេនាសនៈ ជាបច្ច័យនៃសទ្ធាខាងក្រៅ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៨ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធាខាងក្រៅ ... នូវសេនាសនៈ ហើយឲ្យទាន ... បំបែកសង្ឃ សទ្ធាខាងក្រៅ ... សេនាសនៈ ជាបច្ច័យនៃសទ្ធាខាងក្នុង និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៩ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គល

នូវចក្ខុ ខាងក្នុង ... នូវវត្ថុ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន ... ទោមនស្ស កើតឡើង បុគ្គល ( ឃើញ ) នូវរូប ដោយទិព្វចក្ខុ ... ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកខន្ធខាងក្នុង ដោយបុរេជាតប្បច្ច័យ ។

[ ៥៥០ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត គឺបុគ្គលដទៃ ( ឃើញ ) នូវចក្ខុខាងក្នុង ... នូវវត្ថុ ជាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ខាងក្នុង ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណខាងក្រៅ ផោដ្ឋព្វាយតនៈខាងក្នុង ជាបច្ច័យនៃកាយវិញ្ញាណខាងក្រៅ ដោយបុរេជាតប្បច្ច័យ ។

[ ៥៥១ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលដទៃ ( ឃើញ ) នូវចក្ខុខាងក្រៅ ... នូវវត្ថុ ជាមិនទៀង ... ឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ខាងក្រៅ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណខាងក្រៅ ផោដ្ឋព្វាយតនៈ ខាងក្រៅ ( ជាបច្ច័យ ) នៃកាយវិញ្ញាណខាងក្រៅ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈខាងក្រៅ ... កាយាយតនៈ ... វត្ថុជាបច្ច័យនៃពួកខន្ធខាងក្រៅ ដោយបុរេជា-

តប្បច្ច័យ ។

[ ៥៥២ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត គឺបុគ្គល ( ឃើញ ) នូវចក្ខុខាងក្រៅ ... នូវវត្ថុជាមិនទៀង ... ទោមនស្សកើតឡើង បុគ្គល ( ឃើញ ) នូវរូបដោយទិព្វចក្ខុ ... នូវសំឡេងដោយទិព្វសោតធាតុ ... រូបាយតនៈខាងក្រៅ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណខាងក្នុង ។បេ។ ផោដ្ឋព្វាយតនៈខាងក្រៅ ជាបច្ច័យនៃកាយវិញ្ញាណខាងក្នុង ដោយបុរេជាតប្បច្ច័យ ។

[ ៥៥៣ ] ធម៌ខាងក្នុងក្ដី ធម៌ខាងក្រៅក្ដី ជាបច្ច័យនៃធម៌ខាងក្នុង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត គឺរូបាយតនៈខាងក្រៅក្ដី ចក្ខាយតនៈខាងក្នុងក្ដី ជាបច្ច័យនៃចក្ខុវិញ្ញាណខាងក្នុង ដោយបុរេជាតប្បច្ច័យ ផោដ្ឋព្វាយតនៈខាងក្រៅក្ដី កាយាយតនៈខាងក្នុងក្ដី ( ជាបច្ច័យ ) នៃកាយវិញ្ញាណខាងក្នុង រូបាយតនៈខាងក្រៅក្ដី វត្ថុខាងក្នុងក្ដី ... ផោដ្ឋព្វាយតនៈខាងក្រៅក្ដី វត្ថុខាងក្នុងក្ដី ជាបច្ច័យនៃពួកខន្ធខាងក្នុង ដោយបុរេជាតប្បច្ច័យ ។

[ ៥៥៤ ] ធម៌ខាងក្នុងក្ដី ធម៌ខាងក្រៅក្ដី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត គឺរូបាយតនៈខាងក្នុងក្ដី ចក្ខាយតនៈខាងក្រៅក្ដី ជាបច្ច័យនៃចក្ខុវិញ្ញាណខាងក្រៅ ដោយបុរេជាតប្បច្ច័យ ផោដ្ឋព្វាយតនៈខាងក្នុងក្ដី កាយាយតនៈ ខាងក្រៅក្ដី ជាបច្ច័យនៃកាយវិញ្ញាណខាងក្រៅ ដោយបុរេជាតប្បច្ច័យ រូបាយតនៈខាងក្នុង

ក្តី វត្ថុខាងក្រៅក្តី ... ផោដ្ឋព្វាយតនៈខាងក្នុងក្តី វត្ថុខាងក្រៅក្តី ជាបច្ច័យនៃពួកខន្ធខាងក្រៅ ដោយបុរេជាតប្បច្ច័យ ។

[ ៥៥៥ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធខាងក្នុង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៥៥៦ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធខាងក្រៅ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៥៥៧ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអាសេវនប្បច្ច័យ គឺពួកខន្ធខាងក្នុងមុនៗ ជាបច្ច័យនៃពួកខន្ធខាងក្នុងក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៥៥៨ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអាសេវនប្បច្ច័យ គឺមុនៗ ។បេ។ ដូចគ្នានឹងអជ្ឈត្តធម៌ដែរ ។

[ ៥៥៩ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិក: ។ សហជាត គឺចេតនាខាងក្នុង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិក: គឺចេតនាខាងក្នុង ជាបច្ច័យនៃពួកវិបាកក្ខន្ធខាងក្នុងផង នៃ

ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៥៦០ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាខាងក្រៅ ជាបច្ច័យនៃពួកវិបាកក្ខន្ធខាងក្រៅផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៥៦១ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយវិបាកប្បច្ច័យ គឺ ( ចប់ ) បរិបូណ៌ ដូចបដិច្ចវារៈដែរ ។

[ ៥៦២ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអាហារប្បច្ច័យ គឺពួកអាហារខាងក្នុង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ កពឡិង្ការាហារខាងក្នុង ជាបច្ច័យនៃកាយខាងក្នុង ដោយអាហារប្បច្ច័យ ។

[ ៥៦៣ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារខាងក្នុង ជាបច្ច័យនៃកាយខាងក្រៅ ដោយអាហារប្បច្ច័យ ។

[ ៥៦៤ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអាហារប្បច្ច័យ បានដល់ បវត្តិប្បដិសន្ធិ ។ កពឡិង្ការាហារខាងក្រៅ ជាបច្ច័យនៃកាយខាងក្រៅ ដោយអាហារប្បច្ច័យ ។

[ ៥៦៥ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារខាងក្រៅ ជាបច្ច័យនៃកាយខាងក្នុង ដោយអាហារប្បច្ច័យ ។

[ ៥៦៦ ] ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារខាងក្នុងក្តី កពឡិង្ការាហារខាងក្រៅក្តី ជាបច្ច័យនៃកាយខាងក្នុង ដោយអាហារប្បច្ច័យ ។

[ ៥៦៧ ] ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារខាងក្នុងក្តី កពឡិង្ការាហារខាងក្រៅក្តី ជាបច្ច័យនៃកាយខាងក្រៅ ដោយអាហារប្បច្ច័យ ។

[ ៥៦៨ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយឥន្ទ្រិយប្បច្ច័យ បានដល់ ពួកឥន្ទ្រិយដែលប្រព្រឹត្តទៅខាងក្នុង ឯរូបជីវិតិន្ទ្រិយ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត បទនៃមាតិកាទាំងឡាយ បណ្ឌិត កាលអនុម័ត គប្បីឲ្យពិស្តារចុះ ។

[ ៥៦៩ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ ។

[ ៥៧០ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ខាងក្នុង ( ជាបច្ច័យ ) នៃខន្ធ ៣ ផង នៃចិត្តសមុដ្ឋានរូបផង ខន្ធ ២ ... ពួកខន្ធ ( ជាបច្ច័យ ) នៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ វត្ថុ ( ជាបច្ច័យ ) នៃពួកខន្ធ មហាភូត ១ ... ។ សេចក្តីបង្រួញ ។ មហាភូត ១ របស់

ពួកអសញ្ញសត្វ ( ជាបច្ច័យ ) នៃមហាភូត ៣ ។ បុរេជាត គឺនូវចក្ខុ ... នូវវត្ថុ ... ដូចគ្នានឹងបុរេជាតដែរ ។ វត្ថុ ជាបច្ច័យនៃពួកខន្ធខាងក្នុង ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធខាងក្នុងក្តី កពឡិង្ការាហារខាងក្នុងក្តី ( ជាបច្ច័យ ) នៃកាយនេះ រូបជីវិតិន្ទ្រិយ ( ជាបច្ច័យ ) នៃពួកកដត្តារូប ។

[ ៥៧១ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត និងអាហារ ។ បុរេជាត គឺបុគ្គលដទៃ ឃើញច្បាស់នូវចក្ខុខាងក្នុង ... នូវវត្ថុ ថាមិនទៀង ... ដោយទិព្វចក្ខុ ... ដោយទិព្វសោតធាតុ ... រូបាយតនៈខាងក្នុង ... ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណខាងក្រៅ ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារខាងក្នុង ជាបច្ច័យនៃកាយខាងក្រៅ ដោយអត្ថិប្បច្ច័យ ។

[ ៥៧២ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ មិនមានការធ្វើឲ្យផ្សេងៗ គ្នា ត្រង់ធម៌ជាខាងក្រៅឡើយ ឯបទនៃមាតិកាទាំងឡាយ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។

[ ៥៧៣ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត និងអាហារ ។ បុរេជាត គឺបុគ្គល ( ឃើញច្បាស់ ) នូវចក្ខុខាងក្រៅ ... នូវវត្ថុ ... នូវរូប ដោយទិព្វចក្ខុ ... នូវសំឡេង ដោយទិព្វសោតធាតុ ... រូបាយតនៈខាងក្រៅ ... ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណខាងក្នុង ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារខាងក្រៅ ជាបច្ច័យ

នៃកាយខាងក្នុង ដោយអត្ថិប្បច្ច័យ ។

[ ៥៧៤ ] ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត និងអាហារ ។ បុរេជាត គឺរូបាយតនៈខាងក្រៅក្តី ចក្ខុខាងក្នុងក្តី ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណខាងក្នុង ផោដ្ឋព្វាយតនៈខាងក្រៅក្តី កាយាយតនៈខាងក្នុងក្តី ជាបច្ច័យនៃកាយវិញ្ញាណខាងក្នុង ដោយអត្ថិប្បច្ច័យ រូបាយតនៈខាងក្រៅក្តី វត្ថុខាងក្នុងក្តី ... ផោដ្ឋព្វាយតនៈខាងក្រៅក្តី វត្ថុខាងក្នុងក្តី ជាបច្ច័យនៃពួកខន្ធខាងក្នុង ដោយអត្ថិប្បច្ច័យ ។ ឯអាហារ គឺកពឡិង្ការាហារខាងក្នុងក្តី កពឡិង្ការាហារខាងក្រៅក្តី ជាបច្ច័យនៃកាយខាងក្នុង ដោយអត្ថិប្បច្ច័យ ។

[ ៥៧៥ ] ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត និងអាហារ ។ បុរេជាត គឺរូបាយតនៈខាងក្នុងក្តី ចក្ខាយតនៈខាងក្រៅក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណខាងក្រៅ ដោយអត្ថិប្បច្ច័យ ផោដ្ឋព្វាយតនៈខាងក្នុងក្តី កាយាយតនៈខាងក្រៅក្តី ជាបច្ច័យនៃកាយវិញ្ញាណខាងក្រៅ ដោយអត្ថិប្បច្ច័យ រូបាយតនៈខាងក្នុងក្តី វត្ថុខាងក្រៅក្តី ជាបច្ច័យនៃពួកខន្ធខាងក្រៅ ដោយអត្ថិប្បច្ច័យ ផោដ្ឋព្វាយតនៈខាងក្នុងក្តី វត្ថុខាងក្រៅក្តី ជាបច្ច័យនៃពួកខន្ធខាងក្រៅ ដោយអត្ថិប្បច្ច័យ ។ ឯអាហារ គឺកពឡិង្ការាហារខាងក្នុងក្តី កពឡិង្ការាហារខាងក្រៅក្តី ជាបច្ច័យនៃកាយខាងក្រៅ ដោយអត្ថិប្បច្ច័យ ។

[ ៥៧៦ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយនត្ថិប្បច្ច័យ ជា

បច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ៥៧៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងបច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ និងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងអាហារប្បច្ច័យ មានវារៈ ៦ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ និងវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៥៧៨ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៧៩ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ

ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ។

[ ៥៨០ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៨១ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ។

[ ៥៨២ ] ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ... បានដល់ បុរេជាត និងអាហារ ។

[ ៥៨៣ ] ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ( ជាបច្ច័យ ) នៃធម៌ខាងក្រៅ ... បានដល់ បុរេជាត និងអាហារ ។

[ ៥៨៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៦ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ។ សេចក្តីបង្រួញ ។ គ្រប់បទទាំងអស់ បណ្ឌិតគប្បីធ្វើឲ្យមានវារៈ ៦ ផងចុះ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៦ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

**បច្ចនីយៈ ចប់**

[ ៥៨៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ២ ក្នុងនសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ៥៨៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ អនុលោមបទទាំងឡាយ បណ្ឌិតគប្បីរាប់ ( តទៅទៀតចុះ ) ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយានុលោម ចប់

## បញ្ហាវារៈ ចប់

## អជ្ឈត្តត្តិកៈទី ២០ ចប់

# អដ្ឋកថា

## អជ្ឈត្តត្តិកៈ

[ ៤៩៣-៥៨៦ ] អជ្ឈត្តបទ និងពហិទ្ធាបទ ទ្រង់មិនកាន់យកក្នុង អជ្ឈត្តត្តិកៈ ។ ពិតហើយ ពួកធម៌ទាំងពីរ គឺអជ្ឈត្តធម៌ និងពហិទ្ធធម៌ រមែង មិនជាបច្ច័យ និងបច្ចយុប្បន្នៈ ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបថា សូម្បី ពណ៌របស់គ្រាប់ស្ពៃ ដែលនៅក្នុងបាតដៃ រមែងមិនជាអារម្មណ៍ ដូចគ្នានឹង ពណ៌របស់បាតដៃ ៕

**អដ្ឋកថាអជ្ឈត្តត្តិកៈ ចប់**

# អភិធម្មបិដក

## អជ្ឈត្តារម្មណត្តិកៈ

## បដិច្ចវារៈ

[ ៥៨៧ ] អជ្ឈត្តារម្មណធម៌ អាស្រ័យនូវអជ្ឈត្តារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

[ ៥៨៨ ] ពហិទ្ធារម្មណធម៌ អាស្រ័យនូវពហិទ្ធារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាពហិទ្ធារម្មណ៍ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាពហិទ្ធារម្មណ៍ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

[ ៥៨៩ ] អជ្ឈត្តារម្មណធម៌ អាស្រ័យនូវអជ្ឈត្តារម្មណធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ សេចក្តីបង្រួញ ។ ព្រោះអវិគតប្បច្ច័យ ។

[ ៥៩០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### អនុលោម ចប់

[ ៥៩១ ] អជ្ឈត្តារម្មណធម៌ អាស្រ័យនូវអជ្ឈត្តារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជា

អជ្ឈត្តារម្មណ៍ នូវខន្ធ ២ ... អាស្រ័យនូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ ក្នុងខណៈនៃអហេតុកបដិសន្ធិ នូវខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ៥៩២ ] ពហិទ្ធារម្មណធម៌ អាស្រ័យនូវពហិទ្ធារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាពហិទ្ធារម្មណ៍ នូវខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកបដិសន្ធិ ។

[ ៥៩៣ ] អជ្ឈត្តារម្មណធម៌ អាស្រ័យនូវអជ្ឈត្តារម្មណធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺដូចសហជាតប្បច្ច័យក្នុងអនុលោមដែរ មិនមានការធ្វើឲ្យផ្សេងៗ គ្នាទេ ។ ព្រោះនបុរេជាតប្បច្ច័យ គឺអាស្រ័យនូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ ក្នុងអរូប ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៥៩៤ ] ពហិទ្ធារម្មណធម៌ អាស្រ័យនូវពហិទ្ធារម្មណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺអាស្រ័យនូវខន្ធ ១ ជាពហិទ្ធារម្មណ៍ ក្នុងអរូប ក្នុងខណៈនៃបដិសន្ធិ ... ព្រោះនបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ គឺដូចគ្នានឹងសហជាតប្បច្ច័យដែរ ។ ព្រោះនកម្មប្បច្ច័យ គឺចេតនាជាអជ្ឈត្តារម្មណ៍ អាស្រ័យនូវខន្ធទាំងឡាយ ជាអជ្ឈត្តារម្មណ៍ ។

[ ៥៩៥ ] ពហិទ្ធារម្មណធម៌ អាស្រ័យនូវពហិទ្ធារម្មណធម៌ ទើបកើត

*ឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាជាពហិទ្ធារម្មណ៍ អាស្រ័យនូវខន្ធទាំងឡាយ ជាពហិទ្ធារម្មណ៍ ។*

*[ ៥៩៦ ] អាស្រ័យនូវអជ្ឈត្តារម្មណធម៌ ... ព្រោះនវិបាកប្បច្ច័យ គឺបដិសន្ធិ មិនមានទេ ។ ព្រោះនឈានប្បច្ច័យ គឺនូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ ដែលប្រកបដោយបញ្ចវិញ្ញាណ ... ។*

*[ ៥៩៧ ] អាស្រ័យនូវពហិទ្ធារម្មណធម៌ ... ព្រោះនឈានប្បច្ច័យ គឺនូវខន្ធ ១ ជាពហិទ្ធារម្មណ៍ ដែលប្រកបដោយបញ្ចវិញ្ញាណ ... ព្រោះនមគ្គប្បច្ច័យ គឺដូចគ្នានឹងនហេតុប្បច្ច័យដែរ តែមោហៈមិនមានឡើយ ។ ព្រោះនវិប្បយុត្តប្បច្ច័យ គឺនូវខន្ធ ១ ជាអជ្ឈត្តារម្មណ៍ ក្នុងអរូប ... ។*

*[ ៥៩៨ ] អាស្រ័យនូវពហិទ្ធារម្មណធម៌ ... ព្រោះនវិប្បយុត្តប្បច្ច័យ គឺនូវខន្ធ ១ ជាពហិទ្ធារម្មណ៍ ក្នុងអរូប ... ។*

*[ ៥៩៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ នកម្មប្បច្ច័យ នវិបាកប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ និងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។*

***បច្ចនីយៈ ចប់***

*[ ៦០០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ...*

ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### អនុលោមប្បច្ចនីយៈ ចប់

[ ៦០១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### បច្ចនីយានុលោម ចប់

### បដិច្ចវារៈ ចប់

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្ត-វារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បញ្ហាវារៈ

[ ៦០២ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ពួកហេតុជាអជ្ឈត្តារម្មណ៍ ( ជាបច្ច័យ ) នៃពួកសម្ប-យុត្តកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។

[ ៦០៣ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាពហិទ្ធារម្មណ៍ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៦០៤ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលពិចារណានូវវិញ្ញាណញ្ចាយតនៈ ជាអជ្ឈត្តារម្មណ៍ ពិចារណានូវនេវសញ្ញានាសញ្ញាយតនៈ ពិចារណានូវទិព្វចក្ខុខាងក្នុង ជាអជ្ឈត្តារម្មណ៍ ពិចារណានូវទិព្វសោតធាតុ ... នូវឥទ្ធិវិធញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មុបគញ្ញាណ ... នូវអនាគតំសញ្ញាណ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេសជាអជ្ឈត្តារម្មណ៍ ដែលបានលះបង់ហើយ ពិចារណានូវពួកកិលេសដែលសង្កត់សង្កិនហើយ នូវពួកកិលេសដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... ឃើញច្បាស់នូវពួកខន្ធខាងក្នុងដែលជាអជ្ឈត្តារម្មណ៍ ជាមិនទៀង ... ត្រេកអររីករាយ រាគៈដែលជាអជ្ឈត្តារម្មណ៍ប្រារព្ធនូវខន្ធនោះ ... ទោមនស្ស ទើបកើតឡើង ពួកខន្ធខាងក្នុង ដែលជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃការពិចារណា នូវបុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦០៥ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលដទៃពិចារណានូវវិញ្ញាណញ្ចាយតនៈ ជាអជ្ឈត្តារម្មណ៍ ... នូវនេវសញ្ញានាសញ្ញាយតនៈ បុគ្គលដទៃ ពិចារណានូវទិព្វចក្ខុខាងក្នុង ដែលជាអជ្ឈត្តារម្មណ៍ ពិចារណានូវទិព្វសោតធាតុ ... នូវឥទ្ធិវិធញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មុបគញ្ញាណ ... នូវអនាគតំសញ្ញាណ ឃើញច្បាស់នូវពួកខន្ធខាងក្នុង ជាអជ្ឈត្តារម្មណ៍ ជាមិនទៀង ជាទុក្ខ ជាអនត្តា ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយអជ្ឈត្តចិត្ត

ជាអជ្ឈត្តារម្មណ៍ ដោយចេតោបរិយញ្ញាណ ពួកខន្ធខាងក្រៅ ជាអជ្ឈត្តា-រម្មណ៍ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្ស-តិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦០៦ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលដទៃពិចារណានូវទិព្វចក្ខុខាងក្រៅ ជាពហិទ្ធារម្មណ៍ នូវទិព្វសោតធាតុ ... នូវឥទ្ធិវិធញ្ញាណ ... នូវចេតោបរិយញ្ញាណ ... នូវបុព្វេ-និវាសានុស្សតិញ្ញាណ ... នូវយថាកម្មុបគញ្ញាណ ... ពិចារណានូវអនាគតំ-សញ្ញាណ បុគ្គលដទៃឃើញច្បាស់នូវពួកខន្ធខាងក្រៅ ជាពហិទ្ធារម្មណ៍ ថាមិនទៀង ជាទុក្ខ ជាអនត្តា ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយចិត្តខាងក្រៅ ជាពហិទ្ធារម្មណ៍ ដោយចេតោបរិយញ្ញាណ ពួកខន្ធខាងក្រៅ ជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវា-សានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦០៧ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ពិចា-រណានូវកុសលនោះ ពិចារណានូវកុសលទាំងឡាយ ដែលធ្លាប់សន្សំហើយក្នុងកាលមុន ចេញអំពីឈាន ហើយពិចារណានូវឈាន ព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវពួកកិលេស ដែលលះបង់ហើយ ... នូវពួកកិលេស ដែលសង្កត់សង្កិន

ហើយ ... នូវពួកកិលេសដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ។បេ។ បុគ្គល ពិចារណានូវទិព្វចក្ខុខាងក្នុង ជាពហិទ្ធារម្មណ៍ នូវទិព្វសោតធាតុ ... នូវឥទ្ធិ-វិធញ្ញាណ ... នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ... នូវអនាគតំសញ្ញាណ ... ឃើញច្បាស់នូវពួកខន្ធខាងក្នុងជាពហិទ្ធារម្មណ៍ ថាមិនទៀង ... ត្រេកអរ រីករាយ រាគៈជាអជ្ឈត្តារម្មណ៍ ប្រារព្ធនូវខន្ធនោះ ... ទោមនស្សក៏កើតឡើង ពួកខន្ធខាងក្នុងជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦០៨ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្ម-ណាធិបតិ គឺបុគ្គលធ្វើនូវវិញ្ញាណញ្ចាយតនៈខាងក្នុង ជាអជ្ឈត្តារម្មណ៍ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវនេវសញ្ញានាសញ្ញាយតនៈ ឲ្យជាទីគោរព ... ធ្វើនូវទិព្វចក្ខុខាងក្នុង ជាអជ្ឈត្តារម្មណ៍ ឲ្យជាទីគោរព ... នូវទិព្វ-សោតធាតុ ... នូវឥទ្ធិវិធញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មូបគញ្ញាណ ... ធ្វើនូវអនាគតំសញ្ញាណ ឲ្យជាទីគោរព ... ធ្វើនូវពួកខន្ធខាងក្នុង ជាអជ្ឈត្តារម្មណ៍ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈជាអជ្ឈត្តារម្មណ៍ ធ្វើនូវខន្ធនោះឲ្យជាទីគោរព ... ទិដ្ឋិកើតឡើង ។ ឯសហ-ជាតាធិបតិ គឺអជ្ឈត្តារម្មណាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៦០៩ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺពហិទ្ធារម្មណាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៦១០ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណានូវពួកកុសលដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... ចេញអំពីឈាន ... ព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ( ធ្វើ ) នូវមគ្គ ... ធ្វើនូវផល ឲ្យជាទីគោរព ... ធ្វើនូវទិព្វចក្ខុខាងក្នុង ដែលជាពហិទ្ធារម្មណ៍ ឲ្យជាទីគោរព ... ( ធ្វើ ) នូវទិព្វសោតធាតុ ( ឲ្យជាទីគោរព ) ... នូវឥទ្ធិវិធញ្ញាណ ... នូវចេតោបរិយញ្ញាណ ... នូវបុព្វេនិវាសានុស្សតិញ្ញាណ ... នូវយថាកម្មុបគញ្ញាណ ... ធ្វើនូវអនាគតំសញ្ញាណឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវពួកខន្ធខាងក្នុងដែលជាពហិទ្ធារម្មណ៍ ឲ្យជាទីគោរព ហើយត្រេកអរ រាគៈជាអជ្ឈត្តារម្មណ៍ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ... ទិដ្ឋិកើតឡើង ។

[ ៦១១ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធជាអជ្ឈត្តារម្មណ៍មុនៗ ជាបច្ច័យនៃពួកខន្ធជាអជ្ឈត្តារម្មណ៍ក្រោយៗ ដោយអនន្តរប្បច្ច័យ ។

[ ៦១២ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺចុតិចិត្តដែលជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃឧបបត្តិចិត្តដែល

ជាពហិទ្ធារម្មណ៍ ដោយអនន្តរប្បច្ច័យ កវដ្ដ:ជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃអាវជ្ជន: ជាពហិទ្ធារម្មណ៍ ដោយអនន្តរប្បច្ច័យ ពួកខន្ធជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃវុដ្ឋាន: ដែលជាពហិទ្ធារម្មណ៍ ដោយអនន្តរប្បច្ច័យ អនុលោម ដែលជាអជ្ឈត្តារម្មណ៍ ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតន:របស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ៦១៣ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធ ដែលជាពហិទ្ធារម្មណ៍មុនៗ ជាបច្ច័យនៃពួកខន្ធ ដែលជាពហិទ្ធារម្មណ៍ក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ដែលជាពហិទ្ធារម្មណ៍ ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ( ជាបច្ច័យ ) នៃមគ្គ មគ្គ ( ជាបច្ច័យ ) នៃផល ផល ( ជាបច្ច័យ ) នៃផល អនុលោម ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ៦១៤ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺចុតិចិត្តដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃឧបបត្តិចិត្តដែលជាអជ្ឈត្តារម្មណ៍ ដោយអនន្តរប្បច្ច័យ កវដ្ដ: ដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃអាវជ្ជន: ដែលជាអជ្ឈត្តារម្មណ៍ ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃវុដ្ឋាន: ដែលជាអជ្ឈត្តារម្មណ៍ ដោយអនន្ត-

រប្បច្ច័យ ។

[ ៦១៥ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយសមនន្តរប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនាដែលជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាអជ្ឈត្តារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៦១៦ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ បកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាពហិទ្ធារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៦១៧ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដែលជាពហិទ្ធារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៦១៨ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺអនិដ្ឋានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនាដែលជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃអនិដ្ឋានុបស្សនា ទុក្ខានុ-បស្សនា និងអនត្តានុបស្សនាដែលជាអជ្ឈត្តារម្មណ៍ ដោយឧបនិស្សយប្បច្ច័យ ។

[ ៦១៩ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយអាសេវនប្បច្ច័យ គឺពួកខន្ធ ដែលជាអជ្ឈត្តារម្មណ៍មុនៗ ជាបច្ច័យនៃពួកខន្ធដែលជាអជ្ឈត្តារម្មណ៍ក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៦២០ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអាសេវនប្បច្ច័យ គឺអនុលោម ដែលជាអជ្ឈត្តារម្មណ៍ ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ជាបច្ច័យនៃវោទានៈ ដោយអាសេវនប្បច្ច័យ ។

[ ៦២១ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអាសេវនប្បច្ច័យ គឺអនុលោម ដែលជាពហិទ្ធារម្មណ៍ ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៦២២ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលជា

អជ្ឈត្តារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៦២៣ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺចេតនាជាអជ្ឈត្តារម្មណ៍ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលជាពហិទ្ធារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៦២៤ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលជាពហិទ្ធារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៦២៥ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺចេតនាជាពហិទ្ធារម្មណ៍ ជាបច្ច័យនៃពួកវិបាកក្ខន្ធដែលជាអជ្ឈត្តារម្មណ៍ ដោយកម្មប្បច្ច័យ ។

[ ៦២៦ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយវិបាកប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យដោយអត្ថិប្បច្ច័យ ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ៦២៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤

ក្នុងសមនន្តរបច្ច័យ មានវារៈ ៤ ក្នុងសហជាតបច្ច័យ មានវារៈ ២ ក្នុងអញ្ញមញ្ញបច្ច័យ មានវារៈ ២ ក្នុងនិស្សយបច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយបច្ច័យ មានវារៈ ៤ ក្នុងអាសេវនបច្ច័យ មានវារៈ ៣ ក្នុងកម្មបច្ច័យ មានវារៈ ៤ ក្នុងវិបាកបច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ក្នុងសម្បយុត្តបច្ច័យ មានវារៈ ២ ក្នុងអត្ថិបច្ច័យ មានវារៈ ២ ក្នុងនត្ថិបច្ច័យ មានវារៈ ៤ ក្នុងវិគតបច្ច័យ មានវារៈ ៤ ក្នុងអវិគតបច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

## អនុលោម ចប់

[ ៦២៨ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយអារម្មណបច្ច័យ ជាបច្ច័យដោយសហជាតបច្ច័យ ជាបច្ច័យដោយឧបនិស្សយបច្ច័យ ជាបច្ច័យដោយកម្មបច្ច័យ ។

[ ៦២៩ ] អជ្ឈត្តារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអារម្មណបច្ច័យ ជាបច្ច័យដោយឧបនិស្សយបច្ច័យ ជាបច្ច័យដោយកម្មបច្ច័យ ។

[ ៦៣០ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃពហិទ្ធារម្មណធម៌ ដោយអារម្មណបច្ច័យ ជាបច្ច័យដោយសហជាតបច្ច័យ ជាបច្ច័យដោយឧបនិស្សយបច្ច័យ ជាបច្ច័យដោយកម្មបច្ច័យ ។

[ ៦៣១ ] ពហិទ្ធារម្មណធម៌ ជាបច្ច័យនៃអជ្ឈត្តារម្មណធម៌ ដោយ

អារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៦៣២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៤ ( ដូចគ្នា ) ក្នុងនបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ ( មានវារៈ ៤ ) ។ សេចក្តីបង្រួញ ។ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ។ សេចក្តីបង្រួញ ។ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៦៣៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នឧបនិស្សយប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ៦៣៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសម-

នន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និង និស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បញ្ហាវារៈ ចប់

អជ្ឈត្តារម្មណត្តិកៈទី ២១ ចប់

# អដ្ឋកថា

## អជ្ឈត្តារម្មណត្តិកៈ

[ ៥៨៧-៦៣៤ ] ក្នុងអជ្ឈត្តារម្មណត្តិកៈនេះ ក៏មិនបានអជ្ឈត្តារម្មណបទ និងពហិទ្ធារម្មណបទ ដូចអជ្ឈត្តបទ និងពហិទ្ធាបទ ។ ក្នុងតិកៈនេះ ពាក្យដ៏សេស អនុលោមតាមបាលី ( នោះឯង ) ៗ។

**អដ្ឋកថាអជ្ឈត្តារម្មណត្តិកៈ ចប់**

# អភិធម្មបិដក

## សនិទស្សនសប្បដិឃត្តិកៈ

## បដិច្ចវារៈ

[ ៦៣៥ ] *អនិទស្សនសប្បដិឃធម៌ ( ធម៌ដែលមិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ) អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ អាស្រ័យនូវមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូតជាអនិទស្សនសប្បដិឃៈ ចក្ខាយតនៈ និងរសាយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈ ។ សនិទស្សនសប្បដិឃធម៌ ( ធម៌ដែលប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ) អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ រូបាយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈ ។ អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ អាបោធាតុ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវផោដ្ឋព្វាយតនៈ ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ ( ធម៌ដែលមិនប្រកបដោយការ*

ឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ) ក្តី អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ រូបាយតនៈ អាបោធាតុ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវផោដ្ឋព្វាយតនៈ ។ អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមហាភូត ២ ក្តី អាបោធាតុក្តី អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ ក្តី អាបោធាតុក្តី អាស្រ័យនូវមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ចក្ខាយតនៈ រសាយតនៈ អាបោធាតុ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវផោដ្ឋព្វាយតនៈ ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ រូបាយតនៈ ចក្ខាយតនៈ រសាយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈ ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប កដត្តារូប

និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ រូបាយតនៈ ចក្ខាយតនៈ សោយតនៈ អាបោធាតុ ឥន្ទ្រិយ និងកពឡិង្កា-រាហារ អាស្រ័យនូវផោដ្ឋព្វាយតនៈ ។

[ ៦៣៦ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិ-ឃធម៌ ... ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្ស-នអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្ប-ដិឃៈ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវខន្ធទាំងឡាយ ខន្ធទាំងឡាយ អាស្រ័យនូវវត្ថុ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវអាបោធាតុ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវអាបោធាតុ ។ សនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិ-ទស្សនអប្បដិឃធម៌ ... ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិ-ទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈ កដត្តារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សន-សប្បដិឃៈ អាស្រ័យនូវអាបោធាតុ រូបាយតនៈ អាស្រ័យនូវអាបោធាតុ ។ អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ... ព្រោះ

ហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈ កដត្តារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវអាបោធាតុ ចក្ខាយតនៈ និងសោយតនៈ អាស្រ័យនូវអាបោធាតុ ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ... ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវអាបោធាតុ រូបាយតនៈ ឥន្ទ្រិយ និងកពឡីង្ការាហារ អាស្រ័យនូវអាបោធាតុ ។ អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ... ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូប ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប កដត្តារូប

និងបាទារូប ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវអាបោធាតុ ចក្ខាយតនៈ រសាយតនៈ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវអាបោធាតុ ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈ កដត្តារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី អាស្រ័យនូវអាបោធាតុ រូបាយតនៈ ចក្ខាយតនៈ និងរសាយតនៈ អាស្រ័យនូវអាបោធាតុ ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវអាបោធាតុ

រូបាយតនៈ ចក្ខាយតនៈ សោយតនៈ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវអាបោធាតុ ។

[ ៦៣៧ ] សនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង នូវអនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង នូវពួកមហាភូតផង កដត្តារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនសប្បដិឃៈផង ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូតផង អាបោធាតុផង រូបាយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈផង អាបោធាតុផង ។ អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង កដត្តារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ មហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈផង អាបោធាតុផង មហាភូត ១ អាស្រ័យនូវមហាភូត ២ ផង អាបោធាតុផង ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យ

នូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈផង អាបោធាតុផង ចក្ខាយតនៈ និងសោយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈផង អាបោធាតុផង ។ អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង កដត្តារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈផង អាបោធាតុផង ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវផោដ្ឋព្វាយតនៈផង អាបោធាតុផង ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង កដត្តារូប ជាសនិទស្សនអប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈផង អាបោធាតុផង រូបាយតនៈ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវផោដ្ឋព្វាយតនៈផង

អាបោធាតុផង ។ អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង កដត្តារូប ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈផង អាបោធាតុផង ចក្ខាយតនៈ រសាយតនៈ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវផោដ្ឋព្វាយតនៈផង អាបោធាតុផង ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង កដត្តារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈផង អាបោធាតុផង រូបាយតនៈ ចក្ខាយតនៈ និងរសាយតនៈ

អាស្រ័យនូវផោដ្ឋព្វាយតនៈផង អាបោធាតុផង ។ សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង កដត្តារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនសប្បដិឃៈក្តី ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវពួកមហាភូតជាអនិទស្សនសប្បដិឃៈផង អាបោធាតុផង រូបាយតនៈ ចក្ខាយតនៈ រសាយតនៈ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវផោដ្ឋព្វាយតនៈផង អាបោធាតុផង ។

[ ៦៣៨ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ពួកខន្ធអាស្រ័យនូវវត្ថុ ។

[ ៦៣៩ ] អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃ-

ធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺមហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ អាស្រ័យនូវមហាភូត ២ ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ បញ្ហា ៧ ក្នុងអនិទស្សនសប្បដិឃមូលកៈ បណ្ឌិតគប្បីចែកដោយហេតុនេះចុះ បទទាំងឡាយខាងចុង មិនមានឡើយ ។

[ ៦៤០ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវអាបោធាតុ បញ្ហា ៧ ក្នុងអនិទស្សនអសប្បដិឃមូលកៈ បណ្ឌិតគប្បីចែក ដោយហេតុនេះចុះ បទបញ្ចប់មិនមានឡើយ ។

[ ៦៤១ ] សនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង ចិត្តសមុដ្ឋានរូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនអប្បដិឃៈផង អាបោធាតុផង បញ្ហា ៧ បណ្ឌិតគប្បីចែកដោយហេតុនេះចុះ ។

[ ៦៤២ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះអនន្តរប្បច្ច័យ និងសមនន្តរប្បច្ច័យ គឺដូចគ្នានឹង

អារម្មណប្បច្ច័យដែរ ។

[ ៦៤៣ ] អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺមហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ អាស្រ័យនូវមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ចក្ខាយតនៈ អាស្រ័យផោដ្ឋព្វាយតនៈ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ២ អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ បញ្ហា ៧ ជាអនិទស្សនសប្បដិឃមូលកៈ បណ្ឌិតគប្បីចែកដោយហេតុនេះចុះ ។

[ ៦៤៤ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូប ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវអាបោធាតុ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវអាបោធាតុ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវអាបោធាតុ របស់ពួកអសញ្ញសត្វ បញ្ហា ៧ ក្នុងអនិទស្សនអប្បដិឃៈ បណ្ឌិតគប្បីធ្វើ

តាមហេតុនេះចុះ ។

[ ៦៤៥ ] សនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង កដត្តារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈផង ពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈផង អាបោធាតុផង រូបាយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈផង នូវអាបោធាតុផង ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ របស់ពួកអសញ្ញសត្វផង នូវអាបោធាតុផង បញ្ហា ៧ បណ្ឌិតគប្បីចែកតាមហេតុនេះចុះ ។

[ ៦៤៦ ] អនិទស្សនសប្បដិឃធម៌ ( ធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ) អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺមហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ អាស្រ័យនូវមហាភូត ២ ។ អនិទស្សនអប្បដិឃធម៌ ( ធម៌មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ) អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះ

អញ្ញមញ្ញប្បច្ច័យ គឺអាបោធាតុ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនៈ-សប្បដិឃៈ ។ អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី អា-ស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺមហាភូត ២ ក្តី អាបោធាតុក្តី អាស្រ័យនូវមហាភូត ១ ជាអនិទស្សនៈ-សប្បដិឃៈ មហាភូត ១ ក្តី អាបោធាតុក្តី អាស្រ័យមហាភូត ២ ។

[ ៦៤៧ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃ-ធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ នូវខន្ធ ២ ... ខន្ធ ៣ ក្តី វត្ថុក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ ។ អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺពួកមហាភូត ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវអាបោធាតុ ។

[ ៦៤៨ ] អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃ-ធម៌ផង នូវអនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺមហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈផង នូវអាបោធាតុផង មហាភូត ១ អាស្រ័យនូវមហាភូត ២ ផង អាបោធាតុផង ។

[ ៦៤៩ ] អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃ-ធម៌ ទើបកើតឡើង ព្រោះនិស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជា-

តប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

[ ៦៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ២១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ២១ ក្នុងវិបាកប្បច្ច័យ និងអាហារប្បច្ច័យ មានវារៈ ២១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២១ ក្នុងឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវារៈ ២១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ២១ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២១ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៦៥១ ] អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ អាស្រ័យនូវមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អា-

ស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ចក្ខាយតនៈ និងសោយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ របស់ពួកអសញ្ញសត្វ មហាភូត ១ អាស្រ័យនូវមហាភូត ២ ប្រស្នាទាំង ៧ ក្នុងអនិទស្សនសប្បដិឃមូលកៈ បណ្ឌិតគប្បីចែកតាមហេតុនេះចុះ ។

[ ៦៥២ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាអនិទស្សនអប្បដិឃៈ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូប ជាអនិទស្សនអប្បដិឃៈក្តី អាស្រ័យនូវខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធ អាស្រ័យនូវវត្ថុ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវអាបោធាតុ ឥន្ទ្រិយ កពឡិង្ការាហារ អាស្រ័យនូវអាបោធាតុ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូប និងឧបាទារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវអាបោធាតុរបស់ពួកអសញ្ញសត្វ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ប្រស្នាទាំង ៧ ជាអនិទស្សនអប្បដិឃមូលកៈ បណ្ឌិតគប្បីចែកតាមហេតុនេះចុះ ។

[ ៦៥៣ ] សនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃ-

ធម៌ផង នូវអនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកអហេតុកក្ខន្ធ ជាអនិទស្សនអប្បដិឃៈផង នូវពួកមហាភូតផង កដត្តារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈផង នូវអាបោធាតុផង រូបាយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈផង នូវអាបោធាតុផង ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ របស់ពួកអសញ្ញសត្វផង អាបោធាតុផង ប្រស្នាទាំង ៧ ដែលបណ្ឌិតអ្នកមិនកាន់ច្រឡំ គប្បីឲ្យពិស្តារតាមហេតុនេះចុះ ។

[ ៦៥៤ ] អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺមហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ អាស្រ័យនូវមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ចក្ខាយតនៈ និងរសាយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈរបស់ពួកអសញ្ញសត្វ មហាភូត ១ អាស្រ័យនូវមហាភូត ២ ប្រស្នាទាំង ៧ ជា

អនិទស្សនសប្បដិឃមូលក: បណ្ឌិតគប្បីឲ្យពិស្តារ តាមហេតុនេះចុះ ។

[ ៦៥៥ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃ-ធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាអនិ-ទស្សនអប្បដិឃ: អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃ: កដត្តារូប ជាអនិទស្សនអប្បដិឃ: អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃ: ក្នុងខណៈនៃបដិសន្ធិ វត្ថុ អាស្រ័យនូវពួកខន្ធ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនអប្បដិឃ: អាស្រ័យនូវអាបោធាតុ ឥន្ទ្រិយ និងកពឡិង្ការាហារ អាស្រ័យនូវអាបោធាតុ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូប ឧបាទារូប ជាអនិទស្សនអប្បដិឃ: អាស្រ័យនូវអាបោធាតុរបស់ពួកអសញ្ញសត្វ ប្រស្នាទាំង ៧ ក្នុងអនិទស្សនអប្បដិឃ-មូលក: បណ្ឌិតគប្បីឲ្យពិស្តារតាមហេតុនេះចុះ ។

[ ៦៥៦ ] សនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិ-ឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃ: អាស្រ័យនូវពួកខន្ធ ជាអនិ-ទស្សនអប្បដិឃ:ផង នូវពួកមហាភូតផង កដត្តារូប ជាសនិទស្សនសប្ប-ដិឃ: អាស្រ័យនូវពួកខន្ធ ជាអនិទស្សនអប្បដិឃ: ក្នុងខណៈនៃបដិសន្ធិផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូបជាសនិទស្សន-សប្បដិឃ: អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃ:ផង នូវអាបោធាតុផង រូបាយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈផង នូវអាបោធាតុ

ផង ... ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ របស់ពួកអសញ្ញសត្តផង នូវអាបោធាតុផង ក្នុងការជាប់ទាក់ទង បណ្ឌិតគប្បីចែកប្រស្នាទាំង ៧ តាមហេតុនេះចុះ ។

[ ៦៥៧ ] អនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺដូចគ្នានឹងសហជាតប្បច្ច័យដែរ ។ ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ និងនអញ្ញមញ្ញប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ចក្ខាយតនៈ និងសោយតនៈ អាស្រ័យនូវផោដ្ឋព្វាយតនៈ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូប និងឧបាទារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវពួកមហាភូត របស់ពួកអសញ្ញសត្វ ប្រស្នា ២១ បណ្ឌិតគប្បីចែកតាមហេតុនេះចុះ ។ ព្រោះនឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ ។ ព្រោះនកម្មប្បច្ច័យ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ២ អាស្រ័យនូវមហាភូត ១ ជាអនិទស្សនសប្បដិឃៈ មហាភូត ១ អាស្រ័យនូវមហាភូត ២ ឧបាទារូប ជាអនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ប្រស្នា ២១ បណ្ឌិតចែកកម្មប្បច្ច័យ ហើយគប្បីធ្វើតាមនកម្មប្បច្ច័យផងចុះ ។ ព្រោះនវិបាកប្បច្ច័យ បដិសន្ធិក្តី កដត្តារូបក្តី មិនមានទេ ( បដិសន្ធិ និងកដត្តារូប ) បណ្ឌិតគប្បី

ធ្វើក្នុងបញ្ចវោការចុះ ។ ព្រោះនអាហារប្បច្ច័យ គឺពាហិរ ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ... ប្រស្នា ២១ បណ្ឌិតគប្បីចែកតាមហេតុនេះចុះ ។ ព្រោះនឥន្ទ្រិយប្បច្ច័យ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ១ ជាអនិទស្សនសប្បដិឃៈ ... រូបជីវិតិន្ទ្រិយ អាស្រ័យនូវពួកមហាភូតរបស់ពួកអសញ្ញសត្វ ។ សេចក្ដីបង្រួញ ។ ប្រស្នាទាំងអស់ បណ្ឌិតគប្បីចែកផងចុះ ។ ព្រោះនឈានប្បច្ច័យ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ១ របស់ពួកអសញ្ញសត្វ ។ សេចក្ដីបង្រួញ ។ ប្រស្នាទាំង ៧ បណ្ឌិតគប្បីចែកផងចុះ ។

[ ៦៥៨ ] អនិទស្សនអប្បដិឃធម៌ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ប្រកបដោយបញ្ចវិញ្ញាណ នូវខន្ធ ២ ... ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កឡត្តារូប និងឧបាទារូប ជាអនិទស្សនអប្បដិឃៈ អាស្រ័យនូវអាបោធាតុ របស់ពួកអសញ្ញសត្វ ប្រស្នាទាំង ៧ បណ្ឌិតគប្បីចែកយ៉ាងនេះចុះ ។

[ ៦៥៩ ] សនិទស្សនសប្បដិឃធម៌ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ផង នូវអនិទស្សនអប្បដិឃធម៌ផង ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កឡត្តារូប និងឧបាទារូប ជាសនិទស្សនសប្បដិឃៈ អាស្រ័យនូវពួកមហាភូត ជាអនិទស្សនសប្បដិឃៈ របស់ពួកអសញ្ញសត្វផង នូវអាបោធាតុផង ប្រស្នាទាំង ៧

បណ្ឌិតគប្បីចែកយ៉ាងនេះចុះ ។ ព្រោះនមគ្គប្បច្ច័យ បណ្ឌិតគប្បីធ្វើឲ្យគ្រប់គ្រាន់ដូចនហេតុប្បច្ច័យដែរ មោហៈមិនមានទេ ។ ព្រោះនសម្បយុត្តប្បច្ច័យ និងនវិប្បយុត្តប្បច្ច័យ គ្រប់គ្រាន់ហើយ ។ ព្រោះនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

[ ៦៦០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២១ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ មានវារៈ ២១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### បច្ចនីយៈ ចប់

[ ៦៦១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២១ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២១ ។ សេចក្តីបង្រួញ ។ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### អនុលោមបច្ចនីយៈ ចប់

[ ៦៦២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ២១ ។ សេចក្តីបង្រួញ ។ ក្នុងឈានប្បច្ច័យ

មានវារៈ ២១ ក្នុងមគ្គប្បច្ច័យ មានវារៈ ២១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ២១ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២១ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បដិច្ចវារៈ ចប់

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។ សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើក្នុងអរូបផងចុះ ។

## បញ្ហាវារៈ

[ ៦៦៣ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈផង ដោយហេតុប្បច្ច័យ ពួកហេតុ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូប ជាអនិទស្សនអប្បដិឃៈផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។

[ ៦៦៤ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ ដោយហេតុប្បច្ច័យ ក្នុងខណៈ

នៃបដិសន្ធិ ... ប្រស្នាទាំង ៧ ក្នុងអនិទស្សនអប្បដិឃមូលកៈ បណ្ឌិតគប្បី ចែកតាមហេតុនេះចុះ ។

[ ៦៦៥ ] សនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឃើញច្បាស់នូវរូបទាំងឡាយ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន ត្រេកអរ រីករាយ រាគៈប្រារព្ធនូវរូបនោះ ទើបកើតឡើង ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចៈ ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកខន្ធជាសនិទស្សនសប្បដិឃៈ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦៦៦ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអារម្មណប្បច្ច័យ គឺនូវចក្ខុ ... នូវកាយ ពួកសំឡេង ពួកក្លិន ពួករស ... នូវពួកផោដ្ឋព្វៈ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង បុគ្គល ឮនូវសំឡេងដោយទិព្វសោតធាតុ សទ្ទាយតនៈ ( ជាបច្ច័យ ) នៃសោតវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពួកខន្ធជាអនិទស្សនសប្បដិឃៈ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦៦៧ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន សមាទាននូវសីល ធ្វើនូវ

ឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ពិចារណានូវពួកកុសលដែលធ្លាប់សន្សំហើយក្នុងកាលមុន ចេញអំពីឈាន ... ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈពិចារណានូវពួកកិលេសដែលលះបង់ហើយ ពិចារណានូវពួកកិលេសដែលសង្កត់សង្កិនហើយ នូវពួកកិលេសដែលធ្លាប់សន្សំហើយក្នុងកាលមុន ... នូវវត្ថុ ... នូវឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ អាបោធាតុ កពឡិង្ការាហារ ... នូវពួកខន្ធជាអនិទស្សនអប្បដិឃៈ ថាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយចិត្ត ជាអនិទស្សនអប្បដិឃៈ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ជាបច្ច័យនៃវិញ្ញាណញ្ចាយតនៈ ដោយអារម្មណប្បច្ច័យ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ពួកខន្ធជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦៦៨ ] សនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវរូបឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវរូបនោះ ឲ្យជាទីគោរព ... ទិដ្ឋិកើតឡើង ។

[ ៦៦៩ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ ( បុគ្គល ) នូវចក្ខុ ... នូវកាយ ពួកសំឡេង ពួកក្លិន ... ធ្វើនូវពួកផោដ្ឋព្វៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវផោដ្ឋព្វៈនោះ ឲ្យជាទីគោរព ... ទិដ្ឋិកើតឡើង ។

[ ៦៧០ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ... ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ... ចេញអំពីឈាន ... ពួកព្រះអរិយៈ ចេញអំពីមគ្គ ... ចេញអំពីផល ... ធ្វើនូវផល ឲ្យជាទីគោរព ... ធ្វើនូវព្រះនិព្វានឲ្យជាទីគោរព ... ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ ... នូវវត្ថុ ... នូវឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ អាបោធាតុ កពឡិង្ការាហារ ... ធ្វើនូវពួកខន្ធជាអនិទស្សនអប្បដិឃៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ... ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈផង ដោយអធិបតិប្បច្ច័យ ។

[ ៦៧១ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ ជា

អនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនសប្បដិឃៈ ដោយអធិបតិប្បច្ច័យ ប្រស្នាទាំង ៧ ក្នុងអនិទស្សនអប្បដិឃមូលកៈ ឯអធិបតិធម៌ បណ្ឌិតគប្បីចែកតាមការសង្គ្រោះនូវរូប ៣ ប្រការទៀតចុះ ។

[ ៦៧២ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធ ជាអនិទស្សនអប្បដិឃធម៌មុនៗ ជាបច្ច័យនៃពួកខន្ធ ជាអនិទស្សនអប្បដិឃៈក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ( ជាបច្ច័យ ) នៃមគ្គ មគ្គ ( ជាបច្ច័យ ) នៃផល ផល ( ជាបច្ច័យ ) នៃផល អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ៦៧៣ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយសមនន្តរប្បច្ច័យ គឺដូចគ្នានឹងអនន្តរប្បច្ច័យដែរ ។

[ ៦៧៤ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនសប្បដិឃធម៌ ដោយសហជាតប្បច្ច័យ គឺដូចគ្នាដឹងបដិច្ចវារៈដែរ ។ តែបណ្ឌិតត្រូវធ្វើឲ្យមានរបៀបរៀបរយផងចុះ ។ ក្នុងអញ្ញមញ្ញប្បច្ច័យ ដូចអញ្ញមញ្ញប្បច្ច័យក្នុងបដិច្ចវារៈ ។ ក្នុងនិស្សយប្បច្ច័យ ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦៧៥ ] សនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ

និងបកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺបុគ្គល កាលប្រាថ្នានូវវណ្ណ-សម្បទា ឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ... វណ្ណសម្បទា ជាបច្ច័យនៃសទ្ធា បញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៦៧៦ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃ-ធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូប-និស្ស័យ និងបកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺបុគ្គលកាលប្រាថ្នានូវចក្ខុសម្បទា ... នូវកាយសម្បទា ... នូវសទ្ទសម្បទា ... កាលប្រាថ្នានូវផោដ្ឋព្វ-សម្បទា ឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ... នូវរដូវ ... អាស្រ័យនូវសេនាសនៈហើយឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ... នូវឈាន ... នូវវិបស្សនា ... នូវមគ្គ ... នូវអភិញ្ញា ... នូវសមាបត្តិ ... សម្លាប់នូវសត្វបំបែកនូវសង្ឃ ចក្ខុសម្បទា ... ផោដ្ឋព្វសម្បទា ... រដូវ ... សេនាសនៈ ជាបច្ច័យនៃសទ្ធា បញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៦៧៧ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនសប្បដិឃ-ធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូប-និស្ស័យ និងបកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធាហើយឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ... នូវឈាន ... នូវសមាបត្តិ ... ដំឡើងមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ... នូវបញ្ញា រាគៈ សេចក្តីប្រាថ្នា

កាយិកសុខ កាយិកទុក្ខ ... អាស្រ័យនូវភោជន ហើយឲ្យនូវទាន ... បំបែកនូវសង្ឃ ពួកខន្ធជាអនិទស្សនអប្បដិឃៈ ... សទ្ធា បញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ ... ភោជន ( ជាបច្ច័យ ) នៃសទ្ធា បញ្ញា ។ សេចក្តីបង្រួញ ។ ជាបច្ច័យនៃមគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៦៧៨ ] សនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយបុរេជាតប្បច្ច័យ ។ បានដល់ អារម្មណបុរេជាត គឺដោយទិព្វចក្ខុ ... រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។

[ ៦៧៩ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ... នូវកាយ ... នូវពួកសំឡេង ... នូវពួកផោដ្ឋព្វៈ ... ជាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលឮនូវសំឡេងដោយទិព្វសោតធាតុ សទ្ទាយតនៈ ( ជាបច្ច័យ ) នៃសោតវិញ្ញាណ ។បេ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។

[ ៦៨០ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវវត្ថុ ... នូវឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ អាបោធាតុ

កពឡិង្ការាហារ ជាមិនទៀង ... ទោមនស្សកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ដោយបុរេជាតប្បច្ច័យ ។

[ ៦៨១ ] សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត គឺរូបាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកខន្ធជាអនិទស្សនអប្បដិឃៈ ដោយបុរេជាតប្បច្ច័យ ។

[ ៦៨២ ] អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត គឺចក្ខាយតនៈក្តី វត្ថុក្តី ... ផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ដោយបុរេជាតប្បច្ច័យ ។

[ ៦៨៣ ] សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត គឺរូបាយតនៈក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។

[ ៦៨៤ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ បានដល់ បច្ឆាជាត គឺពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃកាយនេះ ជាអនិទស្សនអប្បដិឃៈ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៦៨៥ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃ-

ធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ បានដល់ បច្ឆាជាត គឺពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃកាយនេះ ជាសនិទស្សនសប្បដិឃៈ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ប្រស្នាទាំង ៧ បណ្ឌិតគប្បីចែកយ៉ាងនេះចុះ តែការសង្គ្រោះនូវរូប មាន ៣ យ៉ាងដែរ ។

[ ៦៨៦ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអាសេវនប្បច្ច័យ គឺពួកខន្ធ ជាអនិទស្សនអប្បដិឃៈមុនៗ ជាបច្ច័យនៃពួកខន្ធ ជាអនិទស្សនអប្បដិឃៈក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៦៨៧ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនា ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូប ជាអនិទស្សនអប្បដិឃៈផង ដោយកម្មប្បច្ច័យ ។

[ ៦៨៨ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាសនិ-

ទស្សនសប្បដិឃៈ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនា ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកកដត្តារូប ជាសនិទស្សនសប្បដិឃៈ ដោយកម្មប្បច្ច័យ ប្រស្នាទាំង ៧ ដែលជាសហជាត និងនានាខណិកៈ បណ្ឌិតគប្បីចែកតាមហេតុយ៉ាងនេះចុះ តែការសង្គ្រោះនូវរូប មាន ៣ យ៉ាងដែរ ។

[ ៦៨៩ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈផង ដោយវិបាកប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកកដត្តារូប ជាអនិទស្សនអប្បដិឃៈផង ដោយវិបាកប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ។

[ ៦៩០ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយវិបាកប្បច្ច័យ គឺពួកវិបាកក្ខន្ធ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ ដោយវិបាកប្បច្ច័យ ពួកខន្ធជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកកដត្តារូប ជាសនិទស្សនសប្បដិឃៈ ដោយវិបាកប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ឯបញ្ហាទាំង ៧ និងបវត្តិប្បដិសន្ធិ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។

[ ៦៩១ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអាហារប្បច្ច័យ គឺពួកអាហារ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈផង

ដោយអាហារប្បច្ច័យ ពួកអាហារ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូប ជាអនិទស្សនអប្បដិឃៈផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ជាអនិទស្សនអប្បដិឃៈ ដោយអាហារប្បច្ច័យ ។

[ ៦៩២ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយអាហារប្បច្ច័យ គឺពួកអាហារជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ ដោយអាហារប្បច្ច័យ ពួកអាហារ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកកដត្តារូប ជាសនិទស្សនសប្បដិឃៈ ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ជាសនិទស្សនសប្បដិឃៈ ដោយអាហារប្បច្ច័យ ប្រស្នាទាំង ៧ ក្តី បវត្តិប្បដិសន្ធិក្តី បណ្ឌិតគប្បីចែកយ៉ាងនេះចុះ ឯកពឡិង្ការាហារ បណ្ឌិតគប្បីធ្វើឲ្យដូចក្នុងប្រស្នាទាំង ៧ ដែរ ។

[ ៦៩៣ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយិន្ទ្រិយ ជាបច្ច័យនៃកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៦៩៤ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈផង ដោយឥន្ទ្រិយប្បច្ច័យ ពួកឥន្ទ្រិយ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួក

សម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូប ជាអនិទស្សនសប្បដិឃៈផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ជាអនិទស្សនអប្បដិឃៈ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៦៩៥ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ ដោយឥន្ទ្រិយប្បច្ច័យ ពួកឥន្ទ្រិយ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកកដត្តារូប ជាសនិទស្សនសប្បដិឃៈ ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ជាសនិទស្សនសប្បដិឃៈ ដោយឥន្ទ្រិយប្បច្ច័យ បវត្តិប្បដិសន្ធិក្តី ប្រស្នាទាំង ៧ ក្តី បណ្ឌិត ( គប្បីចែក ) យ៉ាងនេះចុះ ឯរូបជីវិតិន្ទ្រិយ បណ្ឌិតគប្បីចែកក្នុងទីបំផុត ។

[ ៦៩៦ ] អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយក្តី ចក្ខុវិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។ សេចក្តីបង្រួញ ។ កាយិន្ទ្រិយក្តី កាយវិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៦៩៧ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃខន្ធ ៣ ដោយ

សម្បយុត្តប្បច្ច័យ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៦៩៨ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៦៩៩ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈ ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកកដត្តារូប ជាអនិទស្សនអប្បដិឃៈ ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃកាយនេះ ជាអនិទស្សនអប្បដិឃៈ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៧០០ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធ ជាអនិទស្សនអប្បដិឃៈ

ជាបច្ច័យនៃពួកកដត្តារូប ជាសនិទស្សនសប្បដិឃៈ ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។ ឯបច្ឆាជាត គឺពួកខន្ធជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃកាយនេះ ជាសនិទស្សនសប្បដិឃៈ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ប្រស្នា ៥ ដ៏សេស បណ្ឌិតគប្បីឲ្យពិស្តារដូចសហជាត និងបច្ឆាជាតយ៉ាងនេះចុះ ។

[ ៧០១ ] សនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនសប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺនូវរូបទាំងឡាយថាមិនទៀង ... ទោមនស្សកើតឡើង នូវរូបដោយទិព្វចក្ខុ ... រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។

[ ៧០២ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនសប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ គឺមហាភូត ១ ជាអនិទស្សនសប្បដិឃៈ ជាបច្ច័យនៃមហាភូត ២ ដោយអត្ថិប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ១ ដោយអត្ថិប្បច្ច័យ ពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ពួកកដត្តារូប និងពួកឧបាទារូប ជាអនិទស្សនសប្បដិឃៈ ដោយអត្ថិប្បច្ច័យ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃចក្ខាយតនៈ និងរសាយតនៈ ដោយអត្ថិប្បច្ច័យ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន មហាភូត ១ ជាបច្ច័យនៃមហាភូត ២ ដោយអត្ថិប្បច្ច័យ មហាភូត ២ ជាបច្ច័យនៃមហាភូត ១ ដោយអត្ថិប្បច្ច័យ ពួកឧតុសមុដ្ឋាន និងពួកមហាភូត ជាបច្ច័យនៃពួកឧបាទារូប ជាអនិទស្សនសប្បដិឃៈ ដោយអត្ថិប្បច្ច័យ មហាភូត ១

ជាអនិទស្សនសប្បដិឃៈ របស់ពួកអសញ្ញសត្វ ជាបច្ច័យនៃមហាភូត ២ ដោយអត្ថិប្បច្ច័យ មហាភូត ២ ... ។

[ ៧០៣ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ គឺដូចក្នុងនិស្សយប្បច្ច័យ ក្នុងបដិច្ចវារៈដែរ ។

[ ៧០៤ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺពួកមហាភូត ជាអនិទស្សនសប្បដិឃៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ពួកកដត្តារូប និងពួកឧបាទារូប ជាអនិទស្សនអប្បដិឃៈ ដោយអត្ថិប្បច្ច័យ បណ្ឌិតគប្បីឲ្យពិស្តារ រហូតដល់ពួកអសញ្ញសត្វផងចុះ ។ បុរេជាត គឺនូវចក្ខុ ... នូវកាយ ... នូវពួកសំឡេង ... នូវពួកផោដ្ឋព្វៈ ជាមិនទៀង ... ទោមនស្ស កើតឡើង ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ប្រស្នា ៤ ដ៏សេស បណ្ឌិតគប្បីឲ្យពិស្តារ ដូចគ្នានឹងសហជាតប្បច្ច័យ ក្នុងបដិច្ចវារៈដែរ មិនមានការធ្វើឲ្យផ្សេងៗ គ្នាឡើយ ។

[ ៧០៥ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... អាបោធាតុ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ពួកកដត្តារូប និងអា-

បោធាតុ ពួកឧបាទារូប ជាអនិទស្សនអប្បដិឃៈ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃឥន្ទ្រិយផង នៃកពឡិង្ការាហារផង ដោយអត្ថិប្បច្ច័យ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... អាបោធាតុ របស់ពួកអសញ្ញសត្វ ( ជាបច្ច័យ ) នៃពួកកដត្តារូប ជាអនិទស្សនអប្បដិឃៈ ។ បុរេជាត គឺនូវវត្ថុ ... នូវឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ អាបោធាតុ ... នូវកពឡិង្ការាហារ ជាមិនទៀង ... ទោមនស្សកើតឡើង វត្ថុជាបច្ច័យនៃពួកខន្ធជាអនិទស្សនអប្បដិឃៈ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធជាអនិទស្សនអប្បដិឃៈ ជាបច្ច័យនៃកាយនេះ ជាអនិទស្សនអប្បដិឃៈដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ជាអនិទស្សនអប្បដិឃៈ ដោយអត្ថិប្បច្ច័យ ។ ឯរូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ជាអនិទស្សនអប្បដិឃៈ ដោយអត្ថិប្បច្ច័យ ប្រស្នា ៦ ដ៏សេស បណ្ឌិតគប្បីចែកយ៉ាងនេះចុះ ឯសហជាតប្បច្ច័យក្តី បច្ឆាជាតប្បច្ច័យក្តី អាហារប្បច្ច័យក្តី ឥន្ទ្រិយប្បច្ច័យក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះដែរ ។

[ ៧០៦ ] សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺរូបាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ដោយអត្ថិប្បច្ច័យ ។

[ ៧០៧ ] អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ គឺពួកខន្ធ ជាអនិ-

ទស្សនេអប្បដិឃៈក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនសប្បដិឃៈ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... សេចក្តីបង្រួញ ។ ( ឯពួកខន្ធ ) របស់ពួកអសញ្ញសត្វ បណ្ឌិតគប្បីធ្វើផងចុះ ។

[ ៧០៨ ] អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី នៃអនិទស្សនអប្បដិឃធម៌ ... ។ សេចក្តីបង្រួញ ។

[ ៧០៩ ] អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺពួកខន្ធជាអនិទស្សនអប្បដិឃៈក្តី ពួកមហាភូតក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនអប្បដិឃៈ ( ខន្ធទាំងនោះ ) បណ្ឌិតគប្បីធ្វើឲ្យរហូតដល់ពួកអសញ្ញសត្វផងចុះ ។ ឯបុរេជាត គឺចក្ខាយតនៈក្តី វត្ថុក្តី ... ផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកខន្ធ ជាអនិទស្សនអប្បដិឃៈ ដោយអត្ថិប្បច្ច័យ ប្រស្នាដ៏សេស បណ្ឌិតគប្បីចែកផងចុះ ។

[ ៧១០ ] សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺរូបាយតនៈក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។

[ ៧១១ ] សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត គឺរូបាយតនៈក្តី ចក្ខាយតនៈក្តី ចក្ខុវិញ្ញាណ

ក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយចក្ខុវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។

នត្ថិប្បច្ច័យ និងវិគតប្បច្ច័យដូចគ្នានឹងអនន្តរប្បច្ច័យ ។ អវិគតប្បច្ច័យដូច គ្នានឹងអត្ថិប្បច្ច័យដែរ ។

[ ៧១២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ២១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៧ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៨ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៥ ។

[ ៧១៣ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ

មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៧១៤ ] ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យនិងអវិគតប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ។ ពាក្យថា សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។

ភារៈនៃការរាប់ទាំងអស់ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៧១៥ ] សនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៧១៦ ] អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនសប្បដិឃធម៌ ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សនអប្បដិឃធម៌ផង ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ ជាបច្ច័យ នៃសនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សនសប្បដិឃធម៌ផង ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សនអប្បដិឃធម៌ផង ដោយសហជាតប្បច្ច័យ ។

[ ៧១៧ ] អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនអប្បដិឃ-ធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ។ អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆា-ជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្ស-នសប្បដិឃធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្ប-ដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហា-រប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ដោយសហជា-តប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អនិទស្សន-អប្បដិឃធម៌ ជាបច្ច័យនៃអនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិ-ឃធម៌ផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យ

ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អនិទស្សនអប្បដិ-
ឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ផង អនិទស្សនសប្បដិឃធម៌
ផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ
ដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិ-
យប្បច្ច័យ ។ អនិទស្សនអប្បដិឃធម៌ ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌
ផង អនិទស្សនសប្បដិឃធម៌ផង អនិទស្សនអប្បដិឃធម៌ផង ដោយសហ-
ជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ
ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៧១៨ ] សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ( ជា
បច្ច័យ ) នៃអនិទស្សនអប្បដិឃធម៌ ... បានដល់ បុរេជាត ។

[ ៧១៩ ] អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជា
បច្ច័យនៃសនិទស្សនសប្បដិឃធម៌ ដោយសហជាតប្បច្ច័យ ។ អនិទស្សន-
សប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនសប្បដិ-
ឃធម៌ ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សន-
អប្បដិឃធម៌ក្តី ( ជាបច្ច័យ ) នៃអនិទស្សនអប្បដិឃធម៌ ... បានដល់
សហជាត និងបុរេជាត ។ អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃ-
ធម៌ក្តី ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សនអប្បដិឃធម៌
ផង ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សន-
អប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សន-

អប្បដិឃធម៌ផង ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សនសប្បដិឃធម៌ផង ដោយសហជាតប្បច្ច័យ ។ អនិទស្សនសប្ប-ដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃសនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សនសប្បដិឃធម៌ផង នៃអនិទស្សនអប្បដិឃធម៌ផង ដោយសហជាតប្បច្ច័យ ។

[ ៧២០ ] សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ... បានដល់ បុរេជាត ។

[ ៧២១ ] សនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនសប្បដិឃធម៌ក្តី អនិទស្សនអប្បដិឃធម៌ក្តី ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៧២២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២៥ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១២ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២៤ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២៥ ក្នុងនបុរេជាតប្បច្ច័យ មាន វារៈ ២២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ២៥ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ២៥ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ២៣

ក្នុងនឈានប្បច្ច័យ មានវារៈ ២៥ ក្នុងនមគ្គប្បច្ច័យ មានវារៈ ២៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២២ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២៥ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧២៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២២ ព្រោះនហេតុប្បច្ច័យ ដូចក្នុងជំណើរទី ១ ដែរ ។ ... ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧២៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២២ ព្រោះហេតុប្បច្ច័យ និងនអារម្មណប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២២ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២២ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្ស័យ មានវារៈ ២១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២២ ។ សេចក្តីបង្រួញ ។ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២២ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ២២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២២ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៧២៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុង

នសមនន្តរបច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញបច្ច័យ មានវារៈ ៧ ក្នុងនឧបនិស្សយបច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតបច្ច័យ មានវារៈ ៧ ក្នុងបច្ឆាជាតបច្ច័យ មានវារៈ ៧ ។ សេចក្តីបន្រ្ទញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែ មានវារៈ ៧ ក្នុងនសម្បយុត្តបច្ច័យ មានវារៈ ៧ ក្នុងនវិប្បយុត្តបច្ច័យ មានវារៈ ១ ក្នុងនោនត្ថិបច្ច័យ មានវារៈ ៧ ក្នុងនោវិគតបច្ច័យ មានវារៈ ៧ ។

[ ៧២៦ ] ក្នុងនអារម្មណបច្ច័យ មានវារៈ ៧ ព្រោះហេតុបច្ច័យ សហជាតបច្ច័យ និស្សយបច្ច័យ អត្ថិបច្ច័យ និងអវិគតបច្ច័យ ... ក្នុងនអនន្តរបច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរបច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញបច្ច័យ មានវារៈ ៧ ។ សេចក្តីបន្រ្ទញក្នុងទីនេះ ។ ក្នុងនសម្បយុត្តបច្ច័យ មានវារៈ ៧ ក្នុងនវិប្បយុត្តបច្ច័យ មានវារៈ ១ ក្នុងនោនត្ថិបច្ច័យ មានវារៈ ៧ ក្នុងនោវិគតបច្ច័យ មានវារៈ ៧ ។

[ ៧២៧ ] ក្នុងនអារម្មណបច្ច័យ មានវារៈ ១ ព្រោះហេតុបច្ច័យ សហជាតបច្ច័យ អញ្ញមញ្ញបច្ច័យ និស្សយបច្ច័យ អត្ថិបច្ច័យ និងអវិគតបច្ច័យ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ... ក្នុងនោវិគតបច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមបច្ចនីយៈ ចប់

[ ៤២៨ ] ក្នុងអារម្មណបច្ច័យ មានវារៈ ៣ ព្រោះនហេតុបច្ច័យ ... ក្នុងអធិបតិបច្ច័យ មានវារៈ ៩ ក្នុងអនន្តរបច្ច័យ មានវារៈ ១ ក្នុង

សមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ២១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៧ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៨ ក្នុងអត្ថិប្បច្ច័យ មានវារៈ ២៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៥ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បញ្ហាវារៈ ចប់

សនិទស្សនសប្បដិឃត្តិកៈទី ២២ ចប់

អនុលោមត្តិកបដ្ឋាន ខាងចុងបំផុត ចប់

# អដ្ឋកថា

## សនិទស្សនត្តិកៈ

[ ៦៣៥-៤២៨ ] ក្នុងសនិទស្សនត្តិកៈ អ្នកសិក្សាគប្បីកាន់យកអត្ថ ដោយអំណាចនៃបាលី ដែលដូចគ្នាក្នុងតិកៈនេះ អ្នកសិក្សាគប្បីជ្រាបវិធីរាប់ ដោយសង្ខេបវារៈទាំងឡាយ ដែលមកហើយក្នុងព្រះបាលី ប្រៀបធៀបក្នុង បច្ច័យទាំងឡាយ ដែលប្រៀបធៀបគ្នាបាន ដោយន័យដែលបានពោលហើយ ខាងដើមនោះឯង ។ល។

**អដ្ឋកថាសនិទស្សនត្តិកៈ ចប់**

**ពណ៌នាតិកប្បដ្ឋានក្នុងធម្មានុលោម ចប់**

# អភិធម្មបិដក

# បដ្ឋាន សត្តមភាគ

## អនុលោមទុកប្បដ្ឋាន ខាងដើម

*សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## ហេតុទុកៈ

## បដិច្ចវារៈ

[ ១ ] *ធម៌ជាហេតុ អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអទោសៈ អមោហៈ អាស្រ័យនូវអលោភៈ អលោភៈ អមោហៈអាស្រ័យនូវអទោសៈ អលោភៈ អទោសៈអាស្រ័យនូវអមោហៈ មោហៈអាស្រ័យនូវលោភៈ លោភៈអាស្រ័យនូវមោហៈ មោហៈអាស្រ័យនូវទោសៈ ទោសៈអាស្រ័យនូវមោហៈ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌មិនមែនជាហេតុអាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវធម៌ជាហេតុ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ជាហេតុក្តី ធម៌មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអទោសៈក្តី អមោហៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអលោភៈ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវលោភៈ ៗបេៗ ក្នុងខណៈនៃបដិសន្ធិ ៗបេៗ ធម៌មិនមែនជា*

ហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុ ។បេ។ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ។បេ។ ធម៌ជាហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកហេតុ អាស្រ័យនូវពួកខន្ធមិនមែនជាហេតុ ក្នុងខណៈនៃបដិសន្ធិ ពួកហេតុអាស្រ័យនូវវត្ថុ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី អា-ស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ហេតុក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុ ។បេ។ ខន្ធ ២ ក្តី ហេតុក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ ធម៌ជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអទោសៈក្តី អមោហៈក្តី អាស្រ័យនូវអលោភៈផង ពួកសម្បយុត្តកក្ខន្ធផង ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈអាស្រ័យនូវលោភៈផង ពួកសម្បយុត្តកក្ខន្ធផង មោហៈអាស្រ័យនូវទោសៈផង ពួកសម្បយុត្តកក្ខន្ធផង ក្នុងខណៈនៃបដិសន្ធិ អទោសៈក្តី អមោហៈក្តី អាស្រ័យនូវអលោភៈផង វត្ថុផង ។បេ។ ធម៌មិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុផង ជាហេតុ

ផង ។បេ។ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ២ ផង ហេតុផង ក្នុងខណៈនៃបដិសន្ធិ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវវត្ថុផង ហេតុផង ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ ជាហេតុផង ធម៌មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី អទោសៈក្តី អមោហៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុផង អលោភៈផង ។បេ។ ខន្ធ ២ ក្តី អទោសៈក្តី អមោហៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ២ ផង អលោភៈផង ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ខន្ធ ៣ ក្តី មោហៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុផង លោភៈផង ។បេ។ ខន្ធ ២ ។បេ។ ក្នុងខណៈនៃបដិសន្ធិ អទោសៈក្តី អមោហៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុផង អលោភៈផង ។បេ។

[ ២ ] ធម៌ជាហេតុ អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺលើកតែរូបភពចេញ និយាយតែប្រស្នា ៩ ក្នុងអរូបភពតែម្យ៉ាង ។ ព្រោះអធិបតិប្បច្ច័យ គឺបដិសន្ធិ មិនមានទេ ( ការណ៍នេះ ) គ្រប់គ្រាន់ហើយ អាស្រ័យនូវមហាភូត ១ ។បេ។ ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត នេះជាសេចក្តីផ្សេងៗ គ្នា ។ ព្រោះអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ និងសហជាតប្បច្ច័យ គឺពួកមហាភូតទាំងអស់ដរាបដល់ពួកអសញ្ញសត្វ ។ ព្រោះអញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ និងអាសេវនប្បច្ច័យ ឯបដិសន្ធិ មិន

មានក្នុងបច្ច័យទាំង ២ ទេ ។ ព្រោះកម្មប្បច្ច័យ និងវិបាកប្បច្ច័យ ។ សេចក្តីបន្ត្រញ ។ ព្រោះអវិគតប្បច្ច័យ ។

[ ៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៤ ] ធម៌ មិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាអហេតុកៈផង មិនមែនជាហេតុផង ។បេ។ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ។បេ។ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ។បេ។ ធម៌ជាហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ៥ ] ធម៌ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវហេតុ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌មិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ

មិនមែនជាហេតុ ក្នុងខណៈនៃបដិសន្ធិ មហាភូតទាំងអស់ ( ក៏អាស្រ័យនូវពួកនហេតុក្ខន្ធ ) ។ ធម៌មិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវហេតុផង ពួកខន្ធមិនមែនជាហេតុផង ក្នុងខណៈនៃបដិសន្ធិ ។បេ។ ព្រោះនអធិបតិប្បច្ច័យ គឺបរិបូណ៌ ។ ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ ។

[ ៦ ] ធម៌ជាហេតុ អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺអទោសៈ អមោហៈអាស្រ័យនូវអលោភៈ ក្នុងអរូប ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈអាស្រ័យនូវលោភៈ លោភៈអាស្រ័យនូវមោហៈ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌មិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវហេតុ ក្នុងអរូប ចិត្តសមុដ្ឋានរូប អាស្រ័យនូវហេតុ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺអទោសៈក្តី អមោហៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវអលោភៈ ក្នុងអរូប ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវលោភៈ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌មិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុ ក្នុង

អរូប ។បេ។ ខន្ធ ២ អាស្រ័យនូវខន្ធ ២ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធមិនមែនជាហេតុ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ជាហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺពួកហេតុ អាស្រ័យនូវពួកខន្ធ មិនមែនជាហេតុ ក្នុងអរូប ក្នុងខណៈនៃបដិសន្ធិ ។បេ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ពួកហេតុក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុ ក្នុងអរូប ។បេ។ នូវខន្ធ ២ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺអទោសៈ អមោហៈ អាស្រ័យនូវអលោភៈផង ពួកសម្បយុត្តកក្ខន្ធផង ក្នុងអរូប ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈ អាស្រ័យនូវលោភៈផង ពួកសម្បយុត្តកក្ខន្ធផង ក្នុងអរូប ។ បណ្ឌិត គប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌មិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុផង ហេតុផង ក្នុងអរូប ។បេ។ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ មិនមែនជាហេតុផង ហេតុផង ក្នុងខណៈនៃបដិសន្ធិ ។បេ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី អាស្រ័យនូវធម៌ ជាហេតុផង ធម៌មិនមែនជាហេតុផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ ក្តី អទោសៈក្តី អមោហៈក្តី អាស្រ័យនូវខន្ធ ១

មិនមែនជាហេតុផង អលោកៈផង ក្នុងអរូប ។បេ។ នូវខន្ធ ២ ... ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ខន្ធ ៣ ក្តី មោហៈក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាហេតុផង លោកៈផង ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ៧ ] ធម៌ជាហេតុ អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះនបច្ឆាជាតប្បច្ច័យ ។ ... ព្រោះនអាសេវនប្បច្ច័យ ។

[ ៨ ] ធម៌ មិនមែនជាហេតុ អាស្រ័យនូវធម៌ ជាហេតុ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវហេតុ ។ ធម៌មិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកខន្ធមិនមែនជាហេតុ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... ។ នហេតុធម៌ អាស្រ័យនូវហេតុធម៌ និងនហេតុធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវហេតុផង ពួកសម្បយុត្តកក្ខន្ធផង ។

[ ៩ ] ធម៌ជាហេតុ អាស្រ័យនូវធម៌ជាហេតុ ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ មានវារៈ ៩ ។

[ ១០ ] ធម៌មិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនអាហារប្បច្ច័យ គឺពាហិរ ... ឧតុសមុដ្ឋាន ... មហាភូត ៣ អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ កដត្តារូប ឧបាទារូប អាស្រ័យនូវពួកមហាភូត ។

[ ១១ ] ... ព្រោះនឥន្ទ្រិយប្បច្ច័យ គឺពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន មហាភូត ១ ។បេ។ ឧបាទារូប អាស្រ័យនូវពួកមហាភូត រូបជីវិតិន្ទ្រិយ អាស្រ័យនូវពួកមហាភូត របស់ពួកអសញ្ញសត្វ ។

[ ១២ ] ... ព្រោះនឈានប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយបញ្ចវិញ្ញាណ ។បេ។ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ។បេ។

[ ១៣ ] ... ព្រោះនមគ្គប្បច្ច័យ គឺអាស្រ័យនូវខន្ធ ១ ជាអហេតុកៈ និងជានហេតុ ។បេ។ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ។បេ។ ព្រោះនសម្បយុត្តប្បច្ច័យ និងនវិប្បយុត្តប្បច្ច័យ គឺអរូបបញ្ហាទាំងឡាយ ប្រហែលគ្នានឹងនបុរេជាតប្បច្ច័យ ។ ព្រោះនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

[ ១៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្ប-

យុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### បច្ចនីយៈ ចប់

[ ១៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។ ... ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

### អនុលោមប្បច្ចនីយៈ ចប់

[ ១៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ... ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងឈានប្បច្ច័យ មានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

### បច្ចនីយានុលោម ចប់

ឯសហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ បច្ចយវារៈ និង និស្សយវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ កាលពួកមហាកុសលសម្រេចហើយ បណ្ឌិតគប្បីធ្វើបញ្ហាថា ( ពួកខន្ធ ) ពឹងផ្អែកនឹងវត្ថុ ឯអាយតនៈ ៥ បានក្នុងអនុលោម និងបច្ចនីយៈយ៉ាងណា បណ្ឌិតគប្បីធ្វើ ( បញ្ហា ) យ៉ាងនោះដែរ ។ សំសដ្ឋវារៈ និងសម្បយុត្តវារៈ ចប់បរិបូណ៌ហើយ រូបមិនមានទេ មានតែអរូបម្យ៉ាង ។

## បញ្ហាវារៈ

[ ១៧ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយហេតុប្បច្ច័យ គឺអលោភៈ ជាបច្ច័យនៃអទោសៈ និងអមោហៈ ដោយហេតុប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ លោភៈ ជាបច្ច័យនៃមោហៈ ដោយហេតុប្បច្ច័យ ទោសៈជាបច្ច័យនៃមោហៈ ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយហេតុប្បច្ច័យ គឺហេតុជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយហេតុប្បច្ច័យ គឺអលោភៈ ជាបច្ច័យនៃអទោសៈផង អមោហៈផង ពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ លោភៈ ( ជាបច្ច័យ ) នៃមោហៈ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ១៨ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអារម្មណប្បច្ច័យ

គឺពួកហេតុ ប្រារព្ធនូវហេតុ ទើបកើតឡើង ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធមិនមែនជាហេតុ ប្រារព្ធនូវហេតុ ទើបកើតឡើង ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ប្រារព្ធនូវហេតុ ទើបកើតឡើង ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ពិចារណានូវកុសលនោះ ពិចារណានូវកុសលទាំងឡាយដែលសន្សំល្អហើយក្នុងកាលមុន ចេញអំពីឈាន ពិចារណានូវឈាន ពួកព្រះអរិយៈចេញអំពីមគ្គ ពិចារណានូវមគ្គ និងផល ... នូវនិព្វាន ... និព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈពិចារណានូវពួកហេតុ គឺកិលេសដែលលះបង់ហើយ ពួកកិលេសដែលសង្កត់សង្កិនហើយ ... ដឹងនូវពួកកិលេសដែលធ្លាប់សន្សំហើយក្នុងកាលមុន នូវចក្ខុ ... ។បេ។ នូវវត្ថុ ... ឃើញច្បាស់នូវពួកខន្ធមិនមែនជាហេតុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។បេ។ ទោមនស្សកើតឡើង ឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយនហេតុចិត្ត ( ចិត្តមិនមែនជាហេតុ ) ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនកិរិយា ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនកិរិយា អាកិញ្ចញ្ញាយតនកិរិយា ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនកិរិយា រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ។បេ។

ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកខន្ធមិនមែនជាហេតុ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន ... ការពិចារណា គឺដំណើរទី ១ មិនមានទេ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពាក្យដូច្នេះនេះ មិនមានទេ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទានសីល ... ឧបោសថកម្ម ... ពិចារណានូវកុសលនោះ ពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ប្រារព្ធនូវអំពើនោះ ទើបកើតឡើង ។ បុគ្គលអ្នកឋិតនៅក្នុងកុសលកម្មនោះៗ គប្បីធ្វើធម៌នេះ ឲ្យដូចគ្នានឹងដំណើរទី ២ ដែរ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុ ដោយអារម្មណប្បច្ច័យ គឺពួកហេតុប្រារព្ធនូវហេតុផងនូវពួកសម្បយុត្តកក្ខន្ធផង ទើបកើតឡើង ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធមិនមែនជាហេតុ ប្រារព្ធនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ទើបកើតឡើង ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ប្រារព្ធនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ទើប

កើតឡើង ។

[ ១៩ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកហេតុធ្វើនូវហេតុ ឲ្យជាទីគោរព ទើបកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកហេតុ ដោយអធិបតិប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកនហេតុក្ខន្ធ ធ្វើនូវហេតុ ឲ្យជាទីគោរព ទើបកើតឡើង ។ ឯសហជាតាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ធ្វើនូវហេតុឲ្យជាទីគោរព ទើបកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកហេតុផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពាក្យថា ឲ្យទានបណ្ឌិតគប្បីឲ្យពិស្តារ ដរាបដល់ពួកនហេតុកក្ខន្ធ ។ ឯសហជាតាធិបតិ គឺអធិបតិមិនមែនជាហេតុ ជាបច្ច័យពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ

ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន ... វត្តក្តី ពួកខន្ធមិនមែនជាហេតុក្តី មានត្រឹមណា សេចក្តីបង្រួញ បណ្ឌិតគប្បីធ្វើត្រឹមនោះចុះ ។ សហជាតាធិបតិ គឺអធិបតិ មិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកហេតុ ដោយអធិបតិប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សីល ... ឧបោសថកម្ម ... ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា ពួកខន្ធមិនមែនជាហេតុក្តី ពួកហេតុក្តី ធ្វើនូវកុសលនោះឲ្យជាទីគោរព ទើបកើតឡើង ( ពិចារណា ) នូវកុសលទាំងឡាយ ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន វត្តក្តី ពួកខន្ធមិនមែនជាហេតុក្តី មានត្រឹមណា បណ្ឌិតគប្បីធ្វើត្រឹមនោះចុះ ។ ឯសហជាតាធិបតិ គឺអធិបតិមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកហេតុផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកហេតុ ធ្វើនូវហេតុ និងពួកសម្បយុត្តកក្ខន្ធ ឲ្យជាទីគោរព ទើបកើតឡើង ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកខន្ធ មិនមែនជាហេតុ ធ្វើនូវហេតុ និងពួកសម្បយុត្តកក្ខន្ធ ឲ្យជាទីគោរព ទើបកើតឡើង ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុ

ក្តី ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ធ្វើនូវហេតុ និងពួកសម្បយុត្តកក្ខន្ធ ឲ្យជាទីគោរព ទើបកើតឡើង ។

[ ២០ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអនន្តរប្បច្ច័យ គឺពួកហេតុមុនៗ ជាបច្ច័យនៃពួកហេតុក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ គឺពួកហេតុមុនៗ ជាបច្ច័យនៃពួកខន្ធមិនមែនជាហេតុក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអនន្តរប្បច្ច័យ គឺពួកហេតុមុនៗ ជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមិនមែនជាហេតុមុនៗ ជាបច្ច័យនៃពួកខន្ធ មិនមែនជាហេតុក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ ។ សេចក្តីបន្រ្ទញ ។ នេវសញ្ញានាសញ្ញាយតនៈ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអនន្តរប្បច្ច័យ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអនន្តរប្បច្ច័យ គឺនហេតុ-មូលកៈក្តី វារៈ ៣ ក្តី ដូចគ្នានឹងវារៈ ១ ដែរ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុ ដោយអនន្តរប្បច្ច័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី មុនៗ ជាបច្ច័យនៃពួកហេតុក្រោយៗ ដោយអនន្ត-

រប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តីមុនៗ ជាបច្ច័យនៃពួកខន្ធមិនមែនជាហេតុក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអនន្តរប្បច្ច័យ គឺពួកហេតុក្តី ពួកសម្បយុត្ត-កក្ខន្ធក្តី មុនៗ ជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ក្រោយៗ ដោយអនន្តរប្បច្ច័យ ។

[ ២១ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយសមនន្តរប្បច្ច័យ គឺប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។ ... ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ឯបច្ច័យទាំង ២ នេះ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ ដូចនិស្សយប្បច្ច័យក្នុងបច្ចយវារៈដែរ ។

[ ២២ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយឧបនិស្ស-យប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូប-និស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកហេតុ ជាបច្ច័យនៃពួកហេតុ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកហេតុ ជាបច្ច័យនៃពួកខន្ធមិនមែនជាហេតុ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជា

ហេតុផង ធម៌មិនមែនជាហេតុផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកហេតុជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យទាន ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងមានះ ប្រកាន់ទិដ្ឋិ សីល ... ។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេនាសនៈ ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ នៃសេចក្តីប្រាថ្នា មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺនូវសទ្ធា ។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេនាសនៈ ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ នៃសេចក្តីប្រាថ្នា មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺ ( មានសេចក្តី ) ប្រហែលគ្នានឹងឧបនិស្សយប្បច្ច័យទី ២ ដែរ ។ ពួកធម៌ជាហេតុក្តី ពួកធម៌

មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកហេតុ ដោយឧបនិស្សយប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ មិនមែនជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកខន្ធ មិនមែនជាហេតុ ដោយឧបនិស្សយប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៣ ] ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ។បេ។ បុគ្គលឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។បេ។ ទោមនស្សក៏កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ។បេ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយ

បុរេជាតប្បច្ច័យ ។បេ។ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ មិនមែនជាហេតុ ដោយបុរេជាតប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ។បេ។ នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្សក៏កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកហេតុ ដោយបុរេជាតប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ។បេ។ នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្ស ... ដោយទិព្វ ( ចក្ខុ ) ។បេ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។

[ ២៤ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយបច្ឆាជាតប្បច្ច័យ គឺពួកហេតុ ដែលកើតក្រោយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយបច្ឆាជាតប្បច្ច័យ គឺពួកខន្ធមិនមែនជាហេតុដែលកើតក្រោយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយបច្ឆាជាតប្បច្ច័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ដែលកើតក្រោយ ជា

បច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ២៥ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអាសេវនប្បច្ច័យ គឺប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។

[ ២៦ ] ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាមិនមែនជាហេតុ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនា មិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកហេតុ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាមិនមែនជាហេតុ ជាបច្ច័យនៃពួកវិបាកហេតុ ដោយកម្មប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកហេតុផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាមិនមែនជាហេតុ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង ពួកហេតុផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ២៧ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយវិបាកប្បច្ច័យ គឺអលោភៈជាវិបាក ជាបច្ច័យនៃអទោសៈ និងអមោហៈ ដោយវិបាកប្បច្ច័យ ។

ប្រស្នា ៩ ក្នុងការចែកនូវវិបាកប្បច្ច័យ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២៨ ] ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអាហារប្បច្ច័យ គឺពួកអាហារមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអាហារប្បច្ច័យ គឺពួកអាហារមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកហេតុ ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអាហារប្បច្ច័យ គឺពួកអាហារមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកហេតុផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ២៩ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយឥន្ទ្រិយប្បច្ច័យ គឺក្នុងហេតុមូលកៈ មានវារៈតែ ៣ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ។ ឥន្ទ្រិយប្បច្ច័យ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។ មានតែវារៈ ៩ ។

[ ៣០ ] ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយ

ឈានប្បច្ច័យ គឺមានតែវារៈ ៣ ។

[ ៣១ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយមគ្គប្បច្ច័យ ... ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺក្នុងបច្ច័យទាំង ២ នេះ មានវារៈតែ ៩ ។

[ ៣២ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកហេតុ ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ពួកហេតុ ជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកហេតុ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ មិនមែនជាហេតុ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធមិនមែនជាហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធមិនមែនជាហេតុ ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ។បេ។ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធ មិនមែនជាហេតុ ដោយវិប្បយុត្តប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធមិនមែនជាហេតុ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺក្នុង

ខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកហេតុ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺវត្ថុជាបច្ច័យនៃពួកហេតុ ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺវត្ថុជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៣ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអត្ថិប្បច្ច័យ គឺអលោភៈ ជាបច្ច័យនៃអទោសៈ និងអមោហៈ ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ លោភៈ ជាបច្ច័យនៃមោហៈ ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកហេតុជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួក

ចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ឯបច្ឆា-ជាត គឺពួកហេតុ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអត្ថិប្បច្ច័យ គឺអលោភៈជាបច្ច័យនៃអទោសៈ អមោហៈ និងពួកសម្បយុត្ត-កក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ លោភៈ ជាបច្ច័យនៃមោហៈ និងពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ មិនមែនជាហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ មិនមែនជាហេតុ ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។បេ។ ខន្ធ ២ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ មិនមែនជាហេតុ ជាបច្ច័យនៃខន្ធ ៣ ផង ពួកកដត្តារូបផង ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយអត្ថិប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយអត្ថិប្បច្ច័យ មហាភូត ១ ។បេ។ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួកអសញ្ញសត្វ ។បេ។ បុរេជាត គឺនូវចក្ខុ ។បេ។ នូវវត្ថុ ។បេ។ បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ មិនមែន

ជាហេតុ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធមិនមែនជាហេតុ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺពួកខន្ធមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកហេតុ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកហេតុ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺនូវចក្ខុ ។បេ។ នូវវត្ថុ ជាមិនទៀង ។បេ។ ទោមនស្ស ក៏កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ វត្ថុជាបច្ច័យនៃពួកហេតុ ដោយអត្ថិប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ មិនមែនជាហេតុ ជាបច្ច័យនៃខន្ធ ៣ ផង ពួកហេតុផង ពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺនូវចក្ខុ ។បេ។ នូវវត្ថុ ជាមិនទៀង ។បេ។ ទោមនស្សក៏កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ វត្ថុជាបច្ច័យនៃពួកហេតុផង ពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត

គឺអលោភៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃអទោសៈ និងអមោហៈ ដោយ អត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ លោភៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃមោហៈ ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ អលោភៈក្តី វត្ថុក្តី ជាបច្ច័យនៃអទោសៈ និងអមោហៈ ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ មិនមែនជាហេតុក្តី ហេតុក្តី ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។បេ។ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ហេតុក្តី វត្ថុក្តី ជាបច្ច័យនៃពួកខន្ធ មិនមែនជាហេតុ ដោយអត្ថិប្បច្ច័យ ។ សហជាត គឺពួកហេតុក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកហេតុក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយ អត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកហេតុក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួក កដត្តារូប ដោយអត្ថិប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអត្ថិប្បច្ច័យ បាន ដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ មិនមែនជាហេតុក្តី អលោភៈក្តី ជាបច្ច័យនៃខន្ធ ៣ ផង អទោសៈផង អមោហៈផង ពួកចិត្ត-សមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ខន្ធ ១ មិនមែនជាហេតុក្តី លោភៈក្តី ជាបច្ច័យនៃខន្ធ ៣ ផង មោហៈផង ពួក

ចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ មិនមែនជាហេតុក្តី អលោភៈក្តី ... ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ អលោភៈក្តី វត្ថុក្តី ជាបច្ច័យនៃអទោសៈផង អមោហៈផង ពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ លោភៈក្តី វត្ថុក្តី ជាបច្ច័យនៃមោហៈផង ពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតកាលយល់តាម គប្បីរាប់យ៉ាងនេះចុះ ។

អនុលោម ចប់

[ ៣៥ ] ធម៌ជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ធម៌ជាហេតុ ជាបច្ច័យនៃធម៌ ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ពួក

ធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ពួកធម៌ជាហេតុក្តី ពួកធម៌មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ធម៌មិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបង្រួញ ។ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៣៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។ ... ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមបច្ចនីយៈ ចប់

[ ៣៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

ហេតុទុកៈ ចប់

# អដ្ឋកថា

## ទុកប្បដ្ឋាន

## ហេតុទុកជាដើម

[ ១-៣៨ ] ក្នុងទុកប្បដ្ឋាន អ្នកសិក្សាគប្បីជ្រាបបញ្ហាវិសជ្ជនា និងការរាប់ក្នុងទុកៈទាំងអស់ តាមន័យដែលពោលមកហើយ ក្នុងបាលីនោះឯង ។ ម្យ៉ាងទៀត ក្នុងទុកប្បដ្ឋាននេះ ការវិសជ្ជនាសហេតុទុកៈ និងហេតុសម្បយុត្តទុកៈ ដូចគ្នានឹងការវិសជ្ជនាហេតុទុកៈ ។ ហេតុ និងសហេតុកៈ ហេតុនៃហេតុសម្បយុត្តទុកៈ និងសប្បច្ចយទុកៈ សង្ខតទុកៈក៏ដូចគ្នា ។ បទថា **ឥមំ ទុកំ យថា សប្បច្ចយទុកំ ឯវំ កាតព្វំ** ព្រះមានព្រះភាគត្រាស់ ព្រោះសង្ខតធម៌ រមែងប្រកបរួមជាមួយអសង្ខតធម៌មិនបាន ដូចសប្បច្ចយធម៌ប្រកបជាមួយអប្បច្ចយធម៌មិនបាន ដូច្នោះ ។ សារម្មណទុកៈ ចិត្តសម្បយុត្តទុកៈ និងសំសដ្ឋទុកៈ មានវិសជ្ជនាដូចគ្នា ។ អាសវគោច្ឆកៈ ឱឃគោច្ឆកៈ និងយោគគោច្ឆកៈ ក៏មានវិសជ្ជនាដូចគ្នា ព្រោះថា ធម៌ទាំង ៣ នេះ មានវិសជ្ជនាដូចគ្នា ដែលអាស្រ័យនូវគ្នានិងគ្នា ៕

**អដ្ឋកថាហេតុទុកៈជាដើម ចប់**

# សហេតុកទុកៈ

## បដិច្ចវារៈ

[ ៣៩ ] សហេតុកធម៌ ( ធម៌ប្រកបដោយហេតុ ) អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ ខន្ធ ២ អាស្រ័យនូវខន្ធ ២ ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ ( ធម៌មិនមានហេតុ ) អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសហេតុកក្ខន្ធ ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ មហាភូត ៣ អាស្រ័យនូវមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធ អាស្រ័យនូវវត្ថុ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធ អាស្រ័យនូវវត្ថុ

កដត្តារូប អាស្រ័យនូវពួកមហាភូត ។ សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ និងមោហៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ និងវត្ថុ នូវខន្ធ ២ ... ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសហេតុកក្ខន្ធ និងពួកមហាភូត ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ និងមោហៈ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ និងមោហៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ និងវត្ថុ នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវពួកសហេតុកក្ខន្ធ និងពួកមហាភូត ។

[ ៤០ ] សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវសហេតុកធម៌ ទើប

កើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ នូវខន្ធ ២ ... ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ពួកអហេតុកក្ខន្ធ អាស្រ័យនូវវត្ថុ ។ សហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធ អាស្រ័យនូវវត្ថុ ។ សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ និងមោហៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ និងវត្ថុ នូវខន្ធ ២ ... ។

[ ៤១ ] សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសហេតុកក្ខន្ធ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវសហេតុកធម៌ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង

ព្រោះអធិបតិប្បច្ច័យ គឺមហាភូត ១ ... ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និង អហេតុកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អា-ស្រ័យនូវពួកសហេតុកក្ខន្ធ និងពួកមហាភូត ។

[ ៤២ ] អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះ អនន្តរប្បច្ច័យ ។ ... ព្រោះសមនន្តរប្បច្ច័យ ។

[ ៤៣ ] ... ព្រោះសហជាតប្បច្ច័យ គឺសហេតុកក្ខន្ធ ១ ... ក្នុងបដិ-សន្ធិក្ខណៈ ... ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសហេតុកក្ខន្ធ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិ-សន្ធិក្ខណៈ ...។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ខន្ធ ៣ ក្តី មោហៈក្តី ចិត្ត-សមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយ ឧទ្ធច្ចៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ អាស្រ័យនូវ អហេតុកធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្ត-សមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុង

បដិសន្ធិក្ខណៈ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធ អាស្រ័យនូវវត្ថុ មហាភូត ១ ។បេ។ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ១ របស់ ពួកអសញ្ញសត្វ ។បេ។ សហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺប្រស្នា ៥ នេះ ដូចគ្នានឹងហេតុប្បច្ច័យដែរ មិនផ្សេងគ្នាទេ ។

[ ៤៤ ] សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ វត្ថុ អាស្រ័យនូវពួកសហេតុកក្ខន្ធ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ ក្តី វត្ថុក្តី អាស្រ័យនូវសហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ ក្តី វត្ថុក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ អាស្រ័យនូវខន្ធ ២ ... សេចក្តីបង្រួញ ដរាបដល់ពួកអសញ្ញសត្វ ។ សហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើត

ឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធ អាស្រ័យនូវវត្ថុ ។ សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈនិងមោហៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ និងវត្ថុ នូវខន្ធ ២ ... ។

[ ៤៥ ] សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនិស្សយប្បច្ច័យ ។ ... ព្រោះឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ ។ ឈានប្បច្ច័យក្តី មគ្គប្បច្ច័យក្តី ដូចគ្នានឹងសហជាតប្បច្ច័យដែរ ពួកមហាភូតជាខាងក្រៅ មិនមានទេ ។ ... ព្រោះសម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

[ ៤៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុង

អាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងវិគតប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៤៧ ] អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ពួកអសញ្ញសត្វមានដរាបណា បណ្ឌិតគប្បីធ្វើនូវធម៌ទាំងអស់ ដរាបនោះដែរ ។

[ ៤៨ ] អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសហេតុកក្ខន្ធ ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកអហេតុកក្ខន្ធ

ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ វត្ថុ អាស្រ័យនូវពួកខន្ធ មហាភូត ១ ... ។ សេចក្ដីបង្រួញ ។ ( មហាភូត ) ១ របស់ពួកអសញ្ញសត្វ ... ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសហេតុកក្ខន្ធ និងពួកមហាភូត ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ និងមោហៈ ។

[ ៤៩ ] សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺ ( បច្ច័យទាំងឡាយ ) ដូចគ្នានឹងសហជាតប្បច្ច័យក្នុងអនុលោមដែរ ។ ... ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ ។

[ ៥០ ] សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ ក្នុងបដិសន្ធិក្ខណៈ នូវសហេតុកក្ខន្ធ ... ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសហេតុកក្ខន្ធ ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ក្ដី អហេតុកធម៌ក្ដី អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣

ក្តី មោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើងព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប នូវអហេតុកក្ខន្ធ ១ ... នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកអហេតុកក្ខន្ធ ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ... ពួកអសញ្ញសត្វមានដរាបណា សេចក្តីពិស្តារក៏មានដរាបនោះដែរ ។ សហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធ អាស្រ័យនូវវត្ថុ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធ អាស្រ័យនូវវត្ថុ កដត្តារូប អាស្រ័យនូវពួកមហាភូត ។ សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ និងមោហៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ និងវត្ថុ នូវខន្ធ ២ ... ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសហេតុកក្ខន្ធ និងពួកមហាភូត ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែល

ប្រឡាំដោយវិចិកិច្ឆា ប្រឡាំដោយឧទ្ធច្ចៈ និងមោហៈ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ អាស្រ័យនូវសហេតុកក្ខន្ធ ១ និងវត្ថុ នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវពួកសហេតុកក្ខន្ធ និងពួកមហាភូត ។

[ ៥១ ] សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនបច្ឆាជាតប្បច្ច័យ ។ ... ព្រោះនអាសេវនប្បច្ច័យ ។

[ ៥២ ] ... ព្រោះនកម្មប្បច្ច័យ គឺសហេតុកចេតនា អាស្រ័យនូវពួកសហេតុកក្ខន្ធ ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺអហេតុកចេតនា អាស្រ័យនូវពួកអហេតុកក្ខន្ធ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... ។ សហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវមោហៈដែលប្រឡាំដោយវិចិកិច្ឆា ប្រឡាំដោយឧទ្ធច្ចៈ ។ សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកខន្ធដែលប្រឡាំដោយវិចិកិច្ឆា ប្រឡាំដោយឧទ្ធច្ចៈ និងមោហៈ ។

[ ៥៣ ] ... ព្រោះនវិបាកប្បច្ច័យ គឺបដិសន្ធិមិនមានទេ ។

[ ៥៤ ] អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនអាហារប្បច្ច័យ ។ ... ព្រោះនឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ

និងនសម្បយុត្តប្បច្ច័យ ។

[ ៥៥ ] សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺក្នុងអរូប នូវសហេតុកក្ខន្ធ ១ ... ។បេ។ អហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើងព្រោះនវិប្បយុត្តប្បច្ច័យ គឺក្នុងអរូប មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី អាស្រ័យនូវសហេតុកធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ ក្តី មោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ នូវខន្ធ ២ ... ។ អហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ នូវខន្ធ ២ ... ។ សហេតុកធម៌ អាស្រ័យនូវអហេតុកធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺក្នុងអរូប ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ សហេតុកធម៌ អាស្រ័យនូវសហេតុកធម៌ និងអហេតុកធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ និងមោហៈ នូវខន្ធ ២ ... ។ ... ព្រោះនោនត្ថិប្បច្ច័យនិងនោវិគតប្បច្ច័យ ។

[ ៥៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ

៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៥៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមបច្ចនីយៈ ចប់

[ ៥៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងឈានប្បច្ច័យ មានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

សហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៥៩ ] សហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មូលនៃសហេតុកៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ អហេតុកធម៌ ពឹងផ្អែកនឹងអហេតុកធម៌ ... គឺ ( មូលនៃអហេតុកៈ ) ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ សហេតុកធម៌ ពឹងផ្អែកនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ពឹងផ្អែកនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូបពឹងផ្អែកនឹងពួកមហាភូត ពួក

សម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ នឹងវត្ថុ ... ។ សហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងសហេតុកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកសហេតុកក្ខន្ធផង នឹងពួកមហាភូតផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងមោហៈផង ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងសហេតុកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកសហេតុ-កក្ខន្ធផង នឹងពួកមហាភូតផង ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ខន្ធ ៣ ពឹងផ្អែកនឹងសហេតុកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... កដត្តារូប ពឹងផ្អែកនឹងពួកសហេតុកក្ខន្ធផង នឹងពួកមហាភូតផង ។

[ ៦០ ] សហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ ទើបកើតឡើង

ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងសហេតុកក្ខន្ធ ១ ក្នុងបដិ-សន្ធិក្ខណៈ ... ។ អហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ សហេតុ-កធម៌ក្តី អហេតុកធម៌ក្តី ពឹងផ្អែកនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះ អារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកប ដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ នឹងខន្ធ ២ ... ។ អហេតុកធម៌ ពឹងផ្អែក នឹងអហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺនឹងអហេតុកក្ខន្ធ ១ ... នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ពួកខន្ធពឹងផ្អែកនឹងវត្ថុ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួក អហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ សហេតុកធម៌ ពឹងផ្អែកនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកប ដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ពឹងផ្អែកនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ពឹងផ្អែកនឹងវត្ថុ ។ សហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើត ឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងសហេតុកក្ខន្ធ ១ ផង នឹងវត្ថុផង ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយ

ឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ខន្ធ ២ ក្តី មោហៈក្តី ពឹងផ្អែកនឹងខន្ធ ២ ។

[ ៦១ ] សហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ ប្រស្នាទាំង ៩ ក្នុងអធិបតិប្បច្ច័យ តែងប្រព្រឹត្តទៅដដែល ។

[ ៦២ ] សហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអនន្តរប្បច្ច័យ ។ ... ព្រោះសមនន្តរប្បច្ច័យ ។

[ ៦៣ ] ... ព្រោះសហជាតប្បច្ច័យ មានវារៈ ៣ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ អហេតុកធម៌ ពឹងផ្អែកនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ នឹងខន្ធ ២ ... តាំងពីបដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកអហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ សហេតុកធម៌ ពឹងផ្អែកនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ ពួកសហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ពួក

សម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ពឹងផ្អែកនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺពួកសហេតុកក្ខន្ធពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកសម្បយុត្ត-កក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ នឹងវត្ថុ ... ។ សហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើង ព្រោះសហជា-តប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងសហេតុកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុ-កធម៌ ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកសហេតុកក្ខន្ធផង នឹងពួកមហាភូតផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងមោហៈផង មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើង ព្រោះសហ-ជាតប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងសហេតុកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកសហេតុកក្ខន្ធផង នឹងពួកមហាភូត

ផង ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកសហេតុកក្ខន្ធផង នឹងពួកមហាភូតផង ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ ២ ... ខន្ធ ៣ ក្តី មោហៈក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ពឹងផ្អែកនឹងសហេតុកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... កដត្តារូប ពឹងផ្អែកនឹងពួកសហេតុកក្ខន្ធផង នឹងពួកមហាភូតផង ។

[ ៦៤ ] សហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ព្រោះអវិគតប្បច្ច័យ ។

[ ៦៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៦៦ ] អហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ អហេតុកធម៌ ពឹងផ្អែកនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ នឹងអហេតុកក្ខន្ធ ១ ... ក្នុងបដិសន្ធិក្ខណៈ ... ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ

ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកអហេតុកក្ខន្ធ មោហៈក្តី ពឹងផ្អែកនឹងវត្ថុ ។ អហេតុកធម៌ ពឹងផ្អែកនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សេចក្តីបង្រួញ ។

[ ៦៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៦៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ...

ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### អនុលោមបច្ចនីយៈ ចប់

[ ៦៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។ ... ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### បច្ចនីយានុលោម ចប់

និស្សយវារៈ ប្រហែលគ្នានឹងបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ៧០ ] សហេតុកធម៌ ច្រឡូកច្រឡំនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ច្រឡូកច្រឡំនឹងសហេតុកក្ខន្ធ ១ នឹងខន្ធ

*២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ ប្រឡូកប្រឡំនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ប្រឡូកប្រឡំនឹងមោហៈ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ សហេតុកធម៌ ប្រឡូកប្រឡំនឹងសហេតុកធម៌ផង និងអហេតុកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡូកប្រឡំនឹងខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង និងមោហៈផង នឹងខន្ធ ២ ... ។*

*[ ៧១ ] សហេតុកធម៌ ប្រឡូកប្រឡំនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ប្រឡូកប្រឡំនឹងសហេតុកក្ខន្ធ ១ នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ ប្រឡូកប្រឡំនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ប្រឡូកប្រឡំនឹងពួកខន្ធ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ប្រឡូកប្រឡំនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី ប្រឡូកប្រឡំនឹងខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ នឹងខន្ធ ២ ... ។ អហេតុកធម៌ ប្រឡូកប្រឡំនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ប្រឡូកប្រឡំនឹងអហេតុកក្ខន្ធ ១ នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ ប្រឡូកប្រឡំនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រឡំដោយវិចិកិច្ឆា ប្រឡំ*

ដោយឧទ្ធច្ចៈ ប្រឡូកប្រឡំនឹងមោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ សហេតុកធម៌ ប្រឡូកប្រឡំនឹងសហេតុកធម៌ផង នឹងអហេតុកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ប្រឡូកប្រឡំនឹងខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ ២ ... ។

[ ៧២ ] សហេតុកធម៌ ប្រឡូកប្រឡំនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ប្រឡូកប្រឡំនឹងសហេតុកខន្ធ ១ នឹងខន្ធ ២ ... ។

[ ៧៣ ] សហេតុកធម៌ ប្រឡូកប្រឡំនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះអនន្តរប្បច្ច័យ ។ ... ព្រោះសមនន្តរប្បច្ច័យ និងសហជាតប្បច្ច័យ ។ សេចក្តីបង្រួញ ។

[ ៧៤ ] ... ព្រោះវិបាកប្បច្ច័យ គឺនឹងសហេតុកខន្ធ ១ ជាវិបាក ... នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ ប្រឡូកប្រឡំនឹងអហេតុ-កធម៌ ទើបកើតឡើង ព្រោះវិបាកប្បច្ច័យ គឺខន្ធ ៣ ប្រឡូកប្រឡំនឹងអហេតុកខន្ធ ១ ជាវិបាក នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ ... ព្រោះឈានប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ព្រោះអវិគតប្បច្ច័យ ។

[ ៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មាន វារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៦ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ។ សេចក្តីបង្រួញ ។ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងអាហារប្បច្ច័យ មានវារៈ ៦ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៦ ក្នុងឈានប្បច្ច័យ មានវារៈ ៦ ក្នុងមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៧៦ ] អហេតុកធម៌ ប្រឡូកប្រឡំនឹងសហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ប្រឡូកប្រឡំ នឹងពួកខន្ធ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ អហេតុកធម៌ ប្រឡូកប្រឡំនឹងអហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡូកប្រឡំនឹងអហេតុកខន្ធ ១ នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ សេចក្តីបង្រួញ ។

[ ៧៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៧៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

**អនុលោមបច្ចនីយៈ ចប់**

[ ៧៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ... ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

**បច្ចនីយានុលោម ចប់**

សម្បយុត្តវារៈ ប្រហែលគ្នានឹងសំសដ្ឋវារៈដែរ ។

## បញ្ហាវារៈ

[ ៨០ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយហេតុប្បច្ច័យ គឺពួកសហេតុកហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយហេតុប្បច្ច័យ គឺពួកសហេតុកហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ ជាបច្ច័យនៃសហេតុ-

កធម៌ផង នៃអហេតុកធម៌ផង ដោយហេតុប្បច្ច័យ គឺពួកសហេតុកហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ អហេតុកធម៌ជាបច្ច័យនៃសហេតុកធម៌ ដោយហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយហេតុប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ៨១ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សីល ... ឧបោសថកម្ម ពិចារណានូវកុសលនោះ ពិចារណានូវកុសលទាំងឡាយ ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ពិចារណានូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល នូវពួកកិលេស ដែលលះបង់ហើយ ... នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ... ក្នុងកាលមុន ... នូវពួកសហេតុកក្ខន្ធ ថាមិនទៀង ... ទោមនស្សកើតឡើង កាលកុសល និងអកុសល រលត់ហើយ សហេតុកវិបាក ក៏កើតឡើង ព្រោះកុសល និងអកុសលនោះ ជាអារម្មណ៍ ពួកព្រះអរិយៈ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយសហេតុកចិត្ត ដោយ

ចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចា-
យតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ
ពួកសហេតុកក្ខន្ធ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេ-
និវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយ
អារម្មណប្បច្ច័យ ពួកសហេតុកក្ខន្ធ ប្រារព្ធនូវពួកសហេតុកក្ខន្ធ ទើបកើត
ឡើង ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអារម្មណប្បច្ច័យ
គឺនូវពួកសហេតុកក្ខន្ធ ថាមិនទៀង ... ទោមនស្សកើតឡើង កាលកុសល
និងអកុសល រលត់ហើយ អហេតុកវិបាកក៏កើតឡើង ព្រោះកុសល និង
អកុសលនោះ ជាអារម្មណ៍ ពួកអហេតុកក្ខន្ធក្តី មោហៈក្តី ប្រារព្ធនូវពួក
សហេតុកក្ខន្ធ ទើបកើតឡើង ។ សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌
ផង នៃអហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលច្រឡំដោយ
វិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវពួកសហេតុកក្ខន្ធ ទើប
កើតឡើង ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអារម្មណប្បច្ច័យ
គឺនិព្វាន ជាបច្ច័យនៃអាវជ្ជនៈ ដោយអារម្មណប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ...
នូវពួកអហេតុកក្ខន្ធផង នូវមោហៈផង ថាមិនទៀង ... ទោមនស្សកើតឡើង
កាលកុសល និងអកុសលរលត់ហើយ អហេតុកវិបាក ក៏កើតឡើង ព្រោះ
កុសល និងអកុសលនោះ ជាអារម្មណ៍ រូបាយតនៈ ( ជាបច្ច័យ ) នៃ
ចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពួកអហេតុ-
កក្ខន្ធក្តី មោហៈក្តី ប្រារព្ធនូវពួកអហេតុកក្ខន្ធផង នូវមោហៈផង ទើបកើត

ឡើង ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកអហេតុកក្កិលេស ដែលលះបង់ហើយ ក្នុងកាលមុន ... នូវចក្ខុ ... នូវវត្ថុ ... នូវពួកអហេតុកក្ខន្ធផង នូវមោហៈផង ថាមិនទៀង ... ទោមនស្សកើតឡើង កាលកុសល និងអកុសល រលត់ហើយ សហេតុកវិបាកក៏កើតឡើង ព្រោះកុសល និងអកុសលនោះ ជាអារម្មណ៍ ពួកព្រះអរិយៈ ឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយអហេតុកចិត្ត ដោយចេតោបរិយញ្ញាណ ពួកអហេតុកក្ខន្ធ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកសហេតុកក្ខន្ធ ប្រារព្ធនូវពួកអហេតុកក្ខន្ធផង នូវមោហៈផង ទើបកើតឡើង ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវចក្ខុ ទើបកើតឡើង នូវសោតៈ ... នូវវត្ថុ ... ពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវពួកអហេតុកក្ខន្ធផង នូវមោហៈផង ទើបកើតឡើង ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសហេតុកក្ខន្ធប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវមោហៈផង

ទើបកើតឡើង ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃអហេតុកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកអហេតុកក្ខន្ធក្តី មោហៈក្តី ប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវមោហៈផង ទើបកើតឡើង ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវមោហៈផង ទើបកើតឡើង ។

[ ៨២ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គល ឲ្យទាន សីល ... ឧបោសថកម្ម ... ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា អំពីឈាន ... ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ... នូវផល ... ធ្វើនូវពួកសហេតុកក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺសហេតុកាធិបតិជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺសហេតុកាធិបតិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺសហេតុកាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួក

ចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកព្រះអរិយៈធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ... បុគ្គលធ្វើនូវពួកអហេតុកក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៨៣ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសហេតុកក្ខន្ធមុនៗ ជាបច្ច័យនៃពួកសហេតុកក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ( ជាបច្ច័យ ) នៃមគ្គ មគ្គ ( ជាបច្ច័យ ) នៃផល ផល ( ជាបច្ច័យ ) នៃផល អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈរបស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ច: ជាបច្ច័យនៃមោហ:ក្រោយៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ច: ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលប្រកបដោយហេតុ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ សហេតុកភវង្គជាបច្ច័យនៃអាវជ្ជន:ដោយអនន្តរប្បច្ច័យ សហេតុកភវង្គជាបច្ច័យនៃអហេតុកភវង្គ ដោយអនន្ត-

វប្បច្ច័យ ពួកសហេតុកក្ខន្ធ ជាបច្ច័យនៃអហេតុកវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈក្រោយៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ពួកអហេតុកក្ខន្ធមុនៗ ជាបច្ច័យនៃពួកអហេតុកក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃបញ្ចវិញ្ញាណ ដោយអនន្តរប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ អហេតុកចុតិចិត្ត ជាបច្ច័យនៃសហេតុកឧបបត្តិចិត្ត ដោយអនន្តរប្បច្ច័យ អហេតុកភវង្គ ជាបច្ច័យនៃសហេតុកភវង្គ ដោយអនន្តរប្បច្ច័យ ពួកអហេតុកក្ខន្ធ ជាបច្ច័យនៃសហេតុកវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដោយអនន្តរប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង

ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រទូស្តដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រទូស្តដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រទូស្តដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃអហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រទូស្តដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃមោហៈក្រោយៗ ដែលប្រទូស្តដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ពួកខន្ធ ដែលប្រទូស្តដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃអហេតុកវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រទូស្តដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកធម៌ក្រោយៗ ដែលប្រទូស្តដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ ។

[ ៨៤ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយសហជាតប្បច្ច័យ គឺប្រហែលគ្នានឹងសហជាតប្បច្ច័យ ក្នុងបដិច្ចវារៈដែរ តំណាមិនមានក្នុងទីនេះទេ ។ ... ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺប្រហែលគ្នានឹង

និស្សយប្បច្ច័យ ក្នុងបដិច្ចវារៈដែរ ឯគំណាមិនមាន ក្នុងទីនេះទេ ។

[ ៨៥ ] ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកសហេតុកក្ខន្ធ ជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកសហេតុកក្ខន្ធ ជាបច្ច័យនៃពួកអហេតុកក្ខន្ធផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកសហេតុកក្ខន្ធ ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺកាយិកសុខ ជាបច្ច័យនៃកាយិកសុខ និងកាយិកទុក្ខផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ កាយិកទុក្ខ ... រដូវ ... ភោជន ... សេនាសនៈ ជាបច្ច័យនៃកាយិកសុខ និងកាយិកទុក្ខផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ មោហៈជា បច្ច័យនៃកាយិកសុខ និងកាយិកទុក្ខផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ កាយិកសុខក្តី កាយិកទុក្ខក្តី រដូវក្តី ភោជនក្តី សេនាសនៈក្តី មោហៈក្តី ជាបច្ច័យនៃកាយិកសុខ និងកាយិកទុក្ខ

ផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវកាយិកសុខ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ កាយិកទុក្ខ ... រដូវ ភោជន សេនាសនៈ ... អាស្រ័យនូវមោហៈ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ កាយិកសុខក្តី ។បេ។ មោហៈក្តី ជាបច្ច័យនៃសទ្ធា ។បេ។ នៃបញ្ញា និងរាគៈ ។បេ។ នៃសេចក្តីប្រាថ្នា មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺកាយិកសុខក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃអហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកអហេតុកក្ខន្ធផង នៃមោហៈផង ដោយឧបនិស្ស-

យប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ៨៦ ] អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត ( គឺបុគ្គល ) នូវចក្ខុ ... នូវវត្ថុ ជាមិនទៀង ... ទោមនស្ស កើតឡើង កាលកុសល និងអកុសលរលត់ហើយ អហេតុកវិបាកក៏កើតឡើង ព្រោះកុសល និងអកុសលនោះជាអារម្មណ៍ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកអហេតុកក្ខន្ធផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត ( គឺបុគ្គល ) នូវចក្ខុ ... នូវវត្ថុ ជាមិនទៀង ... ទោមនស្សកើតឡើង កាលកុសល និងអកុសល រលត់ហើយ សហេតុកវិបាកក៏កើតឡើង ព្រោះកុសល និងអកុសលនោះ ជាអារម្មណ៍ បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ។

ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយបុរេ-ជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេ-ជាត ( គឺបុគ្គល ) នូវចក្ខុ ... ពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវវត្ថុ ទើបកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ ។

[ ៨៧ ] សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺពួកសហេតុកក្ខន្ធ ដែលកើតក្រោយ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺពួកអហេតុកក្ខន្ធ ដែលកើតក្រោយក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃអហេតុកធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ដែលកើតក្រោយក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៨៨ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអាសេវ-នប្បច្ច័យ គឺប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។ អាវជ្ជនៈក្តី ភវង្គៈក្តី មិនមានទេ ឯវារៈ ៩ ក្នុងអាសេវនប្បច្ច័យ បណ្ឌិតគប្បីវៀរចេញចុះ ។

[ ៨៩ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយកម្មប្បច្ច័យ

បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺសហេតុកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺសហេតុកចេតនា ជាបច្ច័យនៃពួកសហេតុកក្ខន្ធដែលជាវិបាក ដោយកម្មប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺសហេតុកចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺសហេតុកចេតនា ជាបច្ច័យនៃពួកអហេតុកក្ខន្ធជាវិបាកផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺសហេតុកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺសហេតុកចេតនា ជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដែលជាវិបាកផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយកម្មប្បច្ច័យ គឺអហេតុកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផងដោយកម្មប្បច្ច័យ ។

[ ៩០ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយវិបាកប្បច្ច័យ គឺសហេតុកក្ខន្ធ ១ ដែលជាវិបាក ( ជាបច្ច័យ ) នៃខន្ធ ៣ ... ខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយវិបាកប្បច្ច័យ ពួកសហេតុកក្ខន្ធដែលជាវិបាក ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ... ។ សហេតុកធម៌ ជាបច្ច័យនៃ

សហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយវិបាកប្បច្ច័យ គឺសហេតុកក្ខន្ធ ១ ដែលជាវិបាក ( ជាបច្ច័យ ) នៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ... ខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយវិបាកប្បច្ច័យ គឺអហេតុកក្ខន្ធ ១ ដែលជាវិបាក ( ជាបច្ច័យ ) នៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ... ខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ។

[ ៩១ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអាហារប្បច្ច័យ គឺមានវារៈ ៣ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអាហារប្បច្ច័យ គឺពួកអាហារជាអហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ កពឡីការាហារ ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ ។

[ ៩២ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ ៣ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយជាអហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ... ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយិន្ទ្រិយជាបច្ច័យនៃកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៩៣ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយឈានប្បច្ច័យ គឺមានវារៈ ៣ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយឈា-

នប្បច្ច័យ គឺពួកអន្តិឈានជាអហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឈានប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ... ។

[ ៩៤ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយមគ្គប្បច្ច័យ គឺមានវារៈ ៣ ។

[ ៩៥ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយសម្បយុត្តប្បច្ច័យ គឺមានបញ្ហា ៦ ប្រហែលគ្នានឹងសម្បយុត្តប្បច្ច័យ ក្នុងបដិច្ចវារៈដែរ ។

[ ៩៦ ] សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកសហេតុកក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ។ បច្ឆាជាត គឺពួកសហេតុកក្ខន្ធ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកអហេតុកក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ពួកអហេតុកក្ខន្ធ ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកអហេ-

តុកក្ខន្ធផង នៃមោហៈផង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួក អហេតុកក្ខន្ធក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្ប-យុត្តប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺក្នុងបដិសន្ធិក្ខណៈ វត្ថុ ជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយវិប្បយុត្តប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃអហេតុកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្ប-យុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្ប-យុត្តប្បច្ច័យ ។

[ ៩៧ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអត្ថិប្បច្ច័យ គឺសហេតុកក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ ... ខន្ធ ២ ... ក្នុងបដិ-សន្ធិក្ខណៈ ... ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកសហេតុកក្ខន្ធ ជា

បច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកខន្ធ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ... ។ ឯបច្ឆាជាត គឺពួកសហេតុកក្ខន្ធ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអត្ថិប្បច្ច័យ គឺសហេតុកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃខន្ធ ៣ ផង នៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ... ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺអហេតុកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... មោហៈ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ មានទាំងបដិសន្ធិផង ។ បណ្ឌិតគប្បីធ្វើ ដរាបដល់ពួកអសញ្ញសត្វចុះ ។ បុរេជាត ( គឺបុគ្គល ) នូវចក្ខុ នូវវត្ថុ ថាមិនទៀង ... ទោមនស្សកើតឡើង កាលកុសល និងអកុសល រលត់ហើយ អហេតុកវិបាក ក៏កើតឡើង ព្រោះកុសល និងអកុសលនោះ ជាអារម្មណ៍ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ

ដោយអត្ថិប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកអហេតុកក្ខន្ធផង នៃមោហៈផង ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកអហេតុកក្ខន្ធក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ កពឡឹការាហារ ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ វត្ថុ ជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ បុរេជាត ( គឺបុគ្គល ) នូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ... ទោមនស្សកើតឡើង កាលកុសល និងអកុសលរលត់ហើយ សហេតុកវិបាកក៏កើតឡើង ព្រោះកុសល និងអកុសលនោះជាអារម្មណ៍ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ វត្ថុ ជាបច្ច័យនៃពួកសហេតុកក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ បុរេជាត គឺនូវចក្ខុ ... ពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវវត្ថុ ទើបកើតឡើង វត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអត្ថិប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុក-

ធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ សហេតុកក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហជាត គឺសហេតុកក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃអហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកសហេតុកក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ពួកសហេតុកក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ សហជាត គឺពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី វត្ថុក្តី ជាបច្ច័យនៃមោហៈ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកសហេតុកក្ខន្ធក្តី កពឡីការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកសហេតុកក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយ

អត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃខន្ធ ៣ ផងពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ផងមោហៈផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។

[ ៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### អនុលោម ចប់

[ ៩៩ ] សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអារម្មណប្បច្ច័យ

ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ សហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃអហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ អហេតុកធម៌ ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃអហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជា

បច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ។ សហេតុកធម៌ក្តី អហេតុកធម៌ក្តី ជាបច្ច័យនៃសហេតុកធម៌ផង នៃអហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១០០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ១០១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៦ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៦ ។ សេចក្តីបង្រួញ ។ ... ក្នុងនមគ្គប្បច្ច័យ មានវារៈ ៦ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៦ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ១០២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុង

សមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

សហេតុកទុកៈ ចប់

# ហេតុសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ១០៣ ] ហេតុសម្បយុត្តធម៌ ( ធម៌ដែលប្រកបដោយហេតុ ) អាស្រ័យនូវហេតុសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាហេតុសម្បយុត្ត នូវខន្ធ ២ ... ក្នុងខណៈនៃបដិ-

សន្ធិ ... ។ ហេតុវិប្បយុត្តធម៌ ( ធម៌ដែលមិនប្រកបដោយហេតុ ) អាស្រ័យនូវហេតុសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យនូវពួកខន្ធ ជាហេតុសម្បយុត្ត ក្នុងខណៈនៃបដិសន្ធិ ... ។ បណ្ឌិតគប្បីធ្វើឲ្យពិស្ដារតាមដំណើរនេះចុះ ។ ដូចសហេតុកទុកៈដែរ មិនមានការធ្វើឲ្យផ្សេងគ្នាឡើយ ។

ហេតុសម្បយុត្តទុកៈ ចប់

## ហេតុសហេតុកទុកៈ

## បដិច្ចវារៈ

[ ១០៤ ] ធម៌ជាហេតុក្ដី ប្រកបដោយហេតុក្ដី អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអទោសៈនិងអមោហៈអាស្រ័យនូវអលោភៈ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈអាស្រ័យនូវលោភៈ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ អទោសៈ និងអមោហៈអាស្រ័យនូវអលោភៈ ក្នុងខណៈនៃបដិសន្ធិ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវហេតុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ជាហេតុក្ដី ប្រកបដោយហេតុក្ដី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្ដី អាស្រ័យ

នូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអទោសៈ និងអមោហៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវអលោភៈ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវលោភៈ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ អាស្រ័យនូវធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី អាស្រ័យនូវធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺហេតុអាស្រ័យនូវពួកខន្ធ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី អាស្រ័យនូវធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ហេតុក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ជាហេតុក្តី ដែលប្រកបដោយហេតុក្តី អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអទោសៈ និងអមោហៈ អាស្រ័យនូវអលោភៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈអាស្រ័យនូវលោភៈផង នូវ

ពួកសម្បយុត្តកក្ខន្ធផង ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិ-សន្ធិ ... ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុផង នូវហេតុផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី អទោសៈ និងអមោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុផង នូវអលោភៈផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ សេចក្តីបង្រួញ ។ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។

[ ១០៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

**អនុលោម ចប់**

[ ១០៦ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអទោសៈ

និងអមោហៈ អាស្រ័យនូវអលោភៈ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ... ។ វារៈ ៩ ចប់បរិបូណ៌ ។ ព្រោះនបុរេជាតប្បច្ច័យ មានវារៈ ៩ ។ ព្រោះនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ។ ព្រោះនអាសេវនប្បច្ច័យ មានវារៈ ៩ ។

[ ១០៧ ] ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវហេតុ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ អាស្រ័យនូវធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ទើបកើតឡើងព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ព្រោះនវិបាកប្បច្ច័យ និងនវិប្បយុត្តប្បច្ច័យ ។

[ ១០៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

**បច្ចនីយៈ ចប់**

[ ១០៩ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ... ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ១១០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោះនអធិបតិប្បច្ច័យ ... ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបង្រួញ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយានុលោម ចប់

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

# បញ្ហាវារៈ

[ ១១១ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយហេតុប្បច្ច័យ គឺអលោភៈ ជាបច្ច័យនៃអទោសៈ និងអមោហៈ ដោយហេតុប្បច្ច័យ ដូចបដិច្ចវារៈដែរ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែន

ជាហេតុ ដោយហេតុប្បច្ច័យ គឺហេតុជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុតែមិនមែនជាហេតុផង ដោយហេតុប្បច្ច័យ គឺអលោភៈជាបច្ច័យនៃអទោសៈនិងអមោហៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយហេតុប្បច្ច័យ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ១១២ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអារម្មណប្បច្ច័យ គឺពួកហេតុ កើតឡើងព្រោះប្រារព្ធនូវហេតុ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយហេតុ តែមិនមែនជាហេតុ កើតឡើង ព្រោះប្រារព្ធនូវហេតុ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវហេតុ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សីល ... ឧបោសថកម្ម ... ពិចារណានូវកុសលនោះ ពិចារណានូវពួកកុសល ដែលធ្លាប់សន្សំហើយក្នុងកាលមុន ចេញអំពីឈាន ពិចា-រណានូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណានូវមគ្គ ពិចារណា

នូវផល ពិចារណានូវពួកកិលេស ដែលលះបង់ហើយ ពិចារណានូវពួកកិលេសដែលសង្កត់សង្កិនហើយ ដឹងនូវពួកកិលេសដែលសន្សំហើយ ក្នុងកាលមុន នូវពួកខន្ធដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ថាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលដឹងនូវចិត្តរបស់បុគ្គល អ្នកព្រមព្រៀងដោយចិត្ត ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយអារម្មណប្បច្ច័យ ពួកខន្ធ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន ... ដំណើរទី ១ មិនមានផ្សេងគ្នាទេ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន ... ដំណើរទី ១ យ៉ាងណា ( ដំណើរទី ២ ) ក៏មិនផ្សេងគ្នា យ៉ាងនោះដែរ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអារម្មណប្បច្ច័យ គឺពួកហេតុ កើតឡើងព្រោះប្រារព្ធនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ធម៌

ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយហេតុ តែមិនមែនជាហេតុ កើតឡើង ព្រោះប្រារព្ធនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ គឺពួកហេតុក្តី ពួកសម្បយុត្ត-កក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ។

[ ១១៣ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកហេតុ កើតឡើងព្រោះធ្វើនូវហេតុ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃពួកសម្បយុត្តកហេតុ ដោយអធិបតិប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកខន្ធដែលប្រកបដោយហេតុ តែមិនមែនជាហេតុ កើតឡើងព្រោះធ្វើនូវហេតុ ឲ្យជាទីគោរព ។ ឯសហជា-តាធិបតិ គឺអធិបតិធម៌ ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី

ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវហេតុឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកហេតុផង ដោយអធិបតិប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សីល ... ធ្វើឧបោសថកម្ម ធ្វើនូវកុសលនោះឲ្យជាទីគោរព ហើយពិចារណា ក្នុងកាលមុន ... ចេញអំពីឈាន ធ្វើនូវឈានឲ្យជាទីគោរព ហើយពិចារណា ពួកព្រះអរិយៈចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ... ធ្វើនូវផលឲ្យជាទីគោរព ហើយពិចារណា បុគ្គលធ្វើនូវពួកខន្ធ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន ... ដូចជំណើរទី ១

ដែរ ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកហេតុ ដោយអធិបតិប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន ... ដូចដំណើរទី ១ ដែរ ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកហេតុផង ដោយអធិបតិប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកហេតុកើតឡើង ព្រោះធ្វើនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ឲ្យជាទីគោរព ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកខន្ធដែលប្រកបដោយហេតុ តែមិនមែនជាហេតុ កើតឡើង ព្រោះធ្វើនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ឲ្យជាទីគោរព ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ

ពួកហេតុក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះធ្វើនូវហេតុផង នូវពួកសម្បយុត្តកក្ខន្ធផង ឲ្យជាទីគោរព ។

[ ១១៤ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអនន្តរប្បច្ច័យ គឺពួកហេតុមុនៗ ជាបច្ច័យនៃពួកហេតុក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ គឺពួកហេតុមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអនន្តរប្បច្ច័យ គឺពួកហេតុមុនៗ ជាបច្ច័យនៃពួកហេតុក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: ។ សេចក្តីបង្រួញ ។ នេវសញ្ញានាសញ្ញាយតន: របស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង

ប្រកបដោយហេតុផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកហេតុក្រោយៗ ដោយអនន្តរប្បច្ច័យអនុលោម ( ជាបច្ច័យ ) នៃគោត្រភូ ។ សេចក្តីបង្រួញ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុផង ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអនន្ត-រប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកហេតុក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យអនុលោម ( ជាបច្ច័យ ) នៃគោត្រភូ ។ មូលកធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុក្តី វារៈ ៣ ក្តី ដូចគ្នានឹងវារៈ ១ ដែរ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអនន្តរប្បច្ច័យ គឺពួកហេតុមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកហេតុក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ គឺពួកហេតុមុនៗ ក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអនន្តរប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ ជាហេតុផង ដែលប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអនន្តរប្បច្ច័យ គឺ

ពួកហេតុមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកហេតុក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។

[ ១១៥ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយសហជាតប្បច្ច័យ ... ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺវារៈ ៣ ក្តី ពួកបច្ច័យក្តី ដូចហេតុប្បច្ច័យ ក្នុងបដិច្ចវារៈដែរ ។

[ ១១៦ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកហេតុ ជាបច្ច័យនៃពួកហេតុ ដោយឧបនិស្សយប្បច្ច័យ ។ ពួកហេតុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយឧបនិស្សយប្បច្ច័យ ។ ពួកហេតុជាបច្ច័យនៃពួកហេតុផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។ ពួកមូលនៃពួកប្រស្នាទាំងពីរនេះ បណ្ឌិតគប្បីសួរចុះ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ជំឡើងមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ... ។បេ។ អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យទាន ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។

សេចក្ដីប្រាថ្នា ជាបច្ច័យនៃសទ្ធា ។បេ។ នៃសេចក្ដីប្រាថ្នា ដោយឧបនិស្ស-យប្បច្ច័យ ។ ប្រស្នាទាំងពីរដ៏សេស បណ្ឌិតគប្បីឲ្យពិស្ដារ តាមហេតុនេះក្នុងមូលកៈ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុចុះ ។ ធម៌ជាហេតុក្ដី ប្រកបដោយហេតុក្ដី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្ដី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកហេតុក្ដី ពួកសម្បយុត្តកក្ខន្ធក្ដី ជាបច្ច័យនៃពួកហេតុ ដោយឧបនិស្សយប្បច្ច័យ មូលទាំង ២ បណ្ឌិតគប្បីសួរចុះ ។ ពួកហេតុក្ដី ពួកសម្បយុត្តកក្ខន្ធក្ដី ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយឧបនិស្សយប្បច្ច័យ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ ។ ពួកហេតុក្ដី ពួកសម្បយុត្តកក្ខន្ធក្ដី ជាបច្ច័យនៃពួកហេតុផង នៃពួកសម្ប-យុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១១៧ ] ធម៌ជាហេតុក្ដី ប្រកបដោយហេតុក្ដី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអាសេវនប្បច្ច័យ គឺដូចជាអនន្តរប្បច្ច័យដែរ ។

[ ១១៨ ] ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

ឯនានាខណិកៈ គឺចេតនា ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយកម្មប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយកម្មប្បច្ច័យ បានដល់ សហ-ជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកហេតុ ដោយកម្មប្បច្ច័យ ។ ឯនានា-ខណិកៈ គឺចេតនាដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកវិបាកហេតុ ដោយកម្មប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនា ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកហេតុផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកហេតុផង ដោយកម្មប្បច្ច័យ ។

[ ១១៩ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយវិបាកប្បច្ច័យ គឺអលោភៈ ជាវិបាក ជាបច្ច័យនៃអទោសៈ និងអមោហៈ ដោយវិបាកប្បច្ច័យ អលោភៈក្នុងខណៈនៃបដិសន្ធិ ... ។ ព្រោះហេតុប្បច្ច័យយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។ បណ្ឌិតគប្បីកំណត់ជាវិបាកប្បច្ច័យ មានវារៈ ៩ ។

[ ១២០ ] ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអាហារប្បច្ច័យ គឺមានវារៈ ៣ ។

[ ១២១ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយឥន្ទ្រិយប្បច្ច័យ គឺបណ្ឌិតគប្បីកំណត់ថាឥន្ទ្រិយប្បច្ច័យផងចុះ ឯវារៈមាន ៩ ( ចប់ ) គ្រប់គ្រាន់ហើយ ។

[ ១២២ ] ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយឈានប្បច្ច័យ គឺមានវារៈ ៣ ។

[ ១២៣ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយមគ្គប្បច្ច័យ ជាបច្ច័យ ដោយសម្ប-យុត្តប្បច្ច័យ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ ជាបច្ច័យ ដោយនត្ថិប្បច្ច័យ ជាបច្ច័យ ដោយវិគតប្បច្ច័យ ជាបច្ច័យ ដោយអវិគតប្បច្ច័យ ។

[ ១២៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ

មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ១២៥ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហ-ជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយ

អារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយហេតុ តែមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុផង ប្រកបដោយហេតុផង ទាំងប្រកបដោយហេតុ តែមិនមែនជាហេតុផង ដោយអារម្ម-ណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្ស-យប្បច្ច័យ ។

[ ១២៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### បច្ចនីយៈ ចប់

[ ១២៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។ ... ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### អនុលោមបច្ចនីយៈ ចប់

[ ១២៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុង

កម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

ហេតុសហេតុកទុកៈ ចប់

# ហេតុហេតុសម្បយុត្តទុកៈ

[ ១២៩ ] ធម៌ជាហេតុក្តី ប្រកបដោយហេតុក្តី អាស្រ័យនូវធម៌ជាហេតុផង ប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអទោសៈនិងអមោហៈ អាស្រ័យនូវអលោភៈ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ មោហៈអាស្រ័យនូវលោភៈ ។ បណ្ឌិត គប្បីចងជាចក្កៈចុះ ។ ក្នុងខណៈនៃបដិសន្ធិ ... ។ ហេតុចេវសហេតុកទុកៈយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ មិនមានការធ្វើផ្សេងៗ គ្នាឡើយ ។

ហេតុហេតុសម្បយុត្តទុកៈ ចប់

## នហេតុសហេតុកទុកៈ

[ ១៣០ ] ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ នូវខន្ធ ២ ... ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី អាស្រ័យនូវធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។បេ។ គឺមហាភូត ៣ អាស្រ័យនូវមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធមិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុក្តី

ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី អាស្រ័យនូវធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធមិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុផង មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុផង មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុផង មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង នូវពួកមហាភូត

ផង ។

[ ១៣១ ] ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺនូវខន្ធ ១ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុផង មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ សេចក្តីបង្រួញ ។ បណ្ឌិតគប្បីចែកយ៉ាងនេះចុះ ។

[ ១៣២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យមានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបង្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ១៣៣ ] ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ នូវខន្ធ ២ ... ។ បដិសន្ធិមានវេហូតដល់ពួកអសញ្ញសត្វ ឯមោហៈមិនមានទេ ។

[ ១៣៤ ] ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង

ព្រោះនអារម្មណប្បច្ច័យ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ក្នុងខណៈនៃបដិសន្ធិ ... រហូតដល់ពួកអសញ្ញសត្វ ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រកបដោយហេតុផង មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ... ។ សេចក្តីបង្រួញ ។

[ ១៣៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយៈ ចប់

[ ១៣៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ និងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ១៣៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ សេចក្តីបង្រួញ ... ក្នុងអាហារប្បច្ច័យ មានវារៈ ១ ក្នុងឈានប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយានុលោម ចប់

ឯក្នុងសហជាតវារៈ បណ្ឌិតគប្បីរាប់យ៉ាងនេះដែរ ។

# បច្ចយវារៈ

[ ១៣៨ ] ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ពឹងផ្អែកនឹងធម៌

មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ពឹងផ្អែកនឹងធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ពឹងផ្អែកនឹងធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធមិនមែនជាហេតុ តែប្រកបដោយហេតុ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី ពឹងផ្អែកនឹងធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធមិនមែនជាហេតុ តែប្រកបដោយហេតុ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូបពឹងផ្អែកនឹងពួកមហាភូត ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ពឹងផ្អែកនឹងធម៌មិនមែនជាហេតុ តែប្រកបដោយហេតុផង មិនមែនជាហេតុ ទាំងប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺតំណ មានវារៈ ៣ បវត្តិប្បដិសន្ធិ ( ចប់ ) បរិបូណ៌ ។ សេចក្តីបង្រួញ ។

[ ១៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

អនុលោម ចប់

[ ១៤០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបន្រ្ទញ ។ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

បច្ចនីយៈ ចប់

និស្សយវារៈ ដូចគ្នានឹងបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ១៤១ ] ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ប្រឡំនឹងធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ១ មិនមែនជាហេតុ តែប្រកបដោយហេតុ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

អនុលោម ចប់

[ ១៤៣ ] ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ប្រឡំនឹងធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺនឹងខន្ធ ១ មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ... ពួកខន្ធមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១៤៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

បច្ចនីយៈ ចប់

ការរាប់ ២ យ៉ាងដ៏សេស បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

សម្បយុត្តវារៈ ដូចគ្នានឹងសំសដ្ឋវារៈដែរ ។

## បញ្ហាវារៈ

[ ១៤៥ ] ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ពិចារណានូវកុសលនោះ ពិចារណានូវពួកកុសលដែលធ្លាប់សន្សំហើយ ក្នុងកាលមុន នូវឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល នូវពួកកិលេសដែលលះបង់ហើយ ... នូវពួកកិលេសដែលសង្កត់សង្កិនហើយ ... ក្នុងកាលមុន ... នូវពួកខន្ធ មិនមែនជាហេតុ តែប្រកបដោយហេតុ ថាមិនទៀង ... ទោមនស្សក៏កើតឡើង កាលកុសល និងអកុសលរលត់ហើយ វិបាកដែលមិនមែនជាហេតុ តែប្រកបដោយហេតុក៏កើតឡើង ព្រោះកុសល និងអកុសល

នោះជាអារម្មណ៍ បុគ្គលដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយនហេតុកចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ ពួកខន្ធមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកខន្ធមិនមែនជាហេតុ តែប្រកបដោយហេតុ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធមិនមែនជាហេតុ តែប្រកបដោយហេតុ ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ គឺនូវពួកខន្ធ មិនមែនជាហេតុ តែប្រកបដោយហេតុ ថាមិនទៀង ... ទោមនស្ស ក៏កើតឡើង កាលកុសល និងអកុសល រលត់ហើយ វិបាកមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក៏កើតឡើង ព្រោះកុសល និងអកុសលនោះជាអារម្មណ៍ ពួកខន្ធមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ គឺព្រះនិព្វាន ជាបច្ច័យនៃការពិចារណា ដោយអារម្មណប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ... នូវពួកខន្ធ មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ថាមិនទៀង ... ទោមនស្សក៏កើតឡើង កាលកុសល និងអកុសល រលត់ហើយ

វិបាកមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ក៏កើតឡើង ព្រោះកុសល និងអកុសលនោះជាអារម្មណ៍ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកខន្ធមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ... នូវពួកខន្ធមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាមិនទៀង ... ទោមនស្សក៏កើតឡើង កាលកុសល និងអកុសល រលត់ហើយ វិបាកមិនមែនជាហេតុ តែប្រកបដោយហេតុ ក៏កើតឡើង ព្រោះកុសល និងអកុសលនោះ ជាអារម្មណ៍ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយនហេតុអហេតុកចិត្ត ដោយចេតោបរិយញ្ញាណ ពួកខន្ធ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ។

[ ១៤៦ ] ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌

មិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើនូវកុសលនោះឲ្យជាទីគោរព ហើយពិចារណា ពិចារណា នូវពួកកុសលដែលសន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ធ្វើនូវឈាន ឲ្យជាទីគោរព ហើយពិចារណា ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវផល ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើងព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកចិត្ត-សមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ ធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ តែប្រកបដោយហេតុផង មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិ-បតិប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យ

នៃធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ឯព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ... បុគ្គលធ្វើនូវពួកខន្ធដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគ:កើតឡើង ព្រោះធ្វើនូវខន្ធនោះឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។

[ ១៤៧ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ សេចក្ដីបង្រួញ នេវសញ្ញានាសញ្ញាយតន: ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ គឺចុតិចិត្ត ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ ភវង្គ:ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃការពិចារណា ភវង្គ:ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ( ជាបច្ច័យ ) នៃភវង្គ: ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ

ជាបច្ច័យនៃវដ្ឋាន: ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ ការពិចារណា ជាបច្ច័យនៃពួកបញ្ចវិញ្ញាណ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ គឺចុតិចិត្ត ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ ការពិចារណា ជាបច្ច័យនៃពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃវដ្ឋាន: ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអនន្តរប្បច្ច័យ ។

[ ១៤៨ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយសមនន្តរប្បច្ច័យ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺតំណមិនមានក្នុងទីនេះទេ មានតែប្រស្នា ៧ ប្រការ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានប្រស្នា ៦ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានតែបវត្តិប្បដិសន្ធិ និងប្រស្នា ៧ តំណ

មិនមានក្នុងទីនេះទេ ។

[ ១៤៩ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យទាន សេចក្តីបន្រ្ទញ ដំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ... ។បេ។ បុគ្គលអាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យទាន ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេចក្តីប្រាថ្នាជាបច្ច័យនៃសទ្ធា ។បេ។ នៃសេចក្តីប្រាថ្នា មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺសទ្ធាជាបច្ច័យនៃកាយិកសុខ និងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ សីល ។បេ។ សេចក្តីប្រាថ្នា ជាបច្ច័យនៃកាយិកសុខ និងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ សទ្ធា ។បេ។ សេចក្តីប្រាថ្នា ជាបច្ច័យនៃកាយិកសុខ និងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺកាយិកសុខ ជាបច្ច័យនៃកាយិកសុខ និងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ

កាយិកទុក្ខ ... រដូវ ... ភោជន ... សេនាសនៈជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ កាយិកសុខ កាយិកទុក្ខ រដូវ ភោជន សេនាសនៈ ជាបច្ច័យនៃកាយិកសុខ និងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវកាយិកសុខ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ កាយិកទុក្ខ ... រដូវ ... ភោជន ... បុគ្គលអាស្រ័យនូវសេនាសនៈ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ កាយិកសុខ ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ១៥០ ] ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ទោមនស្សកើតឡើង កាលកុសល និងអកុសលរលត់ហើយ វិបាកដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ក៏កើតឡើង ព្រោះកុសល និងអកុសលនោះជាអារម្មណ៍ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យ

នៃពួកខន្ធដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយបុរេជាតប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ... នូវវត្ថុជាមិនទៀង ... ទោមនស្សកើតឡើង កាលកុសល និងអកុសលរលត់ហើយ វិបាកដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ក៏កើតឡើងព្រោះកុសល និងអកុសលនោះជាអារម្មណ៍ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយបុរេជាតប្បច្ច័យ ។

[ ១៥១ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយបច្ឆាជាតប្បច្ច័យ គឺពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយបច្ឆាជាតប្បច្ច័យ គឺពួកខន្ធ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៥២ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអាសេវនប្បច្ច័យ

គឺពួកខន្ធមុនៗ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអាសេវនប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអាសេវនប្បច្ច័យ ។

[ ១៥៣ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនា ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយកម្មប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយ

កម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនា ដែលមិនមែនជាហេតុ តែប្រកប ដោយហេតុ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលមិនមែនជាហេតុ ទាំងមិនប្រកប ដោយហេតុផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ធម៌ដែលមិនមែន ជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែ ប្រកបដោយហេតុផង ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺ ចេតនាដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកសម្ប-យុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកវិបា-កក្ខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយ កម្មប្បច្ច័យ បានដល់ សហជាត គឺចេតនាដែលមិនមែនជាហេតុ ទាំងមិន ប្រកបដោយហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋាន-រូបផង ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ចេតនា ដែលមិនមែនជា ហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួក កដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ១៥៤ ] ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជា បច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយវិបា-

កប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយវិបាកប្បច្ច័យ គឺមានវារៈ ១ ។

[ ១៥៥ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអាហារប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអាហារប្បច្ច័យ គឺពួកអាហារ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ កពឡីការាហារជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ ។

[ ១៥៦ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ រូបជីវិតិន្ទ្រិយជាបច្ច័យនៃកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ។

[ ១៥៧ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយឈានប្បច្ច័យ គឺបទទាំង ៤ បណ្ឌិតគប្បីធ្វើផងចុះ ។ ជាបច្ច័យដោយមគ្គប្បច្ច័យ គឺមានវារៈ ៣ ។

[ ១៥៨ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ( ជាបច្ច័យ ) នៃខន្ធ ៣ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ( ជាបច្ច័យ ) នៃខន្ធ ៣ ... បដិសន្ធិ ។

[ ១៥៩ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ឯបច្ឆាជាត គឺពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយវិប្ប-

យុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយវិប្ប-យុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៦០ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ( ជាបច្ច័យ ) នៃខន្ធ ៣ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយ

ហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ បេយ្យាលៈ ។ ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែន ជាហេតុ តែប្រកបដោយហេតុផង ដែលមិនមែនជាហេតុ ទាំងមិនប្រកប ដោយហេតុផង ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលមិនមែនជាហេតុ តែ ប្រកបដោយហេតុ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមែនជាហេតុ ទាំង មិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកប ដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលមិនមែនជាហេតុ ទាំងមិន ប្រកបដោយហេតុ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយ អត្ថិប្បច្ច័យ រហូតដល់ពួកអសញ្ញសត្វ ( ក៏ដូចគ្នាដែរ ) ។ បុរេជាត គឺនូវ ចក្ខុ ... នូវវត្ថុ ជាមិនទៀង ... ទោមនស្សកើតឡើង រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ចក្ខា- យតនៈ ... កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួក ខន្ធ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ( ជា បច្ច័យ ) នៃកាយនេះ ដែលកើតមុន កពឡីការាហារ ( ជាបច្ច័យ ) នៃ កាយនេះ រូបជីវិតិន្ទ្រិយជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ធម៌

ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យនៃពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺ ... នូវវត្ថុ ថាមិនទៀង ... ទោមនស្សកើតឡើង កាលកុសល និងអកុសលរលត់ហើយ វិបាកដែលមិនមែនជាហេតុ តែប្រកបដោយហេតុ កើតឡើងព្រោះកុសល និងអកុសលនោះ ជាអារម្មណ៍ ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ... ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី កពឡីការាហារក្តី ជាបច្ច័យ

នៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកជត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ១៦១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ១៦២ ] ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជា

បច្ច័យ ដោយកម្មប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ធម៌ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌ដែលមិនមែនជាហេតុ ទាំងមិន

ប្រកបដោយហេតុក្តី ជាបច្ច័យនៃធម៌ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ១៦៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។ សេចក្តីបន្រ្ទញ ។ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### បច្ចនីយៈ ចប់

[ ១៦៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ព្រោះអារម្មណប្បច្ច័យ ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

### អនុលោមប្បច្ចនីយៈ ចប់

[ ១៦៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ...

ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិត គប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

នហេតុសហេតុកទុកៈ ចប់

# សប្បច្ចយទុកៈ

## បដិច្ចវារៈ

[ ១៦៦ ] ធម៌ដែលប្រកបដោយបច្ច័យ អាស្រ័យនូវធម៌ដែលប្រកបដោយបច្ច័យ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយបច្ច័យ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។

[ ១៦៧ ] ធម៌ដែលប្រកបដោយបច្ច័យ អាស្រ័យនូវធម៌ ដែលប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ សេចក្តីបង្រួញ ។ ព្រោះអវិគតប្បច្ច័យ ។

[ ១៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ។ សេចក្តីបង្រួញ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

អនុលោម ចប់

[ ១៦៩ ] ធម៌ដែលប្រកបដោយបច្ច័យ អាស្រ័យនូវធម៌ ដែលប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ដែលប្រកបដោយបច្ច័យ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ដរាបដល់ពួកអសញ្ញសត្វ មោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ សេចក្តីបង្រួញ ។

[ ១៧០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

## បច្ចនីយៈ ចប់

[ ១៧១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ សេចក្តីបង្រួញ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ១៧២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ សេចក្តីបង្រួញ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

## បច្ចនីយានុលោម ចប់

សហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ១៧៣ ] ធម៌ដែលប្រកបដោយបច្ច័យ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយបច្ច័យ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយបច្ច័យ វត្ថុ ពឹងផ្អែកនឹងពួកខន្ធក្នុងខណៈនៃបដិសន្ធិ ពួកខន្ធពឹងផ្អែកនឹងវត្ថុ មហាភូត ១ ... ពួកខន្ធ ដែលប្រកបដោយបច្ច័យ ពឹងផ្អែកនឹងវត្ថុ ។

[ ១៧៤ ] ធម៌ដែលប្រកបដោយបច្ច័យ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ សេចក្តីបង្រួញ ។

បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។ ក្នុងវារៈទាំងអស់ មានប្រស្នាតែមួយគត់ ។

## បញ្ហាវារៈ

[ ១៧៥ ] ធម៌ដែលប្រកបដោយបច្ច័យ ជាបច្ច័យនៃធម៌ ដែលប្រកបដោយបច្ច័យ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយបច្ច័យ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១៧៦ ] ធម៌ដែលប្រកបដោយបច្ច័យ ជាបច្ច័យនៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល

ឧបោសថកម្ម ... ពិចារណានូវកុសលនោះ ពិចារណានូវពួកកុសល ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ហើយពិចារណានូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល នូវពួកកិលេសដែលលះបង់ហើយ ... ពិចារណានូវពួកកិលេស ដែលសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន នូវចក្ខុ ... នូវវត្ថុ ... នូវពួកខន្ធដែលប្រកបដោយបច្ច័យ ថាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលដែលប្រកបដោយចិត្ត ដែលប្រកបដោយបច្ច័យ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ និងអាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពួកខន្ធដែលប្រកបដោយបច្ច័យ ជាបច្ច័យនៃការពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌ដែលមិនមែនជាបច្ច័យ ជាបច្ច័យនៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ ។

[ ១៧៧ ] ធម៌ដែលប្រកបដោយបច្ច័យ ជាបច្ច័យនៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជា-

តាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សីល ... ឧបោសថកម្ម ... ធ្វើនូវកុសលនោះឲ្យជាទីគោរព ហើយពិចារណា ក្នុងកាលមុន ... អំពីឈាន ... ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា នូវផលឲ្យជាទីគោរព ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គលធ្វើនូវពួកខន្ធ ដែលប្រកបដោយបច្ច័យ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើងព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ដែលប្រកបដោយបច្ច័យ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ធម៌ដែលមិនមែនជាបច្ច័យ ជាបច្ច័យនៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺពួកព្រះអរិយៈ ធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ ។

[ ១៧៨ ] ធម៌ដែលប្រកបដោយបច្ច័យ ជាបច្ច័យនៃធម៌ ដែលប្រកបដោយបច្ច័យដោយអនន្តរប្បច្ច័យ ។ សេចក្តីបង្រួញ ។ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ គឺមានបញ្ហា ២ ជាមូលនៃឧបនិស្សយប្បច្ច័យ ។ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ សេចក្តីបង្រួញ ។ ជាបច្ច័យដោយអវិគតប្បច្ច័យ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានបញ្ហាមួយ ។

[ ១៧៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១

ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ១៨០ ] ធម៌ដែលប្រកបដោយបច្ច័យ ជាបច្ច័យនៃធម៌ដែលប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ធម៌ដែលមិនមែនជាបច្ច័យ ជាបច្ច័យនៃធម៌ដែលប្រកបដោយបច្ច័យដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១៨១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ។ សេចក្តីបង្រួញ ។ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ១៨២ ] ក្នុងនអារម្មណបច្ច័យ មានវារៈ ១ ព្រោះហេតុបច្ច័យ ... ក្នុងនអធិបតិបច្ច័យ មានវារៈ ១ ក្នុងនអនន្តរបច្ច័យ មានវារៈ ១ ក្នុងនសមនន្តរបច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញបច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយបច្ច័យ មានវារៈ ១ សេចក្តីបង្រួញ ... ក្នុងនសម្បយុត្តបច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តបច្ច័យ មានវារៈ ១ ក្នុងនោនត្ថិបច្ច័យ មានវារៈ ១ ក្នុងនោវិគតបច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

អនុលោមបច្ចនីយៈ ចប់

[ ១៨៣ ] ក្នុងអារម្មណបច្ច័យ មានវារៈ ២ ព្រោះនហេតុបច្ច័យ ... ក្នុងអធិបតិបច្ច័យ មានវារៈ ២ ក្នុងអនន្តរបច្ច័យ មានវារៈ ១ សេចក្តីបង្រួញ ... ក្នុងឧបនិស្សយបច្ច័យ មានវារៈ ២ ក្នុងបុរេជាតបច្ច័យ មានវារៈ ១ សេចក្តីបង្រួញ ... ក្នុងអវិគតបច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

សប្បច្ចយទុកៈ ចប់

# សង្ខតទុកៈ

## បដិច្ចវារៈ

[ ១៨៤ ] *សង្ខតធម៌ ( ធម៌ដែលមានបច្ច័យតាក់តែង ) អាស្រ័យនូវសង្ខតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសង្ខតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សប្បច្ចយទុកៈ ដូចទុកៈនេះដែរ បណ្ឌិតគប្បីធ្វើនូវទុកៈនេះ ឲ្យដូចសប្បច្ចយទុកៈចុះ មិនមានការធ្វើឲ្យផ្សេងគ្នាទេ ។*

*សង្ខតទុកៈ ចប់*

# សនិទស្សនទុកៈ

## បដិច្ចវារៈ

[ ១៨៥ ] អនិទស្សនធម៌ ( ធម៌ដែលមិនប្រកបដោយការឃើញ ) អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបជាអនិទស្សនៈក្តី អាស្រ័យនូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី កដត្តារូបជាអនិទស្សនៈក្តី អាស្រ័យនូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ ... វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... ចិត្តសមុដ្ឋានរូបជាអនិទស្សនៈ កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សនិទស្សនធម៌ ( ធម៌ដែលប្រកបដោយការឃើញ ) អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបជាសនិទស្សនៈ អាស្រ័យនូវពួកខន្ធ ជាអនិទស្សនៈ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សនិទស្សនធម៌ក្តី អនិទស្សនធម៌ក្តី អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបជាសនិទស្សនៈ និងអនិទស្សនៈក្តី អាស្រ័យនូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូបជាសនិទស្សនៈ និងអនិទស្សនៈ កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។

[ ១៨៦ ] អនិទស្សនធម៌ អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ ។

[ ១៨៧ ] អនិទស្សនធម៌ អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបជាអនិទស្សនៈក្តី អាស្រ័យនូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ ... មហាភូត ៣ អាស្រ័យនូវមហាភូត ១ នូវមហាភូត ២ ... ចិត្តសមុដ្ឋានរូបជាអនិទស្សនៈ និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សនិទស្សនធម៌ អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ អាស្រ័យនូវពួកខន្ធជាអនិទស្សនៈ ចិត្តសមុដ្ឋានរូបជាសនិទស្សនៈ និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សនិទស្សនធម៌ក្តី អនិទស្សនធម៌ក្តី អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបជាសនិទស្សនៈ និងអនិទស្សនៈក្តី អាស្រ័យនូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូបជាសនិទស្សនៈ និងអនិទស្សនៈ និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សេចក្តីបង្រួញ ។ បណ្ឌិតគប្បីធ្វើឲ្យគ្រប់បច្ច័យទាំងអស់ចុះ ។

[ ១៨៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបា-

កប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ១៨៩ ] អនិទស្សនធម៌ អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ខន្ធ ៣ គឺ ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈគឺ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាអនិទស្សនៈ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកបដិសន្ធិ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... ចិត្តសមុដ្ឋានរូបជាអនិទស្សនៈ កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ពាហិរ ... អាហារសមុដ្ឋាន ឧតុសមុដ្ឋាន របស់ពួកអសញ្ញសត្វ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ សនិទស្សនធម៌ អាស្រ័យនូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ចិត្តសមុដ្ឋានរូបជាសនិទស្សនៈ អាស្រ័យនូវពួកអហេតុកក្ខន្ធ ជាអនិទស្សនៈ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូបជាសនិទស្សនៈ និងឧបាទារូប អាស្រ័យនូវពួកមហាភូត របស់ពួក

អសញ្ញសត្វ ។ សនិទស្សនធម៌ក្តី អនិទស្សនធម៌ក្តី អាស្រ័យនូវអនិ-ទស្សនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងអនិទស្សនៈ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាអនិទស្សនៈ នូវខន្ធ ២ ... អាស្រ័យនូវពួកមហាភូត ក្នុងខណៈនៃបដិសន្ធិ ... ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... កដត្តារូបជាសនិទស្សនៈ និងអនិទស្សនៈ និងឧបាទារូប អាស្រ័យនូវពួកមហាភូតរបស់ពួកអសញ្ញសត្វ ។ បច្ច័យទាំងអស់ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយហេតុប្បច្ច័យ គឺពួកនោអាសវហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកអាសវៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃនោអាសវធម៌ ដោយហេតុប្បច្ច័យ គឺពួកអាសវហេតុក្តី ពួកនោអាសវហេតុក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ៣៨៤ ] អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអារម្មណប្បច្ច័យ គឺពួកអាសវៈកើតឡើង ព្រោះប្រារព្ធនូវពួកអាសវៈ ។ អាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអារម្មណប្បច្ច័យ គឺពួកនោអាសវក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកអាសវៈ ។ អាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអារម្មណប្បច្ច័យ គឺពួកអាសវក្ខន្ធក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកអាសវៈ ។ នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... អំពីឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកនោអាសវៈ នូវពួកកិលេស ដែលលះបង់ហើយ ... នូវពួកកិលេសដែលសង្កត់សង្កិនហើយ ... ដឹងនូវពួកកិលេសដែលសន្សំហើយ ក្នុងកាលមុន នូវចក្ខុ ... នូវវត្ថុ ... នូវពួកនោអាសវក្ខន្ធ ជាមិន

ទៀត ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយនោអាសវចិត្តដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពួកនោអាសវក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន ហើយត្រេកអរ រីករាយនឹងកុសលនោះ ពួកអាសវៈកើតឡើង ព្រោះប្រារព្ធនូវកុសលនោះ នូវសីល ... នូវឧបោសថកម្ម ... នូវឈាន ... នូវចក្ខុ ... នូវវត្ថុ ... ត្រេកអរ រីករាយនឹងពួកនោអាសវក្ខន្ធ ពួកអាសវៈកើតឡើង ព្រោះប្រារព្ធនូវពួកអាសវក្ខន្ធនោះ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ... ដូចដំណើរទី ២ ដែរ ត្រេកអរ រីករាយនឹងពួកនោអាសវក្ខន្ធ ពួកអាសវៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃអាសវធម៌ ដោយអារម្មណប្បច្ច័យ គឺពួកអាសវៈកើតឡើង ព្រោះប្រារព្ធនូវពួកអាសវៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃនោអាសវធម៌ ដោយអារម្មណប្បច្ច័យ គឺពួក

នោអាសវក្ខន្ធ កើតឡើងព្រោះប្រារព្ធនូវពួកអាសវៈផង នូវពួកសម្បយុត្ត-កក្ខន្ធផង ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអារម្មណប្បច្ច័យ គឺពួកអាសវៈក្តី ពួកសម្បយុត្ត-កក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវពួកអាសវៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។

[ ៣៤៥ ] អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកអាសវៈកើតឡើង ព្រោះធ្វើនូវពួកអាសវៈឲ្យជាទីគោរព មានវារៈ ៣ ។ គរុការម្មណ៍ ដូចគ្នានឹងអារម្មណប្បច្ច័យបណ្ឌិតគប្បីធ្វើចុះ ។ នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអធិ-បតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណា-ធិបតិ គឺ ( បុគ្គល ) នូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ក្នុងកាលមុន ... ពួកព្រះអរិយៈ អំពីមគ្គ ... នូវផល ... នូវព្រះនិព្វាន ឲ្យជាទីគោរព ... ឯព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យនូវចក្ខុ ... នូវវត្ថុ ... ធ្វើនូវពួកនោអាសវក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអររីករាយ រាគៈធ្វើនូវអាសវៈនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺនោអាសវាធិបតិធម៌ ជាបច្ច័យនៃពួកសម្ប-យុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នោអា-សវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណា-ធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) នូវទាន ... ធ្វើនូវពួកនោអាសវក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ពួកអាសវៈ

ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ។ សហជាតាធិបតិ គឺ នោអាសវាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកាសវៈ ដោយអធិបតិប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយ អធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្ម-ណាធិបតិ គឺ ( បុគ្គល ) នូវទាន ... ធ្វើនូវពួកនោអាសវក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវអាសវៈនោះ ឲ្យជាទីគោរព ទើបកើត ឡើង ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺនោអាសវាធិបតិធម៌ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកអាសវៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃអាសវ-ធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវពួក អាសវៈផង នូវពួកសម្បយុត្តកក្ខន្ធផង ឲ្យជាទីគោរពហើយត្រេកអរ ... ពួក អាសវៈកើតឡើង ។ មានវារៈ ៣ មានគរុការម្មណ៍ ។

[ ៣៤៦ ] អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអនន្តរប្បច្ច័យ គឺ ពួកអាសវៈមុនៗ ជាបច្ច័យនៃពួកអាសវៈក្រោយៗ ដោយអនន្តរប្បច្ច័យ ។ អាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអនន្តរប្បច្ច័យ គឺពួកអាសវៈ មុនៗ ជាបច្ច័យនៃនោអាសវក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកអាសវៈ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ផង នៃនោអាសវធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកអាសវៈមុនៗ ជា បច្ច័យនៃពួកអាសវៈក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្ត-

រប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោអាសវក្ខន្ធមុនៗ ជាបច្ច័យនៃពួកនោអាសវក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ និងផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោអាសវក្ខន្ធមុនៗ ជាបច្ច័យនៃពួកអាសវក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកនោអាសវក្ខន្ធមុនៗ ជាបច្ច័យនៃពួកអាសវៈក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃអាសវធម៌ ដោយអនន្តរប្បច្ច័យ គឺមានវារៈ ៣ ។ អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយសមនន្តរប្បច្ច័យ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៩ ។ ឯវត្ថុ បណ្ឌិតគប្បីសម្តែងចុះ ។

[ ៣៤៧ ] អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកអាសវៈ ជាបច្ច័យនៃពួកអាសវៈ ដោយឧបនិស្សយប្បច្ច័យ ហើយមានវារៈ ៣ ។ នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា

ហើយឲ្យទាន ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ... ។បេ។ អាស្រ័យនូវសេនាសនៈ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ... ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ ។បេ។ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយដំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ... ។បេ។ អាស្រ័យនូវសេនាសនៈ ហើយសម្លាប់សត្វ ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ ។បេ។ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃអាសវធម៌ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ហើយមានភារៈ ៣ ។

[ ៣៤៨ ] នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត

គឺនូវចក្ខុ ... នូវវត្ថុ ... បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកនោអាសវក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ... ត្រេកអរ រីករាយនឹងវត្ថុ ពួកអាសវៈកើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកអាសវៈ ដោយបុរេជាតប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលត្រេកអរ រីករាយនឹងចក្ខុ ពួកអាសវៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវចក្ខុនោះ ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកអាសវៈផង នៃពួកអាសវសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។

[ ៣៤៩ ] អាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកអាសវៈ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកនោអាសវក្ខន្ធ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃនោអាសវធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺ

ពួកអាសវៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣៥០ ] អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអាសេវនប្បច្ច័យ គឺមានវារៈ ៩ ។

[ ៣៥១ ] នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺនោអាសវចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺនោអាសវចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយកម្មប្បច្ច័យ គឺនោអាសវចេតនា ជាបច្ច័យនៃពួកសម្បយុត្តកាសវៈ ដោយកម្មប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយកម្មប្បច្ច័យ គឺនោអាសវចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកអាសវៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ៣៥២ ] នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ ១ ។

[ ៣៥៣ ] នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអាហារប្បច្ច័យ គឺពួកនោអាសវាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កពឡិង្ការាហារ ជាបច្ច័យនៃកាយ

នេះ ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។ នោអាសវធម៌ជាបច្ច័យនៃអាសវធម៌ ដោយអាហារប្បច្ច័យ គឺពួកនោអាសវាហារ ជាបច្ច័យនៃពួកសម្បយុត្តកាសវៈ ដោយអាហារប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអាហារប្បច្ច័យ គឺពួកនោអាស-វាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកអាសវៈផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ។

[ ៣៥៤ ] នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយឥន្ទ្រិ-យប្បច្ច័យ គឺពួកនោអាសវឥន្ទ្រិយ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ក្នុងខណៈនៃបដិសន្ធិ កាយិន្ទ្រិយ ជាបច្ច័យនៃកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិ-យប្បច្ច័យ ហើយមានវារៈ ៣ ។ ជាបច្ច័យដោយឈានប្បច្ច័យ គឺមានវារៈ ៣ ។ ជាបច្ច័យដោយមគ្គប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ ៩ ។

[ ៣៥៥ ] អាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកអាសវៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកអាសវៈ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត

បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកនោអាសវក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកនោអាសវក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បច្ឆាជាត គឺពួកនោអាសវក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុនដោយវិប្បយុត្តប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកអាសវៈ ដោយវិប្បយុត្តប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកអាសវៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃនោអាសវធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកអាសវៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកអាសវៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៥៦ ] អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអត្ថិប្បច្ច័យ គឺកាមាសវៈ ជាបច្ច័យនៃទិដ្ឋាសវៈ និងអវិជ្ជាសវៈ ដោយអត្ថិប្បច្ច័យ ។ ចក្កៈ ។ អាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត

និងបច្ឆាជាត ។ សហជាត គឺពួកអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកអាសវៈ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ អាសវៈ-ធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអត្ថិប្បច្ច័យ គឺកាមាសវៈ ជាបច្ច័យនៃទិដ្ឋាសវៈ និងអវិជ្ជាសវៈផង នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺនោអាសវក្ខន្ធ ១ ( ជាបច្ច័យ ) នៃខន្ធ ៣ រហូតដល់ពួកអសញ្ញសត្វ ។ បុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... នូវវត្ថុ ជាមិនទៀង ... ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកនោអាសវក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកនោអាសវក្ខន្ធ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ រូប-ជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺពួកនោអាសវក្ខន្ធ ជាបច្ច័យនៃពួកអាសវៈ ដោយអត្ថិប្បច្ច័យ ។

ឯបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... ត្រេកអរ រីករាយនឹងវត្ថុ ពួកអាសវៈ កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ វត្ថុ ជាបច្ច័យនៃពួកអាសវៈ ដោយអត្ថិប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺ នោអាសវក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកអាសវៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ ចក្ខុៈ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃអាសវធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហ-ជាត និងបុរេជាត ។ សហជាត គឺកាមាសវៈក្តី ពួកនោអាសវៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃទិដ្ឋាសវៈ និងអវិជ្ជាសវៈ ដោយអត្ថិប្បច្ច័យ ។ ចក្ខុៈ ។ កាមាសវៈក្តី វត្ថុក្តី ជាបច្ច័យនៃទិដ្ឋាសវៈ និងអវិជ្ជាសវៈ ដោយអត្ថិប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃនោអាសវធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺនោអាសវក្ខន្ធ ១ ក្តី ពួកអាសវៈក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ សហជាត គឺពួកអាសវៈក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកអាសវៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកនោអាសវក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកអាសវៈក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកអាសវៈក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យ

នៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហ-ជាត និងបុរេជាត ។ សហជាត គឺនោអាសវក្ខន្ធ ១ ក្តី កាមាសវៈក្តី ជាបច្ច័យនៃខន្ធ ៣ ទិដ្ឋាសវៈ និងអវិជ្ជាសវៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ សហជាត គឺកាមាសវៈក្តី វត្ថុក្តី ជាបច្ច័យនៃទិដ្ឋាសវៈ និងអវិជ្ជាសវៈផង នៃពួកសម្ប-យុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ។ បណ្ឌិតគប្បីចងជាចក្កៈចុះ ។

[ ៣៥៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបង្រួញ ។ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្ប-យុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

## អនុលោម ចប់

[ ៣៥៨ ] អាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអារម្មណប្បច្ច័យ

ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ អាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ អាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃនោអាសវធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នោអាសវធម៌ ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃអាសវធម៌ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ អាសវធម៌ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃនោអាសវធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ អាសវធម៌

ក្តី នោអាសវធម៌ក្តី ជាបច្ច័យនៃអាសវធម៌ផង នៃនោអាសវធម៌ផង ដោយ អារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ។

[ ៣៥៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ( ដូចគ្នា ) ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

## បច្ចនីយៈ ចប់

[ ៣៦០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។

## អនុលោមបច្ចនីយៈ ចប់

[ ៣៦១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ អនុលោមបទទាំងឡាយ ( ចប់ ) បរិបូណ៌ ( តែប៉ុណ្ណេះ ) ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

បច្ចនីយានុលោម ចប់

អាសវទុកៈ ចប់

# សាសវទុកៈ

## បដិច្ចវារៈ

[ ៣៦២ ] សាសវធម៌ ( ធម៌ដែលប្រកបដោយអាសវៈ ) អាស្រ័យនូវសាសវធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសាសវក្ខន្ធ ១ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ អនាសវធម៌ ( ធម៌ដែលមិនមានអាសវៈ ) អាស្រ័យនូវអនាសវធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអនាសវក្ខន្ធ ១ នូវខន្ធ ២ ... ។ សាសវធម៌ អាស្រ័យនូវអនាសវធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកអនាសវក្ខន្ធ ។ សាសវធម៌ក្តី អនាសវធម៌ក្តី អាស្រ័យនូវអនាសវធម៌ ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអនាសវក្ខន្ធ ១ នូវខន្ធ ២ ... ។ សាសវធម៌ អាស្រ័យនូវសាសវធម៌ផង នូវអនាសវធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកអនាសវក្ខន្ធផង នូវពួកមហាភូតផង ។ បណ្ឌិតគប្បីធ្វើនូវសាសវទុកៈ ឲ្យដូចគ្នានឹងលោកិយទុកៈ ក្នុងចូឡន្តរទុកៈចុះ មិនមានការធ្វើឲ្យប្លែកៗ គ្នាទេ ។

សាសវទុកៈ ចប់

# អាសវសម្បយុត្តទុកៈ
## បដិច្ចវារៈ

[ ៣៦៣ ] ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលប្រកបដោយអាសវៈ មោហៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយទោមនស្ស ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែល

ប្រកបដោយអាសវៈ នូវខន្ធ ២ ... ខន្ធ ៣ ក្តី មោហៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយទោមនស្ស នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រាសចាកអាសវៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ៣ អាស្រ័យនូវមហាភូត ១ មហាភូត ១ អាស្រ័យនូវមហាភូត ៣ មហាភូត ២ អាស្រ័យនូវមហាភូត ២ ... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី អាស្រ័យនូវធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវមោហៈ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយ

ទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយអាសវៈផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ ២ ... ។

[ ៣៦៤ ] ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈ អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី

មោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រាសចាកអាសវៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ពួកខន្ធអាស្រ័យនូវវត្ថុ ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ ២ ... ។

[ ៣៦៥ ] ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រាសចាកអាសវៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈដែលប្រកបដោយទោមនស្ស នូវមហាភូត ១ ... ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ធម៌ដែលប្រកបដោយអាសវៈ

អាស្រ័យនូវធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលច្រឡំដោយទោមនស្ស ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវមោហៈ ដែលច្រឡំដោយទោមនស្ស ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលច្រឡំដោយទោមនស្សផង នូវមោហៈផង នូវខន្ធ ២ ... ។ ខន្ធ ៣ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រាសចាកអាសវៈផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយទោមនស្សផង នូវមោហៈផង ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលច្រឡំដោយទោមនស្សផង នូវមោហៈផង នូវខន្ធ ២ ... ។ បច្ច័យទាំងអស់

បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។ សេចក្តីបង្រួញ ។

[ ៣៦៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងវិគតប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

## អនុលោម ចប់

[ ៣៦៧ ] ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣

ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ដែលប្រាសចាកអាសវៈ នូវខន្ធ ២ ... មានអហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ ។

[ ៣៦៨ ] ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយអាសវៈ ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រាសចាកអាសវៈ ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ វត្ថុ អាស្រ័យនូវពួកខន្ធ នូវមហាភូត ១ ... រហូតដល់ពួកអសញ្ញសត្វ ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្ត-សមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយអាសវៈផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង ។

[ ៣៦៩ ] ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។ សេចក្តីបង្រួញ ។

[ ៣៧០ ] ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យ

នូវខន្ធ ១ ដែលប្រកបដោយអាសវៈ ក្នុងអរូប នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺមោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ក្នុងអរូប ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយអាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនបុរេជា-តប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ក្នុងអរូប នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រាសចាកអាសវៈ ក្នុងអរូប នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រាសចាកអាសវៈ ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ មានបដិសន្ធិរហូតដល់ពួកអសញ្ញសត្វ ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ក្នុងអរូប ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ

គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង ក្នុងអរូប នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើងព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលប្រកបដោយអាសវៈផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង ។ មានវារៈ ២ ។ ព្រោះនបច្ឆាជាតប្បច្ច័យ គឺមានវារៈ ៩ ព្រោះនអាសេវនប្បច្ច័យ គឺមានវារៈ ៩ ។

[ ៣៧១ ] ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយអាសវៈ ។ ធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺវិប្បយុត្តកចេតនា អាស្រ័យនូវពួកខន្ធ ដែលប្រាសចាកអាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវមោហៈ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈផង នូវធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយ

ទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង ។ ព្រោះនវិបាកប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ នសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និង នោវិគតប្បច្ច័យ ។

[ ៣៧២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

**បច្ចនីយៈ ចប់**

[ ៣៧៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

**អនុលោមប្បច្ចនីយៈ ចប់**

[ ៣៧៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

បច្ចនីយានុលោម ចប់

សហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៣៧៥ ] ធម៌ដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ធម៌ដែលប្រាសចាកអាសវៈ ពឹងផ្អែកនឹងធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រាសចាកអាសវៈ នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមោហៈ ដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ក្នុងបដិសន្ធិក្ខណៈ វត្ថុ ពឹងផ្អែកនឹងពួកខន្ធ ពួកខន្ធពឹងផ្អែកនឹងវត្ថុ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ពួកខន្ធដែលប្រាសចាក

អាសវៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុបច្ច័យ គឺពួកខន្ធ ដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកសម្បយុត្តកក្ខន្ធ និងចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមោហៈដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពួកខន្ធដែលប្រកបដោយទោមនស្សក្តី មោហៈក្តី ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយអាសវៈផង នឹងធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយអាសវៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយអាសវៈផង នឹងធម៌ ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយអាសវៈផង នឹងពួក

មហាភូតផង ចិត្តសមុដ្ឋានរូបពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈផង នឹងមោហៈផង មោហៈដែលច្រឡំដោយទោមនស្ស ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយទោមនស្សផង នឹងវត្ថុផង ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយអាសវៈផង នឹងធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយអាសវៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូបពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយអាសវៈផង នឹងពួកមហាភូតផង ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈផង នឹងមោហៈផង នឹងខន្ធ ២ ... ខន្ធ ៣ ក្តី មោហៈក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលច្រឡំដោយទោមនស្សផង នឹងវត្ថុផង នឹងខន្ធ ២ ... ។

[ ៣៧៦ ] ធម៌ដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ធម៌ដែលប្រាសចាកអាសវៈ ពឹងផ្អែកនឹងធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រាសចាកអាសវៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ពួកខន្ធពឹងផ្អែកនឹងវត្ថុ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកខន្ធដែលប្រាសចាក

អាសវៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ពឹងផ្អែកនឹងធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលប្រកបដោយអាសវៈ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយអាសវៈផង នឹងធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយអាសវៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ។ ធម៌ដែលប្រាសចាកអាសវៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយអាសវៈផង នឹងធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈ ដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ នឹងវត្ថុផង ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ពឹងផ្អែកនឹងធម៌ដែលប្រកបដោយអាសវៈផង នឹងធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី

មោហៈក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ។ ព្រោះអធិបតិប្បច្ច័យ អនន្តរប្បច្ច័យ និងអវិគតប្បច្ច័យ ។

[ ៣៧៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

អនុលោម ចប់

[ ៣៧៨ ] ធម៌ដែលប្រាសចាកអាសវៈ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រាសចាកអាសវៈ ពឹងផ្អែកនឹងធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ដែលប្រាសចាកអាសវៈ នឹងខន្ធ ២ ... មានអហេតុកប្បដិសន្ធិដែរ រហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកអហេតុកក្ខន្ធដែលប្រាសចាកអាសវៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលប្រាសចាកអាសវៈ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយអាសវៈផង នឹងធម៌ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកប

ដោយវិចិកិច្ឆា ប្រឡូកដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រឡូកដោយវិចិកិច្ឆា ប្រឡូកដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សេចក្ដីបង្រួញ ។

[ ៣៧៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ ២ យ៉ាង ក្រៅពីនេះ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

ឯនិស្សយវារៈ ដូចគ្នានឹងបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ៣៨០ ] ធម៌ដែលប្រកបដោយអាសវៈ ប្រឡូកនឹងធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៨១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៦ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។

## អនុលោម ចប់

[ ៣៨២ ] ធម៌ដែលប្រាសចាកអាសវៈ ប្រឡំនឹងធម៌ ដែលប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ប្រឡំនឹងពួកខន្ធដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រាសចាកអាសវៈ ប្រឡំនឹងធម៌ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។បេ។

[ ៣៨៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ។

ការរាប់ ២ យ៉ាង ក្រៅពីនេះ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

ឯសម្បយុត្តវារៈ ដូចគ្នានឹងសំសដ្ឋវារៈដែរ ។

## បញ្ហាវារៈ

[ ៣៨៤ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយអាសវៈជា

បច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកអាសវៈ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ទោសៈ ជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកសម្បយុត្ត-កក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ទោសៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ មោហៈដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ មានបដិសន្ធិដែរ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ គឺមោហៈ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយហេតុប្បច្ច័យ គឺមោហៈដែលប្រឡំ

ដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ គឺទោសៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយហេតុប្បច្ច័យ គឺទោសៈក្តី មោហៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយហេតុប្បច្ច័យ គឺទោសៈក្តី មោហៈក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ៣៨៥ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយអាសវៈកើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយអាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រាសចាកអាសវៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយអាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈ

ផង ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើងព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយអាសវៈ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកអាសវៈ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គលឲ្យ ) នូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ហើយពិចារណានូវកុសលនោះ នូវពួកកុសលដែលសន្សំហើយ ក្នុងកាលមុន ... អំពីឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ នូវមគ្គ ... នូវផល ... នូវនិព្វាន ... ឯព្រះនិព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេសដែលប្រាសចាកអាសវៈ ដែលលះបង់ហើយ ពិចារណានូវពួកកិលេស ដែលសង្កត់សង្កិនហើយ ក្នុងកាលមុន ... នូវចក្ខុ ... នូវវត្ថុ ... ឃើញនូវពួកខន្ធ ដែលប្រាសចាកអាសវៈ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។ សេចក្តីត្រេកអរ មិនមានក្នុងពួកខន្ធនេះទេ ។ បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយចិត្ត ដែលប្រាសចាកអាសវៈ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពួកខន្ធដែលប្រាសចាកអាសវៈ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថា-

កម្មុបគញ្ញាណ និងអនាគតំសញ្ញាណ និងមោហៈ ដោយអារម្មណប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គលឲ្យ ) នូវទាន ... នូវសីល ... ធ្វើឧបោសថកម្ម ហើយត្រេកអរ រីករាយនឹងកុសលនោះ រាគៈកើតឡើងព្រោះប្រារព្ធនូវកុសលនោះ ទិដ្ឋិកើតឡើង វិចិកិច្ឆា ... ឧទ្ធច្ចៈ ... ទោមនស្ស កើតឡើង នូវពួកកុសលដែលសន្សំហើយ ក្នុងកាលមុន ... ចេញអំពីឈាន នូវឈាន ... នូវចក្ខុ ... នូវវត្ថុ ... ត្រេកអរ រីករាយ នឹងពួកខន្ធ ដែលប្រាសចាកអាសវៈ រាគៈ ព្រោះប្រារព្ធនូវខន្ធនោះ ... ទិដ្ឋិ ទោមនស្ស វិចិកិច្ឆា ... ឧទ្ធច្ចៈ កើតឡើង ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) នូវចក្ខុ ... នូវវត្ថុ ... ពួកខន្ធ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើងព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រាសចាកអាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយអាសវៈ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រាសចាកអាសវៈក្តី មោហៈក្តី កើតឡើង

ព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវមោហៈផង ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវមោហៈផង ។

[ ៣៨៦ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកខន្ធដែលប្រកបដោយអាសវៈ កើតឡើង ព្រោះធ្វើនូវពួកខន្ធដែលប្រកបដោយអាសវៈ ឲ្យជាទីគោរព ។ ៦ សហជាតាធិបតិ គឺអធិបតិធម៌ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកអាសវៈ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺអធិបតិធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ អធិបតិធម៌ ដែលប្រកបដោយទោមនស្ស ជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអធិបតិប្បច្ច័យ

បានដល់ សហជាត គឺអធិបតិធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ អធិបតិធម៌ ដែលប្រឡំដោយទោមនស្ស ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) ទាន ... សីល ... ធ្វើនូវឧបោសថកម្ម ឲ្យជាទីគោរព ហើយពិចារណានូវពួកកុសល ដែលបានសន្សំហើយ ក្នុងកាលមុន ... ចេញអំពីឈាន ឈាន ... ពួកព្រះអរិយៈ ចេញអំពីមគ្គ មគ្គ ... ផល ... ធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ឯព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ ។ ឯសហជាតាធិបតិ គឺ អធិបតិធម៌ ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ ( បុគ្គល ) ទាន ... សីល ... ធ្វើនូវឧបោសថកម្ម ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិក៏កើតឡើង ពួកកុសលដែលបានសន្សំហើយ ក្នុងកាលមុន ... អំពីឈាន ... ចក្ខុ ... វត្ថុ ... ធ្វើនូវពួកខន្ធ ដែលប្រាសចាកអាសវៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ

រាគៈ ធ្វើនូវពួកខន្ធនោះ ឲ្យជាទីគោរព ហើយកើតឡើង ទិដ្ឋិក៏កើតឡើង ។

[ ៣៨៧ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយអាសវៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា និងប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈក្រោយៗ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា និងប្រឡំដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលប្រកបដោយអាសវៈ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអនន្តរប្បច្ច័យ ។ ពួកខន្ធមុនៗ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា និងប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រឡំដោយទោមនស្សផង ប្រឡំដោយវិចិកិច្ឆាផង ប្រឡំដោយឧទ្ធច្ចៈផង និងមោហៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកអាសវៈ ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា និងប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈក្រោយៗ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈនិងមោហៈ ដោយអនន្តរប្បច្ច័យ ពួកខន្ធមុនៗ ដែលប្រាសចាកអាសវៈ

ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រាសចាកអាសវៈ ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ និងផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា និងប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា និងប្រកបដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ អាវជ្ជនា ( ការពិចារណា ) ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអាសវៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង ធម៌ដែលប្រាសចាកអាសវៈផង ដោយអនន្តរប្បច្ច័យ គឺមោហៈមុនៗ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា និងប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ និងមោហៈ ដោយអនន្តរប្បច្ច័យ អាវជ្ជនា ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ និងមោហៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា និងប្រកបដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ

ក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ ដែលប្រាសចាកអាសវៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រទូរ្ស់ដោយទោមនស្ស ប្រទូរ្ស់ដោយវិចិកិច្ឆា ប្រទូរ្ស់ដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃមោហៈក្រោយៗ ដែលប្រទូរ្ស់ដោយទោមនស្ស ប្រទូរ្ស់ដោយវិចិកិច្ឆា និងប្រទូរ្ស់ដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ពួកខន្ធ ដែលប្រទូរ្ស់ដោយទោមនស្ស ប្រទូរ្ស់ដោយវិចិកិច្ឆា ប្រទូរ្ស់ដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ និងធម៌ដែលប្រាសចាកអាសវៈ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រទូរ្ស់ដោយទោមនស្ស ប្រទូរ្ស់ដោយវិចិកិច្ឆា ប្រទូរ្ស់ដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រទូរ្ស់ដោយទោមនស្ស ប្រទូរ្ស់ដោយវិចិកិច្ឆា ប្រទូរ្ស់ដោយឧទ្ធច្ចៈ និងមោហៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយសមនន្តរប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ ៦ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៩ ។

[ ៣៨៨ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអាសវៈ

ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកខន្ធដែលប្រាសចាកអាសវៈ និងមោហៈ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង ធម៌ដែលប្រាសចាកអាសវៈផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រទាំដោយទោមនស្ស ប្រទាំដោយវិចិកិច្ឆា ប្រទាំដោយឧទ្ធច្ចៈ និងមោហៈ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យទាន នូវសីល ... ។បេ។ បញ្ញា កាយិកសុខ សេនាសនៈ ... អាស្រ័យនូវមោហៈ ហើយញុំាងសមាបត្តិ ឲ្យកើតឡើង សទ្ធា ។បេ។ បញ្ញា កាយិកសុខ កាយិកទុក្ខ និងមោហៈ ជាបច្ច័យនៃសទ្ធានិងមោហៈ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងមានះ ប្រកាន់

ទិដ្ឋិ សីល ... ។បេ។ បញ្ញា កាយិកសុខ កាយិកទុក្ខ រដូវ ភោជន សេនាសនៈ ... អាស្រ័យនូវមោហៈ ហើយសម្លាប់សត្វ ។បេ។ បំបែកសង្ឃ សទ្ធាក្តី មោហៈក្តី ជាបច្ច័យនៃរាគៈ ។បេ។ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង ធម៌ដែលប្រាសចាកអាសវៈផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺ សទ្ធា ... សីល ... មោហៈជាបច្ច័យនៃពួកខន្ធ ដែលប្រទូសរ៉ាយជាប់ដោយទោមនស្ស ប្រទូសរ៉ាយដោយវិចិកិច្ឆា ប្រទូសរ៉ាយដោយឧទ្ធច្ចៈ និងមោហៈ ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធដែលប្រទូសរ៉ាយដោយទោមនស្ស ប្រទូសរ៉ាយដោយវិចិកិច្ឆា ប្រទូសរ៉ាយដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយអាសវៈ ដោយឧបនិស្សយប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរចុះ ពួកខន្ធដែលប្រទូសរ៉ាយដោយទោមនស្ស ប្រទូសរ៉ាយដោយវិចិកិច្ឆា ប្រទូសរ៉ាយដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធដែលប្រាសចាកអាសវៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូប-

និស្ស័យ គឺពួកខន្ធដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយ ឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ៣៨៩ ] ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកអាសវៈ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... ឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺ ចក្ខ្វាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកខន្ធដែលប្រាសចាកអាសវៈផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... ត្រេកអរ រីករាយនឹងវត្ថុ រាគៈក៏កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ ។បេ។ ទោមនស្សកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអាសវៈ ដោយបុរេជាតប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈ

ផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ... ពួកខន្ធដែលប្រទូស្តដោយទោមនស្ស ប្រទូស្ត ដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈ និងមោហៈ កើតឡើងព្រោះប្រារព្ធនូវវត្ថុ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រទូស្តដោយទោមនស្ស ប្រទូស្ត ដោយវិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ ។

[ ៣៩០ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រាស ចាកអាសវៈ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធដែល ប្រកបដោយអាសវៈ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជា-តប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាក អាសវៈ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធដែលប្រាស ចាកអាសវៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយ បច្ឆាជាតប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាក អាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកខន្ធ ដែលប្រទូស្តដោយទោមនស្ស ប្រទូស្តដោយ វិចិកិច្ឆា ប្រទូស្តដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣៩១ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកប ដោយអាសវៈ ដោយអាសេវនប្បច្ច័យ គឺមានវារៈ ៩ ឯអាវជ្ជនាក្តី វុដ្ឋានៈ ក្តី មិនមានទេ ។

[ ៣៩២ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយកម្មប្បច្ច័យ គឺចេតនាដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ចេតនាដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយកម្មប្បច្ច័យ គឺចេតនាដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនាដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកអាសវៈ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រាសចាកអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានា

ខណិកៈ គឺចេតនាដែលប្រាសចាកអាសវៈ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៩៣ ] ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយវិបាកប្បច្ច័យ គឺមានវារៈ ១ ។

[ ៣៩៤ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយអាហារប្បច្ច័យ គឺពួកអាហារដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអាហារប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអាហារប្បច្ច័យ គឺអាហារដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអាហារប្បច្ច័យ ពួកអាហារដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង ធម៌ដែលប្រាសចាកអាសវៈផង ដោយអាហារប្បច្ច័យ គឺពួកអាហារ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ពួកអាហារដែលប្រឡំដោយទោមនស្ស ប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអាហារប្បច្ច័យ គឺពួកអាហារដែលប្រាសចាកអាសវៈ

ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ កពឡិង្ការាហារជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ ។

[ ៣៩៥ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ ៤ ជាបច្ច័យដោយឈានប្បច្ច័យ គឺមានវារៈ ៤ ជាបច្ច័យដោយមគ្គប្បច្ច័យ គឺមានវារៈ ៤ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ ៦ ។

[ ៣៩៦ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកចិត្ត-សមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធដែលប្រកបដោយអាសវៈ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធដែលប្រកបដោយអាសវៈ ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេ-

ជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធ ដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៩៧ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយអត្ថិប្បច្ច័យ គឺមានវារៈ ១ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកខន្ធដែលប្រកបដោយទោមនស្ស ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធ ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអត្ថិប្បច្ច័យ

គឺប្រហែលគ្នានឹងសហជាតបច្ច័យដែរ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សេចក្តីបង្រួញ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺមោហៈដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... ហើយត្រេកអរ រីករាយ នឹងវត្ថុ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆា ... ឧទ្ធច្ចៈ ... ទោមនស្ស កើតឡើង វត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអាសវៈ ដោយអត្ថិប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង ធម៌ដែលប្រាសចាកអាសវៈផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺមោហៈដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... ពួកខន្ធដែលច្រឡំដោយទោមនស្ស ច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ និងមោហៈប្រារព្ធនូវវត្ថុ ទើបកើតឡើង ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែល

ប្រកបដោយអាសវៈក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ដែលប្រទូំដោយទោមនស្ស ប្រទូំដោយវិចិកិច្ឆា ប្រទូំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេ-ជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកខន្ធដែលប្រកបដោយអាសវៈក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកខន្ធដែលប្រទូំដោយទោមនស្ស ប្រទូំដោយវិចិកិច្ឆា ប្រទូំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកខន្ធដែលប្រទូំដោយទោមនស្ស ប្រទូំដោយវិចិកិច្ឆា ប្រទូំដោយឧទ្ធច្ចៈក្តី វត្ថុក្តី ជាបច្ច័យនៃមោហៈ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលប្រកបដោយអាសវៈក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆា-ជាត គឺពួកខន្ធដែលប្រកបដោយអាសវៈក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេ-ជាត ។ សហជាត គឺខន្ធ ១ ដែលប្រទូំដោយទោមនស្ស ប្រទូំដោយវិចិកិច្ឆា ប្រទូំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។

[ ៣៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

## អនុលោម ចប់

[ ៣៩៩ ] ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រាសចាកអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ

ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ធម៌ដែលប្រាសចាកអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រាសចាកអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ធម៌ដែលប្រកបដោយ

អាសវៈក្តី ធម៌ដែលប្រាសចាកអាសវៈក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈផង នៃធម៌ដែលប្រាសចាកអាសវៈផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៤០០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

**បច្ចនីយៈ ចប់**

[ ៤០១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ សេចក្តីបង្រួញ ... ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ សេចក្តីបង្រួញ ... ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

**អនុលោមបច្ចនីយៈ ចប់**

[ ៤០២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ...

ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ សេចក្តីបង្រួញ អនុលោមគណនា ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

បច្ចនីយានុលោម ចប់

អាសវសម្បយុត្តទុកៈ ចប់

# អាសវសាសវទុកៈ

## បដិច្ចវារៈ

[ ៤០៣ ] ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋាសវៈ និងអវិជ្ជាសវៈ អាស្រ័យនូវកាមាសវៈ បណ្ឌិតគប្បីចងជាចក្កៈចុះ អវិជ្ជាសវៈ អាស្រ័យនូវភវាសវៈ បណ្ឌិតគប្បីចងជាចក្កៈចុះ អវិជ្ជាសវៈ អាស្រ័យនូវទិដ្ឋាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកអាសវៈ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋាសវៈ អវិជ្ជាសវៈ ពួកសម្បយុត្តកក្ខន្ធ និងចិត្តសមុដ្ឋានរូប អាស្រ័យនូវកាមាសវៈ នូវ

កវាសវៈ ... បណ្ឌិតគប្បីចងជាចក្កៈចុះ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ... ។ ធម៌ជាអាសវៈទាំងប្រកបដោយអាសវៈ អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកអាសវៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី អាស្រ័យនូវធម៌ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ពួកអាសវៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ នូវខន្ធ ២ ... ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋាសវៈ អវិជ្ជាសវៈ អាស្រ័យនូវកាមាសវៈផង នូវពួកសម្បយុត្តកក្ខន្ធផង បណ្ឌិតគប្បីចងជាចក្កៈយ៉ាងនេះចុះ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នូវធម៌ដែលប្រកប

ដោយអាសវៈ តែមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង នូវពួកអាសវៈផង នូវខន្ធ ២ ... ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ទិដ្ឋាសវៈក្តី អវិជ្ជាសវៈក្តី ចិត្ត-សមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង នូវកាមាសវៈផង នូវខន្ធ ២ ... ចក្កៈ ។ សេចក្តីបង្រួញ ។

បដិច្ចវារៈក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី មានប្រការយ៉ាងនេះឯង អាសវទុកៈយ៉ាងណា បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ មិនមានសេចក្តីផ្សេងគ្នាទេ ។

## បញ្ហាវារៈ

ក្នុងបញ្ហាវារៈ បណ្ឌិតមិនគប្បីធ្វើនូវលោកុត្តរ ក្នុងហេតុប្បច្ច័យ និងអារម្មណប្បច្ច័យទេ គប្បីធ្វើថា ពួកសេក្ខបុគ្គលពិចារណានូវគោត្រភូ ពិចា-រណានូវវោទានៈចុះ បើជីងបទទាំងអស់ ក្នុងអធិបតិប្បច្ច័យហើយ គប្បីធ្វើចុះ ។

[ ៤០៤ ] ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអនន្តរប្បច្ច័យ គឺពួកអាសវៈ

មុនៗ ជាបច្ច័យនៃពួកអាសវៈក្រោយៗ ដោយអនន្តរបច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអនន្តរបច្ច័យ គឺពួកអាសវៈមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអនន្តរបច្ច័យ ពួកអាសវៈជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរបច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ដោយអនន្តរបច្ច័យ គឺពួកអាសវៈមុនៗ ជាបច្ច័យនៃពួកអាសវៈក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរបច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអនន្តរបច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអនន្តរបច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ អាវជ្ជនាជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអនន្តរបច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអនន្តរបច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃពួកអាសវៈក្រោយៗ ដោយ

អនន្តរប្បច្ច័យ អាវជ្ជនាជាបច្ច័យនៃពួកអាសវៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈទាំងប្រកបដោយអាសវៈផង នៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃពួកអាសវៈក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ អាវជ្ជនាជាបច្ច័យនៃពួកអាសវៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអនន្តរប្បច្ច័យ គឺពួកអាសវៈមុនៗ ក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកអាសវៈក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអនន្តរប្បច្ច័យ គឺពួកអាសវៈមុនៗ ក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអនន្តរប្បច្ច័យ ពួកអាសវៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ ធម៌ជាអាសវៈទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ដោយ

អនន្តរប្បច្ច័យ គឺពួកអាសវៈមុនៗ ក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកអាសវៈក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។

បទទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។ ឯក្នុងអាសវទុកៈ អនន្តរប្បច្ច័យ បណ្ឌិតគប្បីធ្វើ ឲ្យដូចគ្នានឹងបច្ច័យនេះដែរ ។ អាវជ្ជនាក្តី វុដ្ឋានៈក្តី លោកបានសម្តែងហើយយ៉ាងនេះ ។ សេចក្តីបង្រួញ បទទាំងអស់ ចប់សព្វគ្រប់ហើយ បណ្ឌិតគប្បីធ្វើ ឲ្យដូចគ្នានឹងអាសវទុកៈចុះ មិនមានផ្សេងគ្នាទេ ។

អាសវសាសវទុកៈ ចប់

## អាសវអាសវសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ៤០៥ ] ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ទិដ្ឋាសវៈក្តី អវិជ្ជាសវៈក្តី អាស្រ័យនូវកាមាសវៈ បណ្ឌិតគប្បីចងជាចក្កៈចុះ អវិជ្ជាសវៈអាស្រ័យនូវភវាសវៈ ចក្កៈ អវិជ្ជាសវៈ អាស្រ័យនូវទិដ្ឋាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវពួកអាសវៈ ។ ធម៌ជាអាសវៈ ទាំងប្រកប

ដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋាសវៈក្តី អវិជ្ជាសវៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវកាមាសវៈ ដែលប្រកបដោយអាសវៈ ( បណ្ឌិតគប្បីចង ) ជាចក្កៈទាំងអស់ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ នូវខន្ធ ២ ... ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកអាសវៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី អាស្រ័យនូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ពួកអាសវៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ នូវខន្ធ ២ ... ។ ធម៌ជាអាសវៈទាំងប្រកបដោយអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺទិដ្ឋាសវៈ និងអវិជ្ជាសវៈ អាស្រ័យនូវកាមាសវៈផង នូវពួកសម្បយុត្តកក្ខន្ធផង ( ចង ) ជាចក្កៈទាំងអស់ចុះ ។

ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង នូវពួកអាសវៈផង នូវខន្ធ ២ ... ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នូវធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ទិដ្ឋាសវៈក្តី អវិជ្ជាសវៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង នូវកាមាសវៈផង នូវខន្ធ ២ ... ចក្កៈ ។ បច្ច័យទាំងអស់ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

[ ៤០៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ។ សេចក្តីបង្រួញ ។ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ឯវិបាកប្បច្ច័យ មិនមានវារៈទេ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤០៧ ] ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺនហេតុមូលកៈ មិនមានទេ ។ ព្រោះនបុរេជាតប្បច្ច័យ និងនបច្ឆាជា-

តប្បច្ច័យ ។ សេចក្តីបន្រ្ទញ ។

[ ៤០៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។ ការរាប់ទាំង ២ យ៉ាង ក្រៅពីនេះក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ( ចប់ ) បរិបូណ៌ហើយ ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បញ្ហាវារៈ

[ ៤០៩ ] ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។

[ ៤១០ ] ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ កើតឡើងព្រោះ

ប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈទាំងប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ គឺពួកអាសវៈ កើតឡើងព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ដោយអារម្មណប្បច្ច័យ គឺពួកអាសវៈក្តី ពួកអាសវសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ គឺមានវារៈ ៣ ។

អធិបតិប្បច្ច័យ មានគរុការម្មណ៍ ដូចគ្នានឹងអារម្មណប្បច្ច័យដែរ ។ អនន្តរប្បច្ច័យ ដូចគ្នានឹងអារម្មណប្បច្ច័យដែរ បណ្ឌិតគប្បីធ្វើដូចពាក្យថា ពួកខន្ធមុនៗ ចុះ ។ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ដូចគ្នានឹងអារម្មណប្បច្ច័យដែរ មិនមានការបែកទេ គ្រាន់តែមានវារៈ ៣ ឧបនិស្សយប្បច្ច័យទាំងអស់ បណ្ឌិតគប្បីធ្វើផងចុះ ។

[ ៤១១ ] ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយ

កម្មប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយអាហារប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ គឺមានវារៈ ៩ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ ៩ ជាបច្ច័យដោយអត្ថិប្បច្ច័យ ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ គឺមានវារៈ ៩ ។

[ ៤១២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤១៣ ] ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ

តែមិនមែនជាអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ

ក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈក្តី ធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក្តី ជាបច្ច័យនៃធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នៃធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៤១៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤១៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ សេចក្តីបង្រួញ ... ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៤១៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ អនុលោមបទទាំងឡាយ បណ្ឌិតគប្បីរាប់ផងចុះ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

**អាសវអាសវសម្បយុត្តទុកៈ ចប់**

# អាសវវិប្បយុត្តសាសវទុកៈ

## បដិច្ចវារៈ

[ ៤១៧ ] ធម៌ដែលប្រាសចាកអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវធម៌ ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ... ។ ធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមែនជាអាសវៈ អាស្រ័យនូវធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ។ លោកិយទុកៈ ក្នុងចូឡន្តរទុកៈយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះចុះ មិនមានការធ្វើឲ្យផ្សេងៗ គ្នាទេ ។ សេចក្តីបង្រួញ ។

### អាសវវិប្បយុត្តសាសវទុកៈ ចប់

# អភិធម្មបិដក

# បដ្ឋាន អដ្ឋមភាគ

## អនុលោមទុកបដ្ឋាន

## សញ្ញោជនទុកៈ

## បដិច្ចវារៈ

[ ១ ] សញ្ញោជនធម៌ ( ធម៌ដែលចងសត្វទុកក្នុងវដ្តៈ ) អាស្រ័យនូវសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ សីលព្វតបរាមាស-សញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ មានសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ អវិជ្ជា-សញ្ញោជនៈ អាស្រ័យនូវកាមរាគសញ្ញោជនៈ ឥស្សាសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវបដិឃសញ្ញោជនៈ មច្ឆរិយសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវបដិឃសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ អា-ស្រ័យនូវបដិឃសញ្ញោជនៈ ភវរាគសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អា-ស្រ័យនូវមានសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ អាស្រ័យភវរាគសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ អាស្រ័យនូវវិចិកិច្ឆាសញ្ញោជនៈ ។ នោសញ្ញោជនធម៌ ( ធម៌មិនមែនជាសញ្ញោជនៈ ) អាស្រ័យនូវសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកសញ្ញោជនៈ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី អាស្រ័យនូវ

សញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈ បណ្ឌិតគប្បីចងជាចក្កៈចុះ ។ នោសញ្ញោជនធម៌ អាស្រ័យនូវនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជានោសញ្ញោជនៈ នូវខន្ធ ២ ... វត្ថុអាស្រ័យនូវពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ... ។ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សញ្ញោជនធម៌ អាស្រ័យនូវនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសញ្ញោជនៈ អាស្រ័យនូវពួកនោសញ្ញោជនក្ខន្ធ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី អាស្រ័យនូវនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ពួកសញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជានោសញ្ញោជនៈ នូវខន្ធ ២ ... ។ សញ្ញោជនធម៌ អាស្រ័យនូវសញ្ញោជនធម៌ផង នូវនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី អាស្រ័យនូវកាមរាគសញ្ញោជនៈផង នូវពួកសម្បយុត្តកក្ខន្ធផង បណ្ឌិតគប្បីចងជាចក្កៈចុះ ។ នោសញ្ញោជនធម៌ អាស្រ័យនូវសញ្ញោជនធម៌ផង នូវនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តីអាស្រ័យនូវខន្ធ ១ ជានោសញ្ញោជនៈផង នូវពួកសញ្ញោជនៈផង នូវខន្ធ ២ ... ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី អាស្រ័យនូវ

សញ្ញោជនធម៌ផង នូវនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជានោសញ្ញោជនៈផង នូវកាមរាគសញ្ញោជនៈផង បណ្ឌិតគប្បីចងជាចក្កៈចុះ ។

ក្នុងអារម្មណប្បច្ច័យ មិនមានរូបទេ ។ ឯអធិបតិប្បច្ច័យដូចហេតុប្បច្ច័យដែរ មិនមានវិចិកិច្ឆាសញ្ញោជនៈទេ ។ ព្រោះអនន្តរប្បច្ច័យ ព្រោះអវិគតប្បច្ច័យ ។

[ ២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៣ ] សញ្ញោជនធម៌ អាស្រ័យនូវសញ្ញោជនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជាសញ្ញោជនៈ អាស្រ័យវិចិកិច្ឆាសញ្ញោជនៈ ។ នោសញ្ញោជនធម៌ អាស្រ័យនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ជានោសញ្ញោជនៈ នូវខន្ធ ២ ... រហូតដល់ពួកអសញ្ញសត្វ ។ សញ្ញោជនធម៌ អាស្រ័យនូវនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជាសញ្ញោជនៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ សញ្ញោជនធម៌ អាស្រ័យនូវសញ្ញោជនធម៌ផង នូវ

នោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជាសញ្ញោជនៈ អាស្រ័យវិចិកិច្ឆាសញ្ញោជនៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ សេចក្ដីបង្រួញ ។ ដូចអាសវគោច្ឆកៈដែរ ។ ឯនអារម្មណប្បច្ច័យទាំងអស់ បណ្ឌិត គប្បីរើឡើងផងចុះ ។

[ ៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ បទទាំងអស់ បណ្ឌិតគប្បីរាប់យ៉ាងនេះផងចុះ ។

[ ៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុង

អាហារប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្ប-យុត្តប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

កើតជាមួយនឹងសញ្ញោជនធម៌ ... ។

## បច្ច័យវារៈ

[ ៧ ] សញ្ញោជនធម៌ ពឹងផ្អែកនឹងសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចបដិច្ចវារៈដែរ ។ នោសញ្ញោជនធម៌ ពឹងផ្អែកនឹងនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោសញ្ញោជនក្ខន្ធ ១ នឹងខន្ធ ២ ... វត្ថុ ពឹងផ្អែកនឹងពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធពឹងផ្អែកនឹងវត្ថុ នឹងមហា-ភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ពួកនោសញ្ញោជនក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ សញ្ញោជនធម៌ ពឹងផ្អែកនឹងនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសញ្ញោជនៈ ពឹងផ្អែកនឹងពួកនោសញ្ញោជនក្ខន្ធ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ពឹងផ្អែកនឹងនោសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី សញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោសញ្ញោជនក្ខន្ធ ១ នឹងខន្ធ ២ ... ពួកសញ្ញោជនៈ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ។ សញ្ញោជនធម៌ ពឹងផ្អែកនឹងសញ្ញោជនធម៌ផង នឹងនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី

ពឹងផ្អែកនឹងកាមរាគសញ្ញោជនៈផង នឹងពួកសម្បយុត្តកក្ខន្ធផង ទិដ្ឋិសញ្ញោ-ជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពឹងផ្អែកនឹងកាមរាគសញ្ញោជនៈផង នឹងវត្ថុផង បណ្ឌិតគប្បីចងជាចក្កៈចុះ ។ នោសញ្ញោជនធម៌ ពឹងផ្អែកនឹងសញ្ញោជនធម៌ផង នឹងនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោសញ្ញោជនក្ខន្ធ ១ ផង នឹងពួកសញ្ញោជនៈផង នឹងខន្ធ ២ ... ( គប្បីចង ) ជាចក្កៈចុះ ពួកនោសញ្ញោ-ជនក្ខន្ធ ពឹងផ្អែកនឹងពួកសញ្ញោជនៈផង នឹងវត្ថុផង ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ពឹងផ្អែកនឹងសញ្ញោជនធម៌ផង នឹងនោសញ្ញោជនធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោសញ្ញោជនក្ខន្ធ ១ ផង នឹងកាមរាគសញ្ញោជនៈផង នឹងខន្ធ ២ ... ( គប្បីចង ) ជាចក្កៈចុះ ទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងកាមរាគសញ្ញោជនៈផង នឹងវត្ថុផង ( គប្បីចង ) ជាចក្កៈចុះ ។ សេចក្តីបង្រួញ ។

[ ៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ។ វត្ថុដែលបានត្រង់កន្លែងណាៗ បណ្ឌិតគប្បីធ្វើ មិនឲ្យផ្សេងគ្នាត្រង់កន្លែងនោះៗ ចុះ ។ ក្នុងនអារម្ម-

ណាបច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ ២ យ៉ាងក្រៅនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះផងចុះ ។

## សំសដ្ឋវារៈ

[ ១០ ] សញ្ញោជនធម៌ ប្រឡូកប្រឡំនឹងសញ្ញោជនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺទិដ្ឋិសញ្ញោជនៈក្តី អវិជ្ជាសញ្ញោជនៈក្តី ប្រឡូកប្រឡំនឹងកាមរាគសញ្ញោជនៈ ឯពួកអរូប មានប្រស្នា ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះឯង ។

## បញ្ហាវារៈ

[ ១១ ] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ជាសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកសញ្ញោជនៈ ដោយហេតុប្បច្ច័យ ។ សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកសញ្ញោជនៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នោសញ្ញោជនធម៌

ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជានោសញ្ញោជនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១២ ] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសញ្ញោជនៈ កើតឡើង ព្រោះប្រារព្ធនូវពួកសញ្ញោជនៈ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកនោសញ្ញោជនក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកសញ្ញោជនៈ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវពួកសញ្ញោជនៈ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ... ពិចារណានូវកុសលនោះ ពិចារណានូវពួកកុសលដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ពិចារណានូវឈាន ពួកព្រះអរិយៈចេញអំពីមគ្គ ពិចារណានូវមគ្គ នូវផល ... ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផល និងការពិចារណា ពួកព្រះអរិយៈ ( ពិចារណា ) នូវពួកសញ្ញោជនកិលេស ដែលលះបង់ហើយ ... នូវពួកកិលេសដែលសង្កត់សង្កិនហើយ ... ក្នុងកាលមុន ... នូវចក្ខុ នូវវត្ថុ ... នូវពួកនោសញ្ញោជនក្ខន្ធ ថាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយនោសញ្ញោជនចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ

អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយ-វិញ្ញាណ ពួកនោសញ្ញោជនក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និង អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យ នៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយនឹងពួកនោសញ្ញោជនក្ខន្ធ រាគៈ ប្រារព្ធនូវខន្ធនោះ ... ទោមនស្ស កើតឡើង ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយនឹងពួកនោសញ្ញោជនក្ខន្ធ ពួកសញ្ញោជនៈក្តី ពួកខន្ធប្រកប ដោយសញ្ញោជនៈក្តី កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ គឺ បណ្ឌិតគប្បីប្រារព្ធធ្វើ ឲ្យមានវារៈ ៣ ផងចុះ ។

[ ១៣ ] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអធិប-តិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវពួកសញ្ញោជនៈ ឲ្យជាទីគោរព ... មានវារៈ ៣ មានការធ្វើឲ្យជាទីគោរពជាអារម្មណ៍ ។ នោសញ្ញោ-ជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអធិបតិប្បច្ច័យ បានដល់

អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យនូវទាន នូវសីល ... មានវារៈ ៣ ។ អារម្មណាធិបតិ និងសហជាតាធិបតិ បណ្ឌិតគប្បីធ្វើ ( ដោយអំណាច ) នៃវារៈ ៣ ទាំងគប្បីចែកជាវារៈ ៣ ចុះ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវពួកសញ្ញោជនៈ និងពួកសម្បយុត្តកក្ខន្ធ ឲ្យជាទីគោរព ... មានវារៈ ៣ ។

[ ១៤ ] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសញ្ញោជនៈមុនៗ ជាបច្ច័យនៃពួកសញ្ញោជនៈក្រោយៗ ដោយអនន្តរប្បច្ច័យ មានវារៈ ៣ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោសញ្ញោជនក្ខន្ធមុនៗ ក្រោយ ... ។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោសញ្ញោជនក្ខន្ធមុនៗ នៃពួកសញ្ញោជនៈក្រោយៗ ... វារៈ ២ បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអនន្តរប្បច្ច័យ គឺមានវារៈ ៣ ។ សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយសមនន្តរប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៩ ។

[ ១៥ ] ... ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្ម-

ណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកសញ្ញោជនៈ ជាបច្ច័យនៃពួកសញ្ញោជនៈ ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ យ៉ាងនេះ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ជំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ... ។បេ។ នូវបញ្ញា នូវរាគៈ ។បេ។ នូវសេចក្តីប្រាថ្នា ... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈជាបច្ច័យនៃសទ្ធា ។បេ។ នៃផលសមាបត្តិដោយឧបនិស្សយប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធាហើយជំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ... ។បេ។ អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ ។បេ។ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយជំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ... ។បេ។ អាស្រ័យនូវ

សេនាសនៈ ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈជាបច្ច័យនៃពួកសញ្ញោជនៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយឧបនិស្សយប្បច្ច័យ គឺមានវារៈ ៣ ។

[ ១៦ ] នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកនោសញ្ញោជនក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... ត្រេកអរ រីករាយនឹងវត្ថុ រាគៈប្រារព្ធនូវវត្ថុនោះ ... ទោមនស្សកើតឡើង ។ វត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកសញ្ញោជនៈ ដោយបុរេជាតប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និង វត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... ត្រេកអរ

រិកកាយ នឹងវត្ថុ ពួកសញ្ញោជនៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវវត្ថុនោះ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកសញ្ញោជនៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។

[ ១៧ ] សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ ១ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨ ] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអាសេវនប្បច្ច័យ គឺមានវារៈ ៩ ។

[ ១៩ ] នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយកម្មប្បច្ច័យ គឺមានវារៈ ៣ ។ ជាបច្ច័យដោយវិបាកប្បច្ច័យ គឺមានវារៈ ១ ។ ជាបច្ច័យដោយអាហារប្បច្ច័យ គឺមានវារៈ ៣ ។ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ ៣ ។ ជាបច្ច័យដោយឈានប្បច្ច័យ គឺមានវារៈ ៣ ។ ជាបច្ច័យដោយមគ្គប្បច្ច័យ គឺមានវារៈ ៩ ។ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ ៩ ។

[ ២០ ] សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ បណ្ឌិតគប្បីចែកចុះ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ បណ្ឌិត គប្បីចែកចុះ ។

នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកសញ្ញោជនៈ ដោយវិប្បយុត្តប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកសញ្ញោជនៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ បណ្ឌិតគប្បីចែកចុះ ។

[ ២១ ] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ គឺមានវារៈ ១ ដូចគ្នានឹងបដិច្ចវារៈដែរ ។ សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ ។ សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអត្ថិប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈដែរ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សេចក្តីបង្រួញ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺពួកនោសញ្ញោជនក្ខន្ធ ជាបច្ច័យនៃពួកសម្បយុត្តកសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ ... ត្រេកអរ រីករាយនឹងវត្ថុ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សកើតឡើង វត្ថុ ជាបច្ច័យនៃពួកសញ្ញោជនៈ ដោយអត្ថិប្បច្ច័យ ។

នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺពួកនោសញ្ញោជនៈ ... សេចក្តីបង្រួញ ដូចគ្នានឹងអាសវៈដែរ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ ដូចគ្នានឹងអាសវៈដែរ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ បណ្ឌិតគប្បីចែកចុះ ដូចគ្នានឹងអាសវៈដែរ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ បណ្ឌិតគប្បីចែកចុះ ដូចគ្នានឹងអាសវៈដែរ ។

[ ២២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុង

វិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៣ ] សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។ សញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ។ សញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ។ នោសញ្ញោជនធម៌ ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជា-

តប្បច្ច័យ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃនោសញ្ញោជនធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ។ សញ្ញោជនធម៌ក្តី នោសញ្ញោជនធម៌ក្តី ជាបច្ច័យនៃសញ្ញោជនធម៌ផង នៃនោសញ្ញោជនធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ។ សេចក្តីបង្រួញ ។ ... ក្នុងនមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ២៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ អនុលោមមាតិកា ក្នុងអវិគតប្បច្ច័យ មាន

វារៈ ៩ ។

សញ្ញោជនទុកៈ ចប់

# សញ្ញោជនិយទុកៈ

## បដិច្ចវារៈ

[ ២៧ ] សញ្ញោជនិយធម៌ ( ធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ ) អាស្រ័យនូវសញ្ញោជនិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាសញ្ញោជនិយៈ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ... ។ ដូចគ្នានឹងលោកិយទុកៈ ក្នុងចូឡន្តរទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗ គ្នាទេ ។

សញ្ញោជនិយទុកៈ ចប់

# សញ្ញោជនសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ២៨ ] ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយសញ្ញោជនៈ នូវខន្ធ ២ ... ។ ធម៌

ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈ ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី អាស្រ័យនូវធម៌ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយសញ្ញោជនៈ នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រាសចាកសញ្ញោជនៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈដែលប្រឡំដោយឧទ្ធច្ចៈ មានបដិសន្ធិ ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈ ដែលប្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី អាស្រ័យនូវធម៌ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវមោហៈដែលប្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រឡំដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ ២ ... ។ ធម៌

ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយសញ្ញោជនៈផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលប្រកបដោយឧទ្ធច្ចៈផង នូវមោហៈផង ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី អាស្រ័យនូវធម៌ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ ២ ... ។

[ ២៩ ] ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺនូវខន្ធ ១ ដែលប្រកបដោយសញ្ញោជនៈ ... នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈដែលប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយសញ្ញោជនៈក្តី ធម៌ដែលប្រាសចាកសញ្ញោជនៈក្តី អាស្រ័យនូវធម៌ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយឧទ្ធច្ចៈ នូវខន្ធ ២ ... ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង

ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រាសចាកសញ្ញោជនៈ នូវខន្ធ ២ ... ពួកខន្ធអាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវមោហៈដែលប្រទូរំដោយឧទ្ធច្ចៈ ។ ធម៌ដែលប្រកបដោយសញ្ញោជនៈ អា-ស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រទូរំដោយឧទ្ធច្ចៈផង នូវមោហៈផង នូវខន្ធ ២ ... ។

[ ៣០ ] ធម៌ដែលប្រកបដោយសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រកបដោយសញ្ញោជនៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ ដែលប្រាសចាកសញ្ញោជនៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺមានវារៈ ១ ។ ធម៌ដែលប្រាសចាកសញ្ញោជនៈ អាស្រ័យនូវធម៌ដែលប្រកបដោយសញ្ញោជនៈផង នូវធម៌ដែលប្រាសចាកសញ្ញោជនៈផង ទើបកើតឡើង ព្រោះអធិ-បតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលប្រកបដោយសញ្ញោជនៈផង នូវពួកមហាភូតផង ។ សេចក្តីបង្រួញ ។

[ ៣១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុង

[ ១៣៧ ] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយកម្មប្បច្ច័យ គឺគន្ថសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិក: ។ សហជាត គឺគន្ថ-សម្បយុត្តចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ទិដ្ឋិ-គតវិប្បយុត្តលោភសហគតចេតនា ជាបច្ច័យនៃលោភ:ផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ទោមនស្សសហគតចេតនា ជាបច្ច័យនៃបដិឃ:ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិក: គឺគន្ថសម្បយុត្តចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយកម្មប្បច្ច័យ គឺគន្ថសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ទិដ្ឋិគតវិប្បយុត្តលោភសហគតចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃលោភ:ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ទោមនស្ស-សហគតចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបដិឃ:ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិក: ។ សហជាត គឺគន្ថវិប្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួក

ចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺគន្ថវិប្បយុត្ត-
ចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ១៣៨ ] គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយវិបា-
កប្បច្ច័យ គឺមានវារៈ ១ ។

[ ១៣៩ ] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយ
អាហារប្បច្ច័យ គឺមានវារៈ ៤ ។ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ គឺមាន
វារៈ ៤ ។ ជាបច្ច័យដោយឈានប្បច្ច័យ គឺមានវារៈ ៤ ។ ជាបច្ច័យ
ដោយមគ្គប្បច្ច័យ គឺមានវារៈ ៤ ។ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺ
មានវារៈ ៦ ។

[ ១៤០ ] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយវិប្ប-
យុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ បណ្ឌិត
ត្រូវចែកផងចុះ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយ
វិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សេចក្តី
បង្រួញ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយវិប្ប-
យុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកគន្ថសម្បយុត្តក្ខន្ធ ដោយ
វិប្បយុត្តប្បច្ច័យ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃ
គន្ថវិប្បយុត្តធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជា
បច្ច័យនៃពួកទិដ្ឋិគតវិប្បយុត្ត លោភសហគតក្ខន្ធផង នៃលោភៈផង នៃពួក
ទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយវិប្បយុត្តប្បច្ច័យ ។ គន្ថ-

សម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត ។ សហជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៤១ ] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ គឺមានវារៈ ១ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ បណ្ឌិតត្រូវចែកផងចុះ ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ គឺមានវារៈ ១ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សេចក្តីបង្រួញ បណ្ឌិតត្រូវចែកផងចុះ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ ទោមនស្សសហគតបដិឃៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺបុគ្គល ត្រេកអរ

រីករាយ នឹងចក្ខុ ... នឹងវត្ថុ គន្ថសម្បយុត្តរាគៈ ... ទិដ្ឋិ ... ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវវត្ថុ មានចក្ខុជាដើមនោះ វត្ថុ ជាបច្ច័យនៃពួកគន្ថសម្បយុត្ត-កក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និង បុរេជាត ។ សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភៈ ជាបច្ច័យនៃពួកសម្ប-យុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ បដិឃៈជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង កើតឡើង ព្រោះប្រារព្ធនូវចក្ខុ ... នូវវត្ថុ វត្ថុជាបច្ច័យ នៃពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង នៃលោភៈផង នៃពួកទោមនស្សសហគតក្ខន្ធផង នៃបដិឃៈផង ដោយអត្ថិប្បច្ច័យ ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺគន្ថសម្ប-យុត្តក្ខន្ធ ១ ផង វត្ថុផង ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធ ១ ផង លោភៈផង ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ទោមនស្សសហគតក្ខន្ធ ១ ផង បដិឃៈផង ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួក

គន្ធសម្បយុត្តក្ខន្ធផង ពួកមហាភូតផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ សហជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ សហជាត គឺពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង វត្ថុផង ជាបច្ច័យនៃលោភៈ ដោយអត្ថិប្បច្ច័យ ពួកទោមនស្សសហគតក្ខន្ធផង វត្ថុផង ជាបច្ច័យនៃបដិឃៈ ដោយអត្ថិប្បច្ច័យ ឯបច្ឆាជាត គឺពួកទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធផង លោភៈផង ពួកទោមនស្សសហគតក្ខន្ធផង បដិឃៈផង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកគន្ធសម្បយុត្តក្ខន្ធផង កពឡិង្ការាហារផង ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកគន្ធសម្បយុត្តក្ខន្ធផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ គន្ធសម្បយុត្តធម៌ក្តី គន្ធវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ធសម្បយុត្តធម៌ផង នៃគន្ធវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធ ១ ផង លោភៈផង ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... សហជាត គឺទោមនស្សសហគតក្ខន្ធ ១ ផង បដិឃៈផង ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... សហជាត គឺទិដ្ឋិគតវិប្បយុត្តលោភសហគតក្ខន្ធ ១ ផង វត្ថុផង ជាបច្ច័យនៃខន្ធ ៣ ផង

នៃលោកៈផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... សហជាត គឺទោមនស្ស-សហគតក្ខន្ធ ១ ផង វត្ថុផង ជាបច្ច័យនៃខន្ធ ៣ ផង នៃបដិឃៈផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។

[ ១៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៤៣ ] គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្ស-

យប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ គន្ថសម្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ គន្ថវិប្បយុត្តធម៌ ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ គន្ថសម្បយុត្តធម៌ក្តី គន្ថវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃគន្ថសម្បយុត្តធម៌ផង នៃគន្ថវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជា

បច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១៤៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៤៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ សេចក្តីបង្រួញ ... ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ សេចក្តីបង្រួញ ... ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៤៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ អនុលោមមាតិកា បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

គន្ថសម្បយុត្តទុកៈ ចប់

# គន្ថគន្ថនិយទុកៈ

## បដិច្ចវារៈ

[ ១៤៧ ] ធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជា

គន្ថនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈ អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ អភិជ្ឈាកាយគន្ថៈ អាស្រ័យនូវឥទំសច្ចាភិនិវេសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ ។ ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវពួកគន្ថៈ ។ ធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈផង ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈផង អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

បដិច្ចវារៈក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងគន្ថទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗ គ្នាទេ ។

## បញ្ហាវារៈ

[ ១៤៨ ] ធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ដោយហេតុប្បច្ច័យ គឺពួកគន្ថហេតុ ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ ។ បញ្ហាទាំង ៩ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះផងចុះ ។

[ ១៤៩ ] ធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ដោយអារម្មណប្បច្ច័យ គឺពួកគន្ថៈ កើតឡើងព្រោះប្រារព្ធនូវពួកគន្ថៈ ។ មូល បណ្ឌិតត្រូវសួរផងចុះ ពួកខន្ធជាគន្ថនិយៈ ទាំងជានោគន្ថៈ កើតឡើងព្រោះប្រារព្ធនូវពួកគន្ថៈ ។ មូល បណ្ឌិតត្រូវសួរផងចុះ

ពួកគន្ថៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវពួកគន្ថៈ ។ ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ ដោយអារម្មណប្បច្ច័យ គឺបុគ្គលនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ពិចារណានូវកម្ម មានទានជាដើមនោះ ( នូវពួកកុសល ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... នូវឈាន ... ពួកព្រះអរិយៈ ពិចារណានូវគោត្រភូ ពិចារណានូវវោទានៈ នូវពួកកិលេសដែលខ្លួនលះបង់ហើយ ... ពិចារណានូវពួកកិលេសដែលខ្លួនសង្កត់សង្កិនហើយ ដឹងនូវពួកកិលេសដែលធ្លុះពោរឡើងហើយ ក្នុងកាលមុន នូវចក្ខុ ... នូវវត្ថុ ... នូវពួកខន្ធជាគន្ថនិយៈ ទាំងជានោគន្ថៈ តាមអនិច្ចលក្ខណៈ ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ។ បទទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។ ជាបច្ច័យនៃការស្រាវជ្រាវដោយអារម្មណប្បច្ច័យ ។ ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថនិយៈ ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... បុគ្គលធ្វើនូវឧបោសថកម្មហើយត្រេកអរ រីករាយនឹងកុសលកម្មនោះ រាគៈកើតឡើង ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចៈ ... ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវកុសលកម្មនោះ ( នូវពួកកុសល ) ដែលខ្លួនសន្សំហើយក្នុងកាលមុន ... ចេញអំពីឈាន នូវឈាន ... នូវចក្ខុ ... នូវវត្ថុ ... ត្រេកអរ រីករាយ ចំពោះពួកខន្ធជាគន្ថនិយៈ ទាំងជានោគន្ថៈ រាគៈកើតឡើង ទិដ្ឋិ ... ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវធម្មជាត មានឈានជាដើមនោះ ។ ធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈ ជា

បច្ច័យនៃធម៌ ជាគន្ថៈ ទាំងជាគន្ថនិយៈផង នៃធម៌ជាគន្ថនិយៈ ទាំងជានោគន្ថៈផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ( នូវពួកកុសល ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... ចេញអំពីឈាន នូវឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយ នឹងពួកខន្ធ ជាគន្ថនិយៈ ទាំងជានោគន្ថៈ ពួកគន្ថៈផង ពួកសម្បយុត្តកក្ខន្ធផង កើតឡើង ព្រោះប្រារព្ធនូវធម្មជាត មានឈានជាដើមនោះ ។ វារៈទាំង ៣ ក្រៅពីនេះ បណ្ឌិតគប្បីឲ្យពិស្តារ ប្រារព្ធធ្វើយ៉ាងនេះផងចុះ ។

លោកុត្តរ មិនមានក្នុងទុកៈនេះទេ តែបណ្ឌិតត្រូវកំណត់ថា គន្ថនិយៈប្រហែលគ្នានឹងគន្ថទុកៈដែរ មិនមានការធ្វើផ្សេងគ្នាទេ ។ ក្នុងមគ្គប្បច្ច័យ បណ្ឌិតត្រូវធ្វើឲ្យជាបញ្ហា ៩ ។

គន្ថគន្ថនិយទុកៈ ចប់

# គន្ថគន្ថសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ១៥០ ] ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈ អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ អភិជ្ឈាកាយគន្ថៈ អាស្រ័យនូវឥទំសច្ចាភិនិ-

វេសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ អាស្រ័យនូវអភិជ្ឈាកាយគន្ថៈ ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថ-សម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អា-ស្រ័យនូវពួកគន្ថៈ ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអភិជ្ឈាកាយគន្ថៈផង ពួកសម្បយុត្តកក្ខន្ធផង អាស្រ័យនូវសីលព្វតបរាមាសកាយគន្ថៈ បណ្ឌិតគប្បីធ្វើឲ្យជាចក្កៈផងចុះ ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ អាស្រ័យនូវធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ នូវខន្ធ ២ ... ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត អាស្រ័យនូវធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកគន្ថៈ អាស្រ័យនូវពួកខន្ធ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី អាស្រ័យនូវធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ពួកគន្ថៈផង អាស្រ័យនូវខន្ធ ១ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ នូវខន្ធ ២ ... ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកគន្ថៈ អាស្រ័យនូវពួកគន្ថៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ធម៌ជាគន្ថ-

សម្បយុត្ត ទាំងជានោគន្ថៈ អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង នូវពួកគន្ថៈផង នូវខន្ធ ២ ... ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថ-សម្បយុត្ត ទាំងជានោគន្ថៈក្តី អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង អភិជ្ឈាកាយគន្ថៈផង អាស្រ័យនូវខន្ធ ១ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង នូវសីលព្វតបរាមាសកាយគន្ថៈផង នូវខន្ធ ២ ... បណ្ឌិតគប្បីចងឲ្យជាចក្កៈផងចុះ ។ សេចក្តីបន្រ្ទញ ។

[ ១៥១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៥២ ] ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត អាស្រ័យនូវធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។ សេចក្តីបន្រ្ទញ ។ នហេតុប្បច្ច័យ មិនមានក្នុងទីនេះទេ ។

[ ១៥៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

ការរាប់ទាំង ២ ក្រៅពីនេះក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយ-វារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈយ៉ាងនេះដែរ ។

## បញ្ហាវារៈ

[ ១៥៤ ] ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថ-សម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង ដោយហេតុប្បច្ច័យ ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ដោយហេ-តុប្បច្ច័យ គឺពួកហេតុជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃពួកសម្ប-យុត្តកគន្ថៈ ដោយហេតុប្បច្ច័យ ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជា

នោគន្ថៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង ដោយហេតុប្បច្ច័យ ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ជាបច្ច័យនៃពួកសម្បយុត្តកគន្ថៈ ដោយហេតុប្បច្ច័យ ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី ជាបច្ច័យនៃធម៌ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថ-សម្បយុត្តផង ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជាគន្ថៈ ទាំងជាគន្ថសម្បយុត្តក្តី ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកគន្ថៈផង ដោយហេតុប្បច្ច័យ ។

[ ១៥៥ ] ធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ជាបច្ច័យនៃធម៌ជាគន្ថៈ ទាំងជាគន្ថសម្បយុត្ត ដោយអារម្មណប្បច្ច័យ គឺពួកគន្ថៈកើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ ។ មូល បណ្ឌិតត្រូវធ្វើផងចុះ ពួកខន្ធ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ កើតឡើង ព្រោះប្រារព្ធនូវពួកគន្ថៈ ។ មូល បណ្ឌិតត្រូវធ្វើផងចុះ ពួកខន្ធជាគន្ថៈផង ជាគន្ថសម្បយុត្តផង កើតឡើង ព្រោះប្រារព្ធនូវ

ពួកគន្ថៈ ។ ធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ជាបច្ច័យនៃធម៌ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ កើតឡើងព្រោះប្រារព្ធនូវពួកខន្ធ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ។ មូល បណ្ឌិតត្រូវធ្វើផងចុះ ពួកគន្ថៈកើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ។ មូល បណ្ឌិតត្រូវធ្វើផងចុះ ពួកគន្ថៈក្តី ពួកគន្ថសម្បយុត្តក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ជាគន្ថសម្បយុត្ត ទាំងជានោគន្ថៈ ។ បញ្ហាវារៈទាំង ៣ ក្រៅនេះ បណ្ឌិតគប្បីធ្វើយ៉ាងនេះដែរ ។ ក្នុងអធិបតិប្បច្ច័យក្តី ក្នុងអនន្តរប្បច្ច័យក្តី ក្នុងឧបនិស្សយប្បច្ច័យក្តី ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។ ការបែក ( ឲ្យផ្សេងពីនេះទៅទៀត ) មិនមានទេ ។

[ ១៥៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគ-

តប្បច្ច័យ មានវារៈ ៩ ។

អរូបៈ ក៏មានបច្ច័យដែរ ។ ( បញ្ហាវារៈ ) បីៗ នៃបច្ច័យមួយៗ បណ្ឌិតត្រូវធ្វើផងចុះ ។ អារម្មណប្បច្ច័យក្តី សហជាតប្បច្ច័យក្តី ឧបនិស្សយប្បច្ច័យក្តី បណ្ឌិតត្រូវបន្ថិលក្នុងវារៈទាំង ៩ ផងចុះ ។ បច្ច័យទាំងអស់ បណ្ឌិតត្រូវធ្វើក្នុងបញ្ហាវារៈ យ៉ាងនេះផងចុះ ។

គន្ថគន្ថសម្បយុត្តទុកៈ ចប់

# គន្ថវិប្បយុត្តគន្ថនិយទុកៈ

## បដិច្ចវារៈ

[ ១៥៧ ] គន្ថវិប្បយុត្តធម៌ ( ធម៌ដែលប្រាសចាកគន្ថៈ ) និងគន្ថនិយធម៌ ( ធម៌ដែលគួរដល់គន្ថៈ ) អាស្រ័យនូវគន្ថវិប្បយុត្តធម៌ និងគន្ថនិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ ដែលជាគន្ថវិប្បយុត្ត និងជាគន្ថនិយៈ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ មហាភូត ១ ... ។បេ។ លោកិយទុកៈ ក្នុងចូឡន្តរទុកៈយ៉ាងណា បណ្ឌិតត្រូវឲ្យពិស្តារ យ៉ាងនោះចុះ មិនមានការធ្វើឲ្យផ្សេងៗ គ្នាទេ ។

គន្ថវិប្បយុត្តគន្ថនិយទុកៈ ចប់

# ឱឃយោគគោច្ឆកទុកៈ

## បដិច្ចវារៈ

[ ១៥៨ ] អាស្រ័យនូវឱឃធម៌ ... យោគធម៌ អាស្រ័យនូវយោគធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ឯគោច្ឆកៈទាំងពីរ ( នេះ ) ដូចគ្នានឹងអាសវគោច្ឆកៈដែរ មិនមានការធ្វើផ្សេងៗ ទេ ។

**ឱឃយោគគោច្ឆកទុកៈ ចប់**

# នីវរណទុកៈ

## បដិច្ចវារៈ

[ ១៥៩ ] នីវរណធម៌ ( ធម៌ជាគ្រឿងរាំង ) អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវព្យាបាទនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ កុក្កុច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវព្យាបាទនីវរណៈ ឧទ្ធច្ចនីវរណៈ កុក្កុច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវព្យាបាទនីវរណៈ ឧទ្ធច្ចនីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈ ។ នោនីវរណធម៌ ( ធម៌មិនមែនជាគ្រឿងរាំង ) អាស្រ័យនូវនីវរណធម៌ ទើបកើត

ឡើង ព្រោះហេតុប្បច្ច័យ គឺសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវពួកនីវរណៈ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈផង ឧទ្ធច្ចនីវរណៈផង អវិជ្ជានីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវកាមច្ឆន្ទនីវរណៈ បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ ។ នោនីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ និងចិត្តសមុដ្ឋានរូប អាស្រ័យនូវនោនីវរណក្ខន្ធ ១ បដិសន្ធិ ។ នីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនីវរណៈ អាស្រ័យនូវពួកនោនីវរណក្ខន្ធ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ពួកនីវរណៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនោនីវរណក្ខន្ធ ១ នូវខន្ធ ២ ... ។ នីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង ( បណ្ឌិតត្រូវធ្វើ ) ឲ្យជាចក្កៈផងចុះ ។ នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនោនីវរណក្ខន្ធ ១ ផង នូវនីវរណៈផង នូវខន្ធ ២ ... ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ គឺខន្ធ ៣ ជីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវនោនីវរណក្ខន្ធ ១ ផង នូវកាមច្ឆន្ទនីវរណៈផង នូវខន្ធ ២ ... ( បណ្ឌិតត្រូវធ្វើ ) ឲ្យជាចក្កៈផងចុះ ។ សេចក្តីបង្រួញ ។

[ ១៦០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៦១ ] នីវរណធម៌ អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈ ។ នោនីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនោនីវរណក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... តាំងពីអហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ ។ នីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ នីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធ

ផង ។

[ ១៦២ ] នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈ ។ នោនីវរណធម៌ អាស្រ័យនូវនោនីវរណធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនោនីវរណក្ខន្ធ រហូតដល់ពួកអសញ្ញសត្វ ។ នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ សេចក្តីបង្រួញ ។ ព្រោះនអធិបតិប្បច្ច័យ ព្រោះនអនន្តរប្បច្ច័យ ព្រោះនសមនន្តរប្បច្ច័យ ព្រោះនអញ្ញមញ្ញប្បច្ច័យ ព្រោះនឧបនិស្សយប្បច្ច័យ ។

[ ១៦៣ ] នីវរណធម៌ អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ក្នុងអរូប ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ក្នុងអរូប ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈ ក្នុងអរូប អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈ ក្នុងអរូប ។ នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវពួកនីវរណៈ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈ ក្នុងអរូប ។ បញ្ហាដ៏សេសសល់ទាំងអស់ បណ្ឌិតត្រូវឲ្យពិស្តារផងចុះ អរូបទី ១ បណ្ឌិតត្រូវ

ធ្វើ ( ឲ្យដូចគ្នាផងចុះ ) រូប បណ្ឌិតកាន់យកដូចជាបទខាងក្រោយ ។ នីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អាស្រ័យនូវពួកនោនីវរណក្ខន្ធផង នូវកាមច្ឆន្ទនីវរណៈផង ក្នុងអរូប ( បណ្ឌិតត្រូវធ្វើឲ្យ ) ជាចក្កៈផងចុះ ។ នោនីវរណធម៌ អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវនោនីវរណក្ខន្ធ ១ ផង នូវពួកនីវរណៈផង ក្នុងអរូប នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណៈផង នូវពួកមហាភូតផង ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី អាស្រ័យនូវនីវរណធម៌ផង នូវនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវនោនីវរណក្ខន្ធ ១ ផង នូវកាមច្ឆន្ទនីវរណៈផង ក្នុងអរូប ( បណ្ឌិតត្រូវធ្វើ ) ឲ្យជាចក្កៈផងចុះ ។ សេចក្តីបង្រួញ ។

[ ១៦៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩

ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៦៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។ សេចក្ដីបន្រ្ទួញ ។

[ ១៦៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

ឯសហជាតវារៈ បណ្ឌិតត្រូវធ្វើឲ្យពិស្ដារ យ៉ាងនេះផងចុះ ។

## បច្ចយវារៈ

[ ១៦៧ ] នីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ។ នោនីវរណធម៌ ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងនោនីវរណក្ខន្ធ ១ រហូតដល់ពួកអជ្ឈត្តិកមហាភូត ពួកនោនីវរណក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ នីវរណធម៌ ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនីវរណៈ ពឹងផ្អែកនឹងពួកនោនីវរណក្ខន្ធ ពួកនីវរណៈ ពឹងផ្អែកនឹងវត្ថុ ។ នីវរណធម៌ក្ដី នោនីវរណធម៌ក្ដី ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ពួក

និវរណៈផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងនោនីវរណក្ខន្ធ ១ នឹងខន្ធ ២ ... ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ។ នីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ផង នឹងនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ពឹងផ្អែកនឹងកាមច្ឆន្ទនីវរណៈផង នឹងពួកសម្បយុត្តកក្ខន្ធផង បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ ថីនមិទ្ធនីវរណៈ និងអវិជ្ជានីវរណៈ ពឹងផ្អែកនឹងកាមច្ឆន្ទនីវរណៈផង នឹងវត្ថុផង បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ ។ នោនីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ផង នឹងនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងនោនីវរណក្ខន្ធ ១ ផង នឹងពួកនីវរណៈផង នឹងខន្ធ ២ ... ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងពួកនីវរណៈផង នឹងវត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនីវរណៈផង នឹងពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនីវរណៈផង នឹងពួកមហាភូតផង ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ពឹងផ្អែកនឹងនីវរណធម៌ផង នឹងនោនីវរណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ពឹងផ្អែកនឹងនោនីវរណក្ខន្ធ ១ ផង នឹងកាមច្ឆន្ទនីវរណៈផង នឹងខន្ធ ២ ... បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ និងពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងកាមច្ឆន្ទនីវរណៈផង នឹងវត្ថុផង បណ្ឌិតត្រូវធ្វើ ឲ្យជាចក្កៈផងចុះ ។ សេចក្តីបង្រួញ ។

[ ១៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៦៩ ] នីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ ពឹងផ្អែកនឹងវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ ពឹងផ្អែកនឹងឧទ្ធច្ចនីវរណៈ ។ នោនីវរណធម៌ ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងនោនីវរណក្ខន្ធ ១ ជាអហេតុកៈ នឹងខន្ធ ២ ... រហូតដល់ពួកអសញ្ញសត្វ ពួកនោនីវរណក្ខន្ធជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ ។ នីវរណធម៌ ពឹងផ្អែកនឹងនោនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជា-នីវរណៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អវិជ្ជានីវរណៈ ពឹងផ្អែកនឹងវត្ថុ ។ នីវរណធម៌ ពឹងផ្អែកនឹងនីវរណធម៌ផង នឹងនោនីវរណធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ ពឹងផ្អែកនឹងវិចិកិច្ឆានីវរណៈផង នឹងពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ ពឹងផ្អែកនឹងឧទ្ធច្ចនីវរណៈផង នឹងពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ ពឹងផ្អែកនឹងវិចិកិច្ឆានីវរណៈផង នឹងវត្ថុផង អវិជ្ជានីវរណៈ ពឹងផ្អែកនឹងឧទ្ធច្ចនីវរណៈផង នឹងវត្ថុផង ។ សេចក្តីបង្រួញ ។

[ ១៧០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣

ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៧១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបង្រួញ ។

[ ១៧២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

## សំសដ្ឋវារៈ

[ ១៧៣ ] នីវរណធម៌ លាយឡំនឹងនីវរណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ លាយឡំនឹងកាមច្ឆន្ទនីវរណៈ បណ្ឌិតត្រូវធ្វើឲ្យជាចក្កៈផងចុះ នីវរណៈទាំងអស់ បណ្ឌិតត្រូវឲ្យពិស្តារផងចុះ ។

[ ១៧៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៧៥ ] នីវរណធម៌ លាយឡំនឹងនីវរណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈលាយឡំនឹងវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈលាយឡំនឹងឧទ្ធច្ចនីវរណៈ ។ សេចក្តីបង្រួញ ។

[ ១៧៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

ការរាប់ពីរយ៉ាងដទៃពីនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតត្រូវធ្វើយ៉ាងនេះផងចុះ ។

## បញ្ហាវារៈ

[ ១៧៧ ] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយហេតុប្បច្ច័យ គឺពួកនីវរណហេតុជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយហេតុប្បច្ច័យ ។ នីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយហេតុប្បច្ច័យ គឺពួកនីវរណហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយហេតុប្បច្ច័យ គឺពួកនីវរណហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង

នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយហេតុប្បច្ច័យ គឺពួកនោនីវ-រណហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ បដិសន្ធិ ។

[ ១៧៨ ] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ គឺពួកនីវរណៈកើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនោនីវរណក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ពិចារណានូវកុសលកម្មនោះ ត្រេកអររីករាយនឹងកុសលកម្មនោះ ទិដ្ឋិកើតឡើង ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវកុសលកម្មនោះ ដែលខ្លួនសន្សំហើយក្នុងកាលមុន ... បុគ្គលចេញអំពីឈាន នូវឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ នូវមគ្គ ... នូវផល ... នូវនិព្វាន ... និព្វានជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ ផល និងអាវជ្ជនៈ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈពិចារណានូវពួកនោនីវរណក្កិលេស ដែលខ្លួនលះបង់ហើយ នូវពួកកិលេសដែលខ្លួនសង្កត់សង្កិនហើយ ... ( នូវកងអំពើ ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... នូវចក្ខុ ... នូវវត្ថុ នូវពួកនោនីវរណក្ខន្ធ ថាមិនទៀង ... ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោត-

ជាតុ ដឹងនូវចិត្តនៃបុគ្គល អ្នកប្រកបដោយនោនីវរណចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពួកនោនីវរណក្ខន្ធ ជាបច្ច័យនៃកិរិយាពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ( នូវពួកអំពើ ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... នូវឈាន ... នូវចក្ខុ ... នូវវត្ថុ ... នូវពួកនោនីវរណក្ខន្ធ ត្រេកអរ រីករាយ រាគៈកើតឡើង ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចៈ ... ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ( នូវពួកអំពើ ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... នូវនោនីវរណក្ខន្ធ ត្រេកអររីករាយ ពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ គឺវារៈ ៣ បណ្ឌិតគប្បីប្រារព្ធធ្វើផងចុះ ។

[ ១៧៩ ] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអធិបតិប្បច្ច័យ

បានដល់ អារម្មណាធិបតិ គឺពួកនីវរណៈ កើតឡើងព្រោះធ្វើនូវពួកនីវរណៈឲ្យជាទីគោរព ។ វារៈទាំង ៣ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គល នូវទាន ... នូវសីល ... ធ្វើនូវឧបោសថកម្ម ហើយធ្វើនូវអំពើនោះឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព នូវពួកអំពើដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... អំពីឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ នូវមគ្គ ... នូវផល ... នូវនិព្វាន ... និព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ... ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកនោនីវរណក្ខន្ធ ឲ្យជាទីគោរព រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺនោនីវរណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន ... នូវសីល ... នូវឧបោសថ-កម្ម ... ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកនោនីវរណក្ខន្ធ ឲ្យជាទីគោរព រាគៈ កើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺនោ-នីវរណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយអធិបតិប្បច្ច័យ ។

នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកនោនីវរណក្ខន្ធ ឲ្យជាទីគោរព ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺនោនីវរណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ វារៈទាំង ៣ គឺអារម្មណាធិបតិហ្នឹងឯង ។

[ ១៨០ ] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនីវរណៈមុនៗ ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណៈមុនៗ ជាបច្ច័យនៃពួកនោនីវរណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកនីវរណៈ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ។ ពួកនីវរណៈមុនៗ ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោនីវរណក្ខន្ធមុនៗ ជាបច្ច័យនៃពួកនោនីវរណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គលកាលចេញអំពីនិរោធ ជា

បច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ ។ ពួកនោនីវរណក្ខន្ធមុនៗ ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃពួកនីវរណៈ ដោយអនន្តរប្បច្ច័យ ។ ពួកនោនីវរណក្ខន្ធមុនៗ ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃពួកនីវរណក្ខន្ធផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនីវរណក្ខន្ធមុនៗ ផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ ។ ពួកនីវរណៈមុនៗ ក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកនោនីវរណក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកនីវរណក្ខន្ធក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ ពួកនីវរណៈមុនៗ ក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកនីវរណៈក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ ។

[ ១៨១ ] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកនីវរណៈ មានវារៈ ៣ ។ នោនីវរណធម៌ ជា

បច្ច័យនៃនោនីវរណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូប- និស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺ បុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ញុំាងឈាន ឲ្យកើតឡើង ញុំាងវិបស្សនា ... ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ។បេ។ នូវបញ្ញា ... នូវរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា កាយិក- សុខ និងកាយិកទុក្ខ ... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈជាបច្ច័យនៃសទ្ធា ។បេ។ នៃបញ្ញា នៃរាគៈ ។បេ។ នៃសេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ និងផល- សមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវ- រណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូប- និស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវ សទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ... ។បេ។ បុគ្គល អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ... ។បេ។

បុគ្គលអាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃពួកនីវរណក្ខន្ធផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។ នីវរណធម៌ក្តី នោនីវ-រណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូប-និស្ស័យ គឺពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃពួកនីវរណៈ ដោយឧបនិស្សយប្បច្ច័យ គឺមានវារៈ ៣ ។

[ ១៨២ ] នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយបុរេជា-តប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ... ទោមនស្សកើតឡើង ។ មានវារៈ ៣ ។ បុរេជាតប្បច្ច័យ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ បណ្ឌិតគប្បីចែក ( តាមវារៈ ) នៃកុសល និងអកុសលផងចុះ ។

[ ១៨៣ ] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ ៣ ។ ជាបច្ច័យដោយអាសេវនប្បច្ច័យ គឺមានវារៈ ៩ ។

[ ១៨៤ ] នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺនោនីវរណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺនោនីវរណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បី

សួរផងចុះ ។ នោនីវរណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយកម្មប្បច្ច័យ ។ នោនីវរណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ១៨៥ ] នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ ១ ។ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ។

[ ១៨៦ ] នីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ ប្រស្នាទាំង ៤ ដ៏សេស បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

[ ១៨៧ ] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអត្ថិប្បច្ច័យ គឺកាមច្ឆន្ទនីវរណៈ ជាបច្ច័យនៃថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ដោយអត្ថិប្បច្ច័យ បណ្ឌិតគប្បីធ្វើឲ្យជាចក្កៈផងចុះ ។ នីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ ក្នុងនីវរណៈ ១ មានវារៈ ៣ យ៉ាងនេះឯង ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សេចក្តីបង្រួញ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សេចក្តីបង្រួញ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនី-

វរណធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សេចក្តីបងប្រួញ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺកាមច្ឆន្ទនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ដោយអត្ថិប្បច្ច័យ កាមច្ឆន្ទនីវរណៈក្តី វត្ថុក្តី ជាបច្ច័យនៃថីនមិទ្ធនីវរណៈ និងអវិជ្ជានីវរណៈ ដោយអត្ថិប្បច្ច័យ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនោនីវរណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ជានោនីវរណៈផង ពួកនីវរណៈផង ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ពួកនីវរណៈក្តី វត្ថុក្តី ជាបច្ច័យនៃនោនីវរណក្ខន្ធ ដោយអត្ថិប្បច្ច័យ ពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកនីវរណៈក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង កពឡិង្ការាហារផង ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺពួកនីវរណៈផង ពួកសម្បយុត្តកក្ខន្ធផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់

សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ជានោនីវរណៈផង កាមច្ឆន្ទ-នីវរណៈផង ជាបច្ច័យនៃខន្ធ ៣ ផង នៃថីនមិទ្ធនីវរណៈផង នៃឧទ្ធច្ចនីវរណៈផង នៃអវិជ្ជានីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... កាមច្ឆន្ទនីវរណៈក្តី វត្ថុក្តី ជាបច្ច័យនៃថីនមិទ្ធនីវរណៈផង នៃឧទ្ធច្ចនីវរណៈផង នៃអវិជ្ជានីវរណៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ( បណ្ឌិតគប្បីធ្វើ ) ឲ្យជាចក្កៈផងចុះ ។

[ ១៨៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៨៩ ] នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ

ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ នីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ នីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនោនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆា-ជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នោនីវរណធម៌ ជាបច្ច័យនៃនីវរណធម៌ផង នៃនោនីវរណធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ នីវរណធម៌ក្តី នោនីវរណធម៌ក្តី ជាបច្ច័យនៃនោនីវរណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ នីវ-

វណាធម៌ក្តី នោនីវរណាធម៌ក្តី ជាបច្ច័យនៃនីវរណាធម៌ផង នៃនោនីវរណាធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១៩០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៩១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ។ សេចក្តីបង្រួញ ។ ... ក្នុងនមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ១៩២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ អនុលោមមាតិកា បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

នីវរណទុកៈ ចប់

# ធីវរណិយទុកៈ

## បដិច្ចវារៈ

[ ១៩៣ ] នីវរណិយធម៌ អាស្រ័យនូវនីវរណិយធម៌ ទើបកើតឡើង ... ។ នីវរណិយទុកៈយ៉ាងណា លោកិយទុកៈ បណ្ឌិតគប្បីធ្វើយ៉ាងនោះចុះ មិនមានការធ្វើផ្សេងគ្នាឡើយ ។

ការប្រកបដោយកាមច្ឆន្ទៈពីរលើក ការប្រកបដោយបដិឃៈ ៤ លើក ឧទ្ធច្ចៈ ១ វិចិកិច្ឆា ១ ទាំងពីរនុ៎ះ មានការប្រកបមួយលើកៗ ការប្រកបនូវពួកនីវរណៈ ដោយពួកនីវរណៈ មានប្រការ ៨ ( យ៉ាងនេះឯង ) ។

មាតិកានៃនីវរណទុកៈ លោកបានធ្វើទុកក្នុងទីនេះ ។

នីវរណិយទុកៈ ចប់

# ធីវរណសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ១៩៤ ] នីវរណសម្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានីវរណសម្បយុត្ត នូវខន្ធ ២ ... ។ នីវរណវិប្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណសម្បយុត្តក្ខន្ធ ។ នីវរណសម្បយុត្តធម៌ក្តី នីវរណ-វិប្បយុត្តធម៌ក្តី អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានីវរណសម្បយុត្តផង នូវចិត្តសមុដ្ឋានរូបផង នូវខន្ធ ២ ... ។ នីវរណវិប្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ ជានីវរណវិប្បយុត្ត នូវខន្ធ ២ ... បដិសន្ធិ មានដរាបដល់ពួកមហាភូតខាងក្នុង ។ នីវរណវិប្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ផង នូវនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនីវរណសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង ។ សេចក្តីបង្រួញ ។

[ ១៩៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ១៩៦ ] នីវរណសម្បយុត្តធម៌ អាស្រ័យនូវនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ នីវរណវិប្បយុត្តធម៌ អាស្រ័យនូវនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺជានីវរណវិប្បយុត្ត ជាអហេតុកៈ ... ដរាបដល់ពួកអសញ្ញសត្វ ។ សេចក្តីបំប្រួញ ។

[ ១៩៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មាន

វារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៩៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៩៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។បេ។ ... ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ។បេ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯសហជាតវារៈ បណ្ឌិតត្រូវធ្វើឲ្យជាវារៈ ១ ចុះ ។

## បច្ចយវារៈ

[ ២០០ ] នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ។ នីវរណវិប្បយុត្តធម៌

ពីងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ ១ ជានីវរណវិប្បយុត្ត នឹងខន្ធ ២ ... បដិសន្ធិ ពួកនីវរណវិប្បយុត្តក្ខន្ធ ពឹងផ្អែកនឹងមហាភូត ១ នឹងវត្ថុ ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ពួកនីវរណសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងនីវរណវិប្បយុត្ត-ធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនីវរណសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ។ នីវរណសម្ប-យុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជានីវ-រណសម្បយុត្តផង នឹងវត្ថុផង នឹងខន្ធ ២ ... ។ នីវរណវិប្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនីវរណសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជានីវរណសម្បយុត្តផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនីវរណ-សម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង ។ សេចក្តីបង្រួញ ។

[ ២០១ ] ក្នុងហេតុប្បច្ច័យមានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ

៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ។បេ។ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២០២ ] នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ នីវរណវិប្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ ១ ជាអហេតុកៈ ជានីវរណ-វិប្បយុត្ត ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកនីវរណវិប្បយុត្តក្ខន្ធជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ នីវរណសម្បយុត្តធម៌ ពឹងផ្អែកនឹងនីវរណសម្បយុត្តធម៌ផង នឹងនីវរណវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សេចក្តីបង្រួញ ។

[ ២០៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មាន

វារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់វារៈទាំងពីរក្រៅពីនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ៗ

## សំសដ្ឋវារៈ

[ ២០៤ ] នីវរណសម្បយុត្តធម៌ លាយឡំនឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២០៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ២០៦ ] នីវរណសម្បយុត្តធម៌ លាយឡំនឹងនីវរណសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ លាយឡំនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ លាយឡំនឹងនីវរណវិប្បយុត្តធម៌ ... ។

[ ២០៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

ការរាប់វារៈទាំងពីរក្រៅពីនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាង នេះចុះ ។

## បញ្ហាវារៈ

[ ២០៨ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកនីវរណសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្ត-កក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ ។ ពួកនីវរណសម្បយុត្តហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ ពួកនីវរណសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកនីវរណវិប្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺជាបដិសន្ធិ ។

[ ២០៩ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលត្រេកអរ រីករាយ ចំពោះរាគៈ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ត្រេកអរ រីករាយ ចំពោះទិដ្ឋិ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ វិចិកិច្ឆា ទិដ្ឋិ ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវវិចិកិច្ឆា ឧទ្ធច្ចៈ កើតឡើង ព្រោះប្រារព្ធនូវឧទ្ធច្ចៈ ទិដ្ឋិ ... វិចិកិច្ឆាកើតឡើង ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវទោមនស្ស ទិដ្ឋិ ...

វិចិកិច្ឆា ... ឧទ្ធច្ចៈកើតឡើង ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណ-វិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ពិចារណានូវពួកកិលេស ជានីវរណសម្បយុត្ត ដែលខ្លួនលះបង់ហើយ ពិចារណានូវពួកកិលេស ដែលខ្លួនសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ឃើញនូវពួកនីវរណសម្បយុត្តក្ខន្ធ ថាមិនទៀង ជាទុក្ខ ជាអនត្តា ដឹងនូវចិត្តនៃបុគ្គលអ្នកប្រកបដោយនីវរណសម្បយុត្តចិត្ត ដោយចេតោបរិយញ្ញាណ ពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុ-បគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នីវរណវិប្ប-យុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ពិចារណានូវហេតុនោះ ( នូវពួកអំពើ ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... ចេញអំពីឈាន នូវឈាន ... ពួកព្រះអរិយៈ ចេញអំពីមគ្គ នូវមគ្គ ... ពិចារណានូវផល នូវព្រះនិព្វាន ... ព្រះនិព្វាន ជាបច្ច័យនៃកិរិយាពិចារណានូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ ... ឃើញច្បាស់នូវវត្ថុ នូវពួកនីវរណវិប្ប-យុត្តក្ខន្ធថាមិនទៀង ជាទុក្ខ ជាអនត្តា ឃើញនូវរូបដោយទិព្វចក្ខុ ដរាបអំពីអាវជ្ជនៈ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយ ចំពោះពួក

នីវរណវិប្បយុត្តក្ខន្ធ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។

[ ២១០ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវរាគៈ ឲ្យជាទីគោរព រាគៈ ទិដ្ឋិកើតឡើង ព្រោះធ្វើនូវរាគៈនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺនីវរណសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយអធិបតិប្បច្ច័យ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺនីវរណសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ នីវរណសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គល នូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ធ្វើនូវហេតុនោះ ឲ្យជាទីគោរព ហើយពិចារណា ( នូវពួកអំពើ ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... ចេញអំពីឈាន នូវឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ ធ្វើនូវមគ្គ ឲ្យជាទីគោរព ... នូវផល ... នូវព្រះនិព្វាន ... ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ ។ ឯសហជាតាធិបតិ គឺនីវរណ-

វិប្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្ត-ធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺនូវទាន ... ។បេ។ ក្នុងកាលមុន ... នូវឈាន ... នូវចក្ខុ ... នូវវត្ថុ ... ធ្វើនូវពួកនីវរណវិប្ប-យុត្តក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ទិដ្ឋិកើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព ។

[ ២១១ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនីវរណសម្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកនីវ-រណសម្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ( ខន្ធ ៣ ) មុនៗ មិនមានក្នុងទីនោះទេ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណវិប្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកនីវរណវិប្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ គឺអនុលោមញាណ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនៈជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយអនន្តរប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយសមនន្តរប្បច្ច័យ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ ។

[ ២១២ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ដោយ

ឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និង បកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវរាគៈ ហើយ សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ នូវទោសៈ ... នូវមោហៈ មានះ និងទិដ្ឋិ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយសម្លាប់នូវសត្វ ។បេ។ បំបែក នូវសង្ឃ រាគៈ ។បេ។ សេចក្តីប្រាថ្នា ( ជាបច្ច័យ ) នៃរាគៈ ។បេ។ ជា បច្ច័យនៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្ត-រូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យ នូវរាគៈ ហើយឲ្យនូវទាន នូវសីល ... នូវឧបោសថកម្ម ញ៉ាំងឈាន វិបស្សនា មគ្គ និងអភិញ្ញា ... ញ៉ាំងសមាបត្តិឲ្យកើតឡើង នូវទោសៈ ... អាស្រ័យនូវ សេចក្តីប្រាថ្នា ហើយឲ្យនូវទាន ។បេ។ ញ៉ាំងសមាបត្តិឲ្យកើតឡើង រាគៈ ។បេ។ សេចក្តីប្រាថ្នា ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ ជាបច្ច័យនៃបញ្ញា កាយិក-សុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នីវរ-ណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធាហើយឲ្យនូវទាន នូវសីល ... ។បេ។ ញ៉ាំងមគ្គ ... ញ៉ាំងអភិញ្ញា ញ៉ាំងសមាបត្តិឲ្យកើតឡើង នូវសីល ... ។បេ។ នូវបញ្ញា ... ។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ។បេ។ ញ៉ាំងសមាបត្តិ ឲ្យកើតឡើង សទ្ធា ។បេ។ សេនាសនៈ ( ជាបច្ច័យ )

នៃសទ្ធា ។បេ។ ជាបច្ច័យនៃបញ្ញា មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ... ។បេ។ នូវបញ្ញា ... កាយិកៈ ... ។បេ។ អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ២១៣ ] នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ... ឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ ជាអនត្តា ឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកនីវរណវិប្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ... ត្រេកអរ រីករាយ ចំពោះវត្ថុ រាគៈ ទោសៈ មោហៈ ( កើតឡើង ) ព្រោះប្រារព្ធនូវហេតុនោះ ។

ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

[ ២១៤ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ ២ ។ ជាបច្ច័យដោយអាសេវនប្បច្ច័យ គឺមានវារៈ ២ ។

[ ២១៥ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយកម្មប្បច្ច័យ គឺនីវរណសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ ដោយកម្មប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ ។ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺនីវរណសម្បយុត្តចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺនីវរណសម្បយុត្តចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ នីវរណសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សេចក្តីបង្រួញ ។ ជាបច្ច័យដោយវិបាកប្បច្ច័យ គឺមានវារៈ ១ ។

[ ២១៦ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអាហារប្បច្ច័យ ។ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ

គឺមានវារៈ ២ ។

[ ២១៧ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។

[ ២១៨ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ជានីវរណសម្បយុត្ត ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកនីវរណសម្បយុត្តក្ខន្ធ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ផង នៃនីវរណវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ជានីវរណសម្បយុត្ត ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បាន

ដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សេចក្តីបង្រួញ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺបុគ្គល នូវចក្ខុ ... ត្រេកអរ រីករាយចំពោះវត្ថុ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ វត្ថុ ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ នីវរណ-សម្បយុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ជានីវរណសម្បយុត្តផង វត្ថុផង ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ផង វត្ថុផង ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។ នីវរណសម្ប-យុត្តធម៌ក្តី នីវរណវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកនីវរណសម្បយុត្តក្ខន្ធផង ពួកមហាភូតផង ជាបច្ច័យនៃពួកចិត្ត-សមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកនីវរណសម្បយុត្តក្ខន្ធផង កពឡិង្ការាហារផង ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ បច្ឆាជាត គឺ ពួកនីវរណសម្បយុត្តក្ខន្ធផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ២១៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ២២០ ] នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ផង នៃនីវរណវិប្បយុត្តធម៌ផង ដោយសហជាតប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ

ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នីវរណវិប្បយុត្តធម៌ ជាបច្ច័យនៃនីវរណ-សម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្ប-យុត្តធម៌ក្តី ជាបច្ច័យនៃនីវរណសម្បយុត្តធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នីវរណសម្បយុត្តធម៌ក្តី នីវរណវិប្បយុត្ត-ធម៌ក្តី ជាបច្ច័យនៃនីវរណវិប្បយុត្តធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិ-យប្បច្ច័យ ។

[ ២២១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ២២២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុង

នសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ២២៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ការរាប់ជាអនុលោម បណ្ឌិតគប្បីធ្វើចុះ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

នីវរណសម្បយុត្តទុកៈ ចប់

# នីវរណនីវរណិយទុកៈ

## បដិច្ចវារៈ

[ ២២៤ ] ធម៌ជានីវរណៈ និងជានីវរណិយៈ អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ។ ការរាប់ទាំងអស់ បណ្ឌិតគប្បីចែកយ៉ាងនេះចុះ ប្រហែលគ្នានឹងនីវរណទុកៈដែរ ឥតមានការធ្វើឲ្យផ្សេងគ្នាឡើយ ។

## បញ្ហាវារៈ

[ ២២៥ ] ធម៌ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃធម៌ ជានីវ-

រណៈ និងជានីវរណិយៈ ដោយហេតុប្បច្ច័យ គឺពួកហេតុ ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយហេតុប្បច្ច័យ ។ ធម៌ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃធម៌ជានីវរណិយៈ និងជានោនីវរណៈ ដោយហេតុប្បច្ច័យ គឺពួកហេតុ ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេ-តុប្បច្ច័យ ។ ធម៌ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណិយៈផង នៃធម៌ជានីវរណិយៈ និងជានោនីវរណៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុ ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ ធម៌ជានីវរណិយៈ និងជានោនីវរណៈ ជាបច្ច័យនៃធម៌ ជានីវរណិយៈ និងជានោនីវរណៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណិយៈ និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ មានបដិសន្ធិ ។

[ ២២៦ ] ធម៌ជានីវរណៈ និងជានីវរណិយៈ ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណិយៈ ដោយអារម្មណប្បច្ច័យ គឺពួកនីវរណៈ កើតឡើងព្រោះប្រារព្ធនូវពួកនីវរណៈ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកខន្ធជានីវរណិយៈ និងជានោនីវរណៈ កើតឡើងព្រោះប្រារព្ធនូវពួកនីវរណៈ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវពួកនីវរណៈ ។ ធម៌ជានីវរណិយៈ និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជា

នីវរណិយៈ និងជានោនីវរណៈ ដោយអារម្មណប្បច្ច័យ គឺបុគ្គល នូវទាន ... នូវសីល ... ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវឧបោសថកម្មនោះ ត្រេកអរ រីករាយ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ( នូវពួកអំពើ ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... អំពីឈាន ពួកព្រះអរិយៈ ពិចារណានូវគោត្រភូ នូវវោទានៈ ... នូវពួកកិលេសដែលខ្លួនលះបង់ហើយ ... នូវពួកកិលេសដែលខ្លួនសង្កត់សង្កិនហើយ ... នូវពួកកិលេសដែលខ្លួនដកឡើងព្រមហើយ ក្នុងកាលមុន ... នូវចក្ខុ ... នូវវត្ថុ ... នូវពួកខន្ធ ជានីវរណិយៈ និងជានោនីវរណៈ ថាមិនទៀង ... ឃើញច្បាស់ ត្រេកអរ រីករាយ ។បេ។ ទោមនស្ស ... ដោយទិព្វចក្ខុ ... ការនឹករំពឹង ( មាន ) ត្រឹមណា បណ្ឌិតត្រូវធ្វើត្រឹមណោះ ។ ធម៌ជានីវរណិយៈ និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណិយៈ ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ( នូវពួកអំពើ ) ដែលខ្លួនសន្សំហើយក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយ ចំពោះពួកខន្ធ ជានីវរណិយៈ និងជានោនីវរណៈ រាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។ ធម៌ជានីវរណិយៈ និងជានោនីវរណិយៈ ជាបច្ច័យនៃធម៌ ជានីវរណៈ និងជានីវរណិយៈផង នៃធម៌ជានីវរណិយៈ និងជានោនីវរណៈផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ( នូវពួកអំពើ ) ដែលខ្លួនសន្សំហើយក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... បុគ្គល

ត្រេកអរ រីករាយចំពោះពួកខន្ធជានីវរណិយៈ និងជានោនីវរណៈ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវហេតុនោះ បណ្ឌិតគប្បីធ្វើនូវវារៈទាំង ៣ ដទៃ យ៉ាងនេះចុះ ។ អធិបតិប្បច្ច័យ ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។ សូម្បីបុរេជាតប្បច្ច័យ ក៏ប្រហែលគ្នានឹងអារម្មណប្បច្ច័យដែរ ។ បណ្ឌិតមិនត្រូវធ្វើនូវលោកុត្តរ ក្នុងឧបនិស្សយប្បច្ច័យឡើយ ។ សេចក្តីបង្រួញ ។ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។ នីវរណ-ទុកៈ យ៉ាងណា បណ្ឌិតគប្បីពិចារណា ហើយធ្វើយ៉ាងនោះចុះ ។

**នីវរណនីវរណិយទុកៈ ចប់**

# នីវរណនីវរណសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ២២៧ ] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺថីន-មិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ នីវរណៈទាំងអស់ បណ្ឌិតគប្បីធ្វើឲ្យជាចក្កៈផងចុះ ។ ធម៌ជានីវរណសម្ប-យុត្ត និងជានោនីវរណៈ អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវពួកនីវរណៈ ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត

និងជានោនីវរណៈក្តី អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជា-នីវរណៈ និងពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ បណ្ឌិតគប្បីធ្វើឲ្យជាចក្កៈផងចុះ ។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ អាស្រ័យនូវធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានីវរណសម្បយុត្ត និងជានោនីវរណៈ នូវខន្ធ ២ ... ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណ-សម្បយុត្ត និងជានោនីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនីវរណៈ អាស្រ័យនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី អាស្រ័យនូវធម៌ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ពួកនីវរណៈផង អាស្រ័យនូវខន្ធ ១ ជានីវរណសម្បយុត្ត និងជានោនីវរណៈនូវខន្ធ ២ ... ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ ជានីវរណៈ និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ អវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង បណ្ឌិត ( គប្បីធ្វើ ) ឲ្យជាចក្កៈផងចុះ ។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោ-

នីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានីវរណសម្បយុត្ត និងជានោនីវរណៈផង នូវពួកនីវរណៈផង នូវខន្ធ ២ ... ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ជាថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ អាស្រ័យនូវខន្ធ ១ ជានីវរណសម្បយុត្ត និងជានោនីវរណៈផង នូវកាមច្ឆន្ទនីវរណៈផង នូវខន្ធ ២ ... បណ្ឌិត ( គប្បីធ្វើ ) ឲ្យជាចក្កៈផងចុះ ។ សេចក្តីបង្រួញ ។

[ ២២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២២៩ ] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈ ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត អាស្រ័យនូវធម៌ជានីវរណៈ

និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង អវិជ្ជានីវរណៈ អាស្រ័យនូវឧទ្ធច្ចនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ សេចក្តីបង្រួញ ។

[ ២៣០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ២៣១ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ... ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ២៣២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈយ៉ាងនេះដែរ មិនមានការធ្វើឲ្យផ្សេងគ្នាទេ ។

## បញ្ហាវារៈ

[ ២៣៣ ] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជា

នីវរណៈ និងជានីវរណសម្បយុត្ត ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយហេតុប្បច្ច័យ ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃពួកនីវរណសម្បយុត្តក្ខន្ធ ដោយហេតុប្បច្ច័យ ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្តផង ជានីវរណសម្បយុត្ត និងជានោនីវរណៈផង ដោយហេតុប្បច្ច័យ គឺពួកហេតុជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង ដោយហេតុប្បច្ច័យ ។

[ ២៣៤ ] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអារម្មណប្បច្ច័យ គឺពួកនីវរណៈកើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ កើតឡើងព្រោះប្រារព្ធនូវពួកនីវរណៈ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកនីវរណៈ ។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃធម៌ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ ។ ពួកនីវរណៈកើតឡើង ព្រោះប្រារព្ធនូវ

ពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ ។ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអារម្មណប្បច្ច័យ គឺមានវារៈ ៣ ។

[ ២៣៥ ] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ ។ វារៈទាំង ៣ បានដល់ គរុការម្មណ៍ហ្នឹងឯង ។ ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ កើតឡើង ព្រោះធ្វើនូវពួកខន្ធជានីវរណសម្បយុត្តនិងជានោនីវរណៈ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរផងចុះ ។ ពួកនីវរណៈ កើតឡើង ព្រោះធ្វើនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ ឲ្យជាទីគោរព សហជាតាធិបតិ គឺអធិបតិ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយអធិបតិប្បច្ច័យ ពួកនីវរណៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះធ្វើនូវពួកខន្ធជានីវរណសម្បយុត្ត និងជានោនីវរណៈ

ឲ្យជាទីគោរព សហជាតាធិបតិ គឺអធិបតិ ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង ដោយអធិបតិប្បច្ច័យ ។ ធម៌ជានីវរណៈ និងជានីវរណសម្បយុត្តក្តី ជានីវរណសម្បយុត្ត និងជានោនីវរណៈក្តី ជាបច្ច័យនៃធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ ។ គឺមានវារៈ ៣ ។

[ ២៣៦ ] ជាបច្ច័យដោយអនន្តរប្បច្ច័យ អាវជ្ជនៈក្តី វុដ្ឋានៈក្តី មិនមានទេ ( ពួកខន្ធ ) មុនៗ បណ្ឌិតគប្បីធ្វើក្នុងបច្ច័យទាំងអស់ចុះ ។ ជាបច្ច័យដោយសមនន្តរប្បច្ច័យ មានវារៈ ៩ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ មានវារៈ ៩ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ មានវារៈ ៩ ។ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ មានវារៈ ៩ ។ ដូចគ្នានឹងអារម្មណប្បច្ច័យដែរ វិភង្គមិនមានទេ ។ ជាបច្ច័យដោយអាសេវនប្បច្ច័យ ។

[ ២៣៧ ] ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយកម្មប្បច្ច័យ គឺចេតនា ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីសួរចុះ ។ ចេតនាជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃពួកសម្បយុត្តកនីវរណៈ ដោយកម្មប្បច្ច័យ ។ ចេតនាជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃ

ពួកសម្បយុត្តកក្ខន្ធផង នៃពួកនីវរណៈផង ដោយកម្មប្បច្ច័យ ។

[ ២៣៨ ] ធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ជាបច្ច័យនៃធម៌ជានីវរណសម្បយុត្ត និងជានោនីវរណៈ ដោយអាហារប្បច្ច័យ គឺមានវារៈ ៣ ។ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ។ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៣ ។ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៣ ។ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៩ ។ ជាបច្ច័យដោយអត្ថិប្បច្ច័យ មានវារៈ ៩ ។ ជាបច្ច័យដោយនត្ថិប្បច្ច័យ មានវារៈ ៩ ។ ជាបច្ច័យដោយវិគតប្បច្ច័យ មានវារៈ ៩ ។ ជាបច្ច័យដោយអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៤០ ] ធម៌ជានីវរណៈ និងជានីវរណសម្បយុត្ត ជាបច្ច័យនៃធម៌ ជា

នីវរណៈ និងជានីវរណសម្បយុត្ត ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ វារៈទាំង ៩ បណ្ឌិតគប្បីប្រែត្រឡប់ ក្នុងបទទាំង ៣ យ៉ាងនេះចុះ ។

[ ២៤១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៤២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៤៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ អនុលោមមាតិកា បណ្ឌិតត្រូវធ្វើចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

**នីវរណនីវរណសម្បយុត្តទុកៈ ចប់**

# នីវរណវិប្បយុត្តនីវរណិយទុកៈ

## បដិច្ចវារៈ

[ ២៤៤ ] ធម៌ជានីវរណវិប្បយុត្ត និងជានីវរណិយៈ អាស្រ័យនូវធម៌

ជានីវរណវិប្បយុត្ត និងជានីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ ជានីវរណវិប្បយុត្ត និងជានីវរណិយៈ នូវខន្ធ ២ ... បដិសន្ធិ ។ សេចក្តីបម្រើញ ។ លោកិយ-ទុកៈ ក្នុងចូឡន្តរទុកៈយ៉ាងណា បណ្ឌិតគប្បីធ្វើយ៉ាងនោះដែរ មិនមានការធ្វើឲ្យផ្សេងៗ គ្នាឡើយ ។

នីវរណវិប្បយុត្តនីវរណិយទុកៈ ចប់

## បរាមាសទុកៈ

## បដិច្ចវារៈ

[ ២៤៥ ] នោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវបរាមាស ។ នោបរាមាសធម៌ អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ មិនមែនជាបរាមាស នូវខន្ធ ២ ... បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ពួកមហាភូត ។ បរាមាសធម៌ អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបរាមាស អាស្រ័យនូវពួកនោបរាមាសក្ខន្ធ ។ បរា-មាសធម៌ក្តី នោបរាមាសធម៌ក្តី អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង បរាមាសផង ចិត្តសមុដ្ឋានរូបផង

អាស្រ័យនូវខន្ធ ១ មិនមែនជាបរាមាសៈ នូវខន្ធ ២ ... ។ នោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ផង នូវនោបរាមាសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាបរាមាសផង នូវបរាមាសផង នូវខន្ធ ២ ... ។

[ ២៤៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ២៤៧ ] នោបរាមាសធម៌ អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ ជាអហេតុកៈ មិនមែនជាបរាមាស នូវខន្ធ ២ ... អហេតុកប្បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ២៤៨ ] នោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវបរាមាស ។ នោបរាមាសធម៌ អាស្រ័យនូវនោបរាមាសធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ដរាបដល់ពួកអសញ្ញសត្វ អាស្រ័យនូវពួកខន្ធ មិនមែនជាបរាមាស ។ នោបរាមាសធម៌ អាស្រ័យនូវបរាមាសធម៌ផង នូវនោបរាមាសធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវបរាមាសៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។

[ ២៤៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៥០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៥១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯសហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ២៥២ ] នោបរាមាសធម៌ ពឹងផ្អែកនឹងបរាមាសធម៌ ទើបកើតឡើង

ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងបរាមាស ។ នោបរាមាសធម៌ ពឹងផ្អែកនឹងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ ១ មិនមែនជាបរាមាស នឹងខន្ធ ២ ... បដិសន្ធិ ដរាបដល់ពួកមហាភូតខាងក្នុង ពួកនោបរាមាសក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ បរាមាសធម៌ពឹងផ្អែកនឹងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបរាមាសពឹងផ្អែកនឹងពួកនោបរាមាសក្ខន្ធ បរាមាសពឹងផ្អែកនឹងវត្ថុ ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ពឹងផ្អែកនឹងនោបរាមាសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង បរាមាសផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ ១ មិនមែនជាបរាមាស នឹងខន្ធ ២ ... បរាមាស ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត បរាមាសក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ។ នោបរាមាសធម៌ ពឹងផ្អែកនឹងបរាមាសធម៌ផង នឹងនោបរាមាសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្ត-សមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ មិនមែនជាបរាមាសផង នឹងបរាមាសផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងបរាមាសផង នឹងពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងបរាមាសផង នឹងពួកមហាភូតផង ពួកខន្ធមិនមែនជាបរាមាស ពឹងផ្អែកនឹងបរាមាសផង នឹងវត្ថុផង ។ សេចក្តីបង្រួញ ។

[ ២៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់សុទ្ធតែមាន

វារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ២៥៤ ] នោបរាមាសធម៌ ពឹងផ្អែកនឹងនោបរាមាសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ពឹងផ្អែកនឹងខន្ធ ១ មិនមែនជាបរាមាស ជាអហេតុកៈ នឹងខន្ធ ២ ... អហេតុកប្បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកខន្ធមិនមែនជាបរាមាស ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សេចក្តីបង្រួញ ។

[ ២៥៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៥៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ...

ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិតគប្បីធ្វើក្នុងបច្ច័យទាំងអស់យ៉ាងនេះចុះ ។

[ ២៥៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

និស្សយវារៈ ប្រហែលគ្នានឹងបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ២៥៨ ] នោបរាមាសធម៌ លាយឡំនឹងបរាមាសធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ លាយឡំនឹងបរាមាស ។ បញ្ហា ៥ ក្នុងអរូប បណ្ឌិតគប្បីធ្វើយ៉ាងនេះដែរ ។

សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ២៥៩ ] នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុមិនមែនជាបរាមាស ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ មិនមែនជាបរាមាស ជាបច្ច័យនៃបរាមាស ដោយហេតុប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុមិនមែនជាបរាមាស ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបរា-

មាសផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ២៦០ ] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺបរាមាស ប្រារព្ធនូវបរាមាស ទើបកើតឡើង ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ ។ ពួកខន្ធមិនមែនជាបរាមាស ប្រារព្ធនូវបរាមាស ទើបកើតឡើង ។ បរាមាសក្តី ពួកសម្បយុត្តកក្ខន្ធក្តី ប្រារព្ធនូវបរាមាស ទើបកើតឡើង ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គល នូវទាន ... នូវសីល ... ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវអំពើនោះ ត្រេកអរ រីករាយ រាគៈ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ( នូវអំពើទាំងឡាយ ) ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ... ចេញអំពីឈាន ( ពិចារណា ) នូវឈាន ... ពួកព្រះអរិយៈចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផល និងអាវជ្ជនៈ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ( ពិចារណា ) នូវពួកកិលេសមិនមែនជាបរាមាស ដែលលះបង់ហើយ ... នូវពួកកិលេសដែលសង្កត់សង្កិនហើយ ... ក្នុងកាលមុន នូវចក្ខុ ... នូវវត្ថុ ... ( ព្រះអរិយៈ ) ពិចារណាឃើញនូវពួកខន្ធ មិនមែនជាបរាមាស ថាមិនទៀង ត្រេកអរ រីករាយ រាគៈ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ( ព្រះអរិយៈ ) ឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយនោបរាមាសចិត្ត ដោយ

ចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចា-យតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពួកខន្ធមិនមែនជាបរាមាស ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ អនា-គតំសញ្ញាណ និងការពិចារណា ដោយអារម្មណប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ត្រេកអរ រីករាយនឹងអំពើនោះ ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ក្នុងកាលមុន ... អំពីឈាន ... ។បេ។ នូវចក្ខុ ... នូវវត្ថុ ... ត្រេកអរ រីករាយចំពោះពួកខន្ធ មិនមែនជាបរាមាស ទិដ្ឋិប្រារព្ធនូវខន្ធនោះ ... ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ត្រេកអរ រីករាយនឹងអំពើនោះ បរាមាសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ក្នុងកាលមុន ... អំពីឈាន ... នូវចក្ខុ ... នូវវត្ថុ ... ត្រេកអរ រីករាយ ចំពោះពួកខន្ធមិនមែនជាបរាមាស បរាមាសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយអារម្មណប្បច្ច័យ គឺប្រារព្ធនូវបរាមាសធម៌ផង នូវពួកសម្បយុត្តកក្ខន្ធផង ... មានវារៈ ៣ ។

[ ២៦១ ] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអធិបតិប្បច្ច័យ

គឺបរាមាស ( កើតឡើង ) ព្រោះធ្វើនូវបរាមាស ឲ្យជាទីគោរព បានដល់ អារម្មណាធិបតិហ្នឹងឯង បណ្ឌិតគប្បីធ្វើឲ្យមានវារៈ ៣ ចុះ ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... បុគ្គលពិចារណា ត្រេកអរ រីករាយ ព្រោះធ្វើនូវកុសលកម្មនោះ ឲ្យជាទីគោរព រាគៈកើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ក្នុងកាលមុន ... អំពីឈាន ... ពួកអរិយៈចេញអំពីមគ្គ ហើយធ្វើនូវមគ្គឲ្យជាទីគោរព ... នូវផលឲ្យជាទីគោរព ... នូវព្រះនិព្វាន ឲ្យជាទីគោរព ... ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធ មិនមែនជាបរាមាស ឲ្យជាទីគោរព រាគៈកើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិមិនមែនជាបរាមាស ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ អារម្មណាធិបតិ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ក្នុងកាលមុន ... អំពីឈាន ... ។បេ។ នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធ មិនមែនជាបរាមាស ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ... ។បេ។ ឯសហជាតាធិបតិ គឺអធិបតិ មិនមែនជាបរាមាស ជា

បច្ច័យនៃបរាមាស ដោយអធិបតិប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន ... នូវសីល ... នូវឧបោសថកម្ម ... ក្នុងកាលមុន ... អំពីឈាន ... ។បេ។ នូវចក្ខុ ... នូវវត្ថុ ... បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធ មិនមែនជាបរាមាសឲ្យជាទីគោរព បរាមាសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិ មិនមែនជាបរាមាស ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបរាមាសៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបរាមាស ធ្វើនូវបរាមាសផង នូវពួកសម្បយុត្តកក្ខន្ធផង ឲ្យជាទីគោរព ... មានវារៈ ៣ ។

[ ២៦២ ] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយអនន្តរប្បច្ច័យ គឺបរាមាសមុនៗ ជាបច្ច័យនៃបរាមាសក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ។ បរាមាសមុនៗ ជាបច្ច័យនៃពួកនោបរាមាសក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ បរាមាសជាបច្ច័យនៃវុដ្ឋានៈ ( ការចេញអំពីឈាន ) ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ បរាមាសមុនៗ ជាបច្ច័យនៃបរាមាសក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយ

អនន្តរប្បច្ច័យ គឺពួកនោបរាមាសក្ខន្ធមុនៗ ជាបច្ច័យនៃពួកនោបរាមាសក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោមជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ ។ ពួកនោបរា-មាសក្ខន្ធមុនៗ ជាបច្ច័យនៃបរាមាសក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃបរាមាស ដោយអនន្តរប្បច្ច័យ ។ ពួកនោបរាមាសក្ខន្ធមុនៗ ជាបច្ច័យនៃបរាមាសក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្ត-រប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃបរាមាសផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយអនន្តរប្បច្ច័យ គឺបរាមាសមុនៗ ផង ពួកសម្បយុត្ត-កក្ខន្ធផង ជាបច្ច័យនៃបរាមាសក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ ។ បរាមាសមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកនោបរាមាសក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ បរាមាសក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ បរាមាសមុនៗ ក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃបរាមាសក្រោយៗ ផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ បរាមាសធម៌ជាបច្ច័យនៃបរា-មាសធម៌ ដោយសមនន្តរប្បច្ច័យ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៥ ។

[ ២៦៣ ] បរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយឧបនិស្ស-

យប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូប-និស្ស័យ ។បេ។ បកតូបនិស្ស័យ គឺបរាមាស ជាបច្ច័យនៃបរាមាស ដោយឧបនិស្សយប្បច្ច័យ ។ មានវារៈ ៣ ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើងជំឡើងនូវមានះ នូវសីល ... ។បេ។ នូវបញ្ញា រាគៈ ទោសៈ មោហៈ មានះសេចក្តីប្រាថ្នា និងកាយិកសុខ ... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃបញ្ញានៃរាគៈ ។បេ។ នៃសេចក្តីប្រាថ្នា កាយិកសុខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ប្រកាន់នូវទិដ្ឋិ នូវសីល ... ។បេ។ នូវបញ្ញា រាគៈ សេចក្តីប្រាថ្នា និងកាយិកសុខ ... អាស្រ័យនូវសេនាសនៈ ហើយប្រកាន់នូវទិដ្ឋិ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃបរាមាស ដោយឧបនិស្សយប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។

បកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយប្រកាន់នូវទិដ្ឋិ នូវសីល ...។បេ។ អាស្រ័យនូវសេនាសនៈ ហើយប្រកាន់នូវទិដ្ឋិ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃបរាមាសៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃបរាមាសធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ ឧបនិស្ស័យទាំង ៣ គឺបរាមាសក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃបរាមាស ដោយឧបនិស្សយប្បច្ច័យ ។ មានវារៈ ៣ ។

[ ២៦៤ ] នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលពិចារណាឃើញនូវចក្ខុ ... នូវវត្ថុ ថាមិនទៀង ... ត្រេកអរ រីករាយ វិចិកិច្ឆា ឧទ្ធច្ចៈ និងទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកខន្ធមិនមែនជាបរាមាស ដោយបុរេជាតប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គល នឹងចក្ខុ ... ត្រេកអរ រីករាយ នឹងវត្ថុ ទិដ្ឋិ ( កើតឡើង ) ព្រោះប្រារព្ធនូវវត្ថុនោះ ... ។ ឯវត្ថុបុរេជាត គឺវត្ថុ

ជាបច្ច័យនៃបរាមាស ដោយបុរេជាតប្បច្ច័យ ។ នោបរាមាសធម៌ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គល នឹងចក្ខុ ... ត្រេកអរ រីករាយនឹងវត្ថុ បរាមាសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃបរាមាសផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។

[ ២៦៥ ] បរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺវារៈទាំង ៣ បណ្ឌិតគប្បីធ្វើឲ្យជាបច្ឆាជាត ។ ជាបច្ច័យដោយអាសេវនប្បច្ច័យ មានវារៈ ៩ ។

[ ២៦៦ ] នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺនោបរាមាសចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺនោបរាមាសចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ មូលទាំងឡាយ បណ្ឌិតគប្បីធ្វើផងចុះ ។ នោបរាមាសចេតនា ជាបច្ច័យនៃបរាមាស ដោយកម្មប្បច្ច័យ ។ នោបរាមាសចេតនា ជាបច្ច័យនៃបរាមាសផង នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ២៦៧ ] នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ ១ ។ ជាបច្ច័យដោយអាហារប្បច្ច័យ គឺមានវារៈ ៣

ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយឈានប្បច្ច័យ គឺមានវារៈ ៣ ។

[ ២៦៨ ] បរាមាសធម៌ជាបច្ច័យនៃនោបរាមាសធម៌ ដោយមគ្គប្បច្ច័យ បានដល់ ពួកអង្គនៃមគ្គជាបរាមាស ... បញ្ហាទាំង ៥ បណ្ឌិត គប្បីធ្វើយ៉ាង នេះចុះ ។ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ ៥ ។

[ ២៦៩ ] បរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ ។ នោបរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សេចក្តីបង្រួញ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃបរាមាស ដោយវិប្បយុត្តប្បច្ច័យ ។ នោបរាមាសធម៌ ជាបច្ច័យនៃបរាមាសធម៌ផង នៃនោបរាមាសធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃបរាមាសផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ បរាមាសធម៌ក្តី នោបរាមាសធម៌ក្តី ជាបច្ច័យនៃនោបរាមាសធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបង្រួញ ។

[ ២៧០ ] បរាមាសធម៌ ជាបច្ច័យនៃនោបរាមាសធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺបរាមាស ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯ

